# ចូរនិយាយឲ្យចំលើ ភាពឯកា



*ការយកជ័យជម្នះលើសមរភូមិនៃអារម្មណ៍ដោយ អំណាចនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់!*


## ចយស៍ ម៉ៃយ័រ


សៀវភៅដែលបានបោះពុម្ពមុនគឺ ជួយខ្ញុំផង ខ្ញុំជាមនុស្សឯកា!

# ចូរនិយាយឲ្យចំលើ

# ភាពឯកា

ចូរនិយាយឲ្យចំលើ

# ភាពឯកា

## ការទុកចិត្តព្រះនៅពេលមាន
## ភាពឯកានិងភាពទុក្ខសោក


**និពន្ធដោយ**

*ចយស៍ ម៉ៃយ័រ*

**បកប្រែដោយ**

លោក ទុំ គីមហ៊ីន

**កែសម្រួលដោយ**

វេជ្ជ. *យ៉ៃម ទេវីនាថ*

អ្នកស្រី *ផុន សិរីរតន៍*



JOYCE MEYER MINISTRIES

P.O. Box 548, Phnom Penh

CAMBODIA

ព្រះបន្ទូលនៅក្នុងសៀវភៅនេះត្រូវបានដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ
និង ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន។

រក្សាសិទ្ធិគ្រប់យ៉ាង © ដោយ ព័ន្ធកិច្ច ចយស៏ ម៉ៃយ័រ

**ចូរនិយាយឲ្យចំលើ ភាពឯកា**
*ការទុកចិត្តព្រះនៅពេលមាន*
*ភាពឯកានិងភាពសោកសៅ!*

បោះពុម្ពនៅភ្នំពេញ

# មាតិកា

*សេចក្តីផ្តើម* 7

*ជំពូក មួយ ៖* **កុំបោះបង់ចោលឲ្យសោះ** **11**

១- អ្នកមិននៅម្នាក់ឯងទេ 13

២- ភាពឯកាអាចប្រោសឲ្យជាបាន 21

៣- ប្រាំពីរដំណាក់កាលនៃភាពសោកសៅ 31

៤- ការជាសះស្បើយពីគ្រោះមហន្តរាយនិងការបាត់បង់ 63

*ជំពូក ពីរ ៖* **បទគម្ពីរ**

- ដើម្បីយកឈ្នះភាពឯកានិងភាពទុក្ខសោក 81

សេចក្តីបញ្ចប់ 85

***សេចក្តីអធិស្ឋាន***

- ការអធិស្ឋាននិងព្រះពរ 87
- សម្រាប់ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះជាម្ចាស់ 89

# សេចក្ដីផ្ដើម

បញ្ហាច្រើនជាងគេដែលមនុស្សលោកជួបសព្វថ្ងៃនេះគឺ ភាពសោកសៅនិងភាពឯកា ។ ការទាំងពីរនេះជាញឹកញាប់ដើរទន្ទឹមគ្នា ព្រោះមនុស្សជាច្រើនសោកសៅដោយសារតែភាពឯកា។

ភាពឯកាបានក្លាយទៅជាបញ្ហាសំខាន់ជាងកាលពីអតីត។ នៅក្នុងព័ន្ធកិច្ចរបស់ខ្ញុំចំនួនមនុស្សកើនឡើងស្នើសុំឲ្យអធិស្ឋានសម្រាប់ ការណែនាំនិងជួយដោះស្រាយជាមួយនឹងភាពឯកា។

នៅក្នុងព្រះបន្ទូលរបស់ទ្រង់ ព្រះអង្គមានបន្ទូលប្រាប់យើងថា យើងមិននៅម្នាក់ឯងទេ។ ទ្រង់គាប់ព្រះហឫទ័យប្រោសលោះ ជួយសំរាលទុក្ខ និងប្រោសយើងឲ្យបានជា។ តែនៅពេលមនុស្សជួបប្រទះជាមួយនឹងការឈឺចាប់ ដោយសារតែមានការបាត់បង់ដ៏ធំនៅក្នុងជីវិតរបស់ពួកគេ គួរឲ្យសោកស្ដាយណាស់ មានមនុស្សជាច្រើនមិនអាចយកឈ្នះលើវាបានទេ។ ពេលសោកនាដកម្មលេចមកហើយការឈឺចាប់ហាក់បីដូចជាទ្រាំមិនបាន សាតាំងឃើញថាវាជាឱកាស វាខំប្រឹងធ្វើលុះត្រាតែនាំអ្នកណាម្នាក់ ឬគ្រួសារណាមួយឲ្យធ្លាក់ទៅក្នុងការជាប់ចំណងរហូត។

ការស្លាប់មនុស្សជាទីស្រឡាញ់ណាម្នាក់ ការលែងលះ ឬការលែងមានទំនាក់ទំនងជិតស្និទ្ធណាមួយ អាចនាំមកនូវភាពសោកសៅ ហើយមនុស្សភាគច្រើនឆ្លងកាត់ដំណើរការនៃភាពសោកសៅនេះ។ គន្លឹះដើម្បីយកឈ្នះគឺត្រូវយល់ពីភាពខុសគ្នារវាង ភាពធម្មតា តុល្យភាព «ដំណើរការនៃភាពសោកសៅ» និង «វិញ្ញាណនៃ

ភាពសោកសៅ» ការមួយអាចជួយដល់អ្នកដែលកើតទុក្ខឲ្យបានជាសះស្បើយពីការបាត់បង់ដោយប្រើពេលវេលា ការមួយផ្សេងទៀតអាចធ្វើឲ្យគាត់កាន់តែធ្ងន់ជាងមុន ហើយលិចកាន់តែជ្រៅទៅក្នុងភាពអស់សង្ឃឹម។

ខ្ញុំជឿហេតុផលមួយ ដែលធ្វើឲ្យមនុស្ស ជាពិសេសគ្រិស្តបរិស័ទជាប់ចំណងជាមួយភាពសោកសៅ និងភាពឯកាគឺដោយសារការបាត់បង់និងដោយសារខ្វះការយល់ដឹងអំពី«ដំណើរការនៃភាពសោក សៅ»។ ពេលខ្លះ ព្រះបានប្រោសឲ្យជាឃើញលទ្ធផលភ្លាមៗ។ តែជាញឹកញាប់ ជាពិសេសការប្រោសឲ្យជាពីការបាត់បង់ គឺជាការប្រោសឲ្យជាដែលប្រើពេលវេលា ដែលព្រះអម្ចាស់នាំបុត្រធីតារបស់ទ្រង់ដើរឆ្លងមួយជំហានម្តងៗ។ ប្រាកដណាស់ មនុស្សគ្រប់គ្នាអត់បានឆ្លើយតបចំពោះការបាត់បង់តាមរបៀបដូចគ្នាទេ ឬនៅក្នុងកំរិតដូចគ្នាដែរ តែយើងទាំងអស់គ្នាមានអារម្មណ៍ដែលអាចជារបួសនិងស្នាមជាំដែលត្រូវការ ការប្រោសឲ្យជា។

ព្រះយេស៊ូបានយាងមកផែនដីដើម្បីបំផ្លាញផែនការរបស់សាតាំង(១យ៉ូហាន ៣:៨) ហើយប្រទានជីវិតពេញបរិបូរណ៌(យ៉ូហាន១០:១០)! បើសិនជាយើងរៀនពីរបៀបនៃការទទួល អ្វីដែលព្រះអង្គបានរៀបចំឲ្យយើង យើងនឹងមានបទពិសោធន៍នៃជីវិតពេញបរិបូរណ៌ដែលមានសេរីភាពពីភាពសោកសៅនិងពីភាពឯកា។

ព្រះបានរំដោះខ្ញុំពីចំណងនៃភាពសោកសៅនិងភាពឯកា ហើយខ្ញុំជឿថា ព្រះអង្គនឹងប្រើវាមួយជំហានម្តងៗ ក្នុងសៀវភៅនេះដើម្បីជួយអ្នកឲ្យមានសេរីភាពផងដែរ!

# ជំពូក មួយ

## កុំប្បោះបង់ចោលឲ្យសោះ

# ១

# អ្នកមិននៅម្នាក់ឯងទេ

ឯព្រះយេស៊ូវ ទ្រង់យាងមកមានព្រះបន្ទូលនឹងគេថា ... ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប។ អាម៉ែន។

*ម៉ាថាយ ២៨:១៨-២០*

# ១

# អ្នកមិននៅម្នាក់ឯងទេ

*ព្រះអម្ចាស់មានព្រះបន្ទូលថា:«ដោយគេស្ថិតនៅជាប់នឹងយើង យើងនឹងជួយរំដោះគេ យើងនឹងការពារគេ ព្រោះគេទទួលស្គាល់ថា យើងជា**ព្រះអម្ចាស់**! គេនឹងអង្វររកយើង ហើយយើងនឹងឆ្លើយតបមកគេវិញនៅពេលគេមានអាសន្ន យើងនឹងស្ថិតនៅជាមួយគេ យើងនឹងរំដោះគេ ព្រមទាំងលើកតម្កើងគេផង។*

*យើងនឹងឲ្យគេមានអាយុយឺនយូរ ហើយយើងនឹងឲ្យគេឃើញថា យើងពិតជាព្រះសង្គ្រោះមែន»។*

*ទំនុកដំកើត៩១:១៤-១៦*

ព្រះគាប់ព្រះហឫទ័យឲ្យអ្នកដឹងថា អ្នកមិននៅម្នាក់ឯងទេ។ សាតាំងវិញចង់ឲ្យអ្នកជឿថា អ្នកទាំងអស់គ្នានៅម្នាក់ឯង តែអ្នកមិននៅម្នាក់ឯងទេ។ វាចង់ឲ្យអ្នកជឿថា គ្មានអ្នកណាម្នាក់យល់ចិត្ត និងយល់ពីអារម្មណ៍ដែលអ្នកមានយ៉ាងដូចម្ដេចនោះទេ តែការនោះមិនមែនជាការពិតទេ។

ថែមពីលើនោះព្រះគង់ជាមួយអ្នក មានអ្នកជឿព្រះជាច្រើនដឹងថាអ្នកមាន អា រម្មណ៍យ៉ាងដូចម្ដេចហើយយល់ពីបទពិសោធន៍ផ្លូវចិត្តនិងអារម្មណ៍ដែលអ្នកមាន។ ទំនុកតម្កើង៣៤:១៩ បានថ្លែងថា «មនុស្សសុចរិតរមែងជួបនឹងទុក្ខលំបាកជាច្រើន ប៉ុន្តែ ព្រះអម្ចាស់តែងតែរំដោះគេឲ្យរួចផុតពីទុក្ខលំបាកទាំងនោះជានិច្ច។» មានដំ ណើរ រឿងជាច្រើននៅក្នុងព្រះគម្ពីរពី«ទុក្ខលំបាករបស់មនុស្សសុចរិត» (KJV) ហើយ ព្រះជាម្ចាស់រំដោះពួកគេឲ្យរួចជានិច្ច។

***ព្រះអង្គគឺជាព្រះប្រោសលោះ***

ព្រះអង្គបានរំដោះលោកប៉ូលនិងលោកស៊ីឡាស់ពីឃុំឃាំង។

*កិច្ចការ១៦:២៣-២៦*

នៅក្នុង១សាំយ៉ូអែល១៧:៣៧យើងអានពីការដែលព្រះបានរំដោះដាវីឌពីទុក្ខលំបាក។ ដាវីឌពោលបន្តទៀតថា៖«ព្រះអម្ចាស់តែងតែជួយទូលបង្គំឲ្យរួចពីក្រញាំតោ និងខ្លាឃ្មុំ ព្រះអង្គមុខជាជួយទូលបង្គំឲ្យរួចផុតពីកណ្តាប់ដៃរបស់ជនភីលីស្ទីននេះមិនខាន»។ ឮដូច្នេះ ព្រះបាទសូលមានរាជឱង្ការទៅកាន់ដាវីឌថា៖ «ទៅចុះ! សូមព្រះអម្ចាស់គង់ជាមួយអ្នក»។

ពេលដែលអ្នកចាប់ផ្តើមរីកចំរើន ជាញឹកញាប់ សាតាំងនាំទុក្ខលំបាកដើម្បីឲ្យអ្នកបាក់ទឹកចិត្ត ហើយវាព្យាយាមធ្វើឲ្យអ្នកមានអារម្មណ៍ឯកា។ អ្វីដែលសាតាំងចង់ធ្វើចំពោះយើងគឺការឈឺចាប់ តែព្រះអង្គនឹងធ្វើការនោះឲ្យទៅជាល្អសម្រាប់យើងវិញ។ (សូមមើលក្នុងលោកុប្បត្តិ៥០:២០)។ អ្នកអាចធ្វើដូចអ្វីដែលដាវីឌបានធ្វើនៅក្នុងបទគម្ពីរខាងលើ ហើយលើកទឹកចិត្តខ្លួនឯងដោយការចងចាំចំពោះជ័យជំនះដែលមានពីអតីត។

លោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌ-នេកោ មានបទពិសោធន៍ជាមួយទុក្ខលំបាក ពួកគេនៅតែខ្ជាប់ខ្ជួននៅក្នុងការប្តេជ្ញាចិត្តចំពោះព្រះពិតតែមួយ (ដានីយ៉ែល៣:១០-៣០)។ នៅពេលដែលពួកគេបដិសេធព្រះចៅនេប៊ូក្នេសាជាស្តេចអាក្រក់មិនព្រមក្រាបថ្វាយបង្គំរូបបដិមាមាសដែលបានតាំងឡើង។ ព្រះចៅនេប៊ូក្នេសាបោះអស់លោកភ្លាម ទៅក្នុងភ្លើងដែលឆេះយ៉ាងសន្ធោសន្ធៅហើយទ្រង់ដុតកំដៅប្រាំពីរដងក្តៅជាងធម្មតា។

ព្រះចៅនេប៊ូក្នេសា «រន្ធត់ព្រះហឫទ័យ» ជាខ្លាំង (ខ២៤) ក្នុងការឃើញ លោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌ-នេកោ ជួបជាមួយមនុស្សទីបួនដែល

នៅក្នុង ភ្លើងដែលកំពុងឆេះយ៉ាងសន្ធោសន្ធៅ រីឯអ្នកទីបួន មានទ្រង់ទ្រាយ «ដូចបុត្រារបស់ព្រះ» (ខ២៧ KJV)។ ភ្លើងពុំមានអំណាចអ្វីលើរូបកាយរបស់បុរសទាំងបីសោះ ហើយពួកគេក៏អត់មានផុំក្លិនឈ្ងៀមដែរ(ខ២៧)។

នៅក្នុខ៣០បានប្រាប់យើងថា ព្រះរាជាប្រោសប្រទានឲ្យលោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌ-នេកោមានបុណ្យស័ក្តិកាន់តែខ្ពង់ខ្ពស់ឡើង។ ព្រះមិនគ្រាន់តែនាំអ្នកចេញពីទុក្ខលំបាកទេ តែទ្រង់នឹងលើកអ្នកឲ្យបានខ្ពង់ខ្ពស់ឡើងផងដែរ។

ដានីយ៉ែលក៏មានទុក្ខលំបាកដែរ។ ការដាក់ទោសដោយសារតែគាត់ស្មោះត្រង់និងការប្តូរផ្តាច់ជាមួយព្រះ លោកដានីយ៉ែលត្រូវបានយកទៅដាក់នៅក្នុងរូងតោ។ តែដានីយ៉ែលជ្រើសរើសក្នុងការទុកចិត្តព្រះ ហើយព្រះអង្គបានចាត់ទេវតាឲ្យមកបិទមាត់របស់តោ។ លោកដានីយ៉ែលចេញមកដោយមិនមានគ្រោះថ្នាក់អ្វីសោះ(ដានីយ៉ែល ៦:៣-២៣)។ ចូររក្សាការទុកចិត្តលើព្រះ អ្នកនឹងចេញមកដោយមិនមានគ្រោះថ្នាក់អ្វី។

អ្នកទាំងអស់នោះបានអោយដឹងថា ព្រះអង្គជាព្រះស្មោះត្រង់។ ខ្ញុំក៏មានបទពិសោធន៍ផងដែរ ជាមួយនឹងក្តីមេត្តា និងភាពស្មោះត្រង់របស់ទ្រង់។ ខ្ញុំធ្លាប់បានទទួលការរំលោភបំពានផ្លូវភេទ ផ្លូវចិត្តនិងផ្លូវអារម្មណ៍ពីកុមារ។ ខ្ញុំធ្លាប់ឈឺចាប់នៅក្នុងជីវិតរបស់ខ្ញុំ ហើយបូកបញ្ចូលដប់ឆ្នាំដែលខ្ញុំមានជំងឺ ឈឺមួយចំហៀងក្បាល ហើយមានជំងឺមហារីកវាយលុកហើយរួមជាមួយជំងឺតូចៗមួយចំនួនថែមទៀត តែយ៉ាងណាក៏ដោយ ការឈឺចាប់និងអារម្មណ៍ទុក្ខព្រួយជាជំងឺ។

នៅក្នុងករណីនិមួយៗព្រះរំដោះខ្ញុំ ហើយផ្តល់ចម្លើយដល់ខ្ញុំ។ តែមានពេលដែលត្រូវរង់ចាំព្រះហើយត្រូវតែស្មោះត្រង់។

ព្រះគម្ពីរ ១ពេត្រុស៥:៨,៩ ថ្លែងថា:

*ត្រូវភ្ញាក់ខ្លួន (ចេះប្រមាណមានចិត្តនឹងធឹង)ហើយប្រុងស្មារតីជានិច្ច! ដ្បិត*

*មារ*ជាសត្រូវនឹងបងប្អូនកំពុងតែក្រវែលជុំវិញបងប្អូនដូចសឹង្ហក្រវែលទាំងគ្រហឹម (ពេញដោយភ្លើងកំហឹង) រកត្របាក់ស៊ីអ្នកណាម្នាក់។*

*ចូរប្រឆាំងនឹងវា ហើយមានជំនឿមាំមួនឡើង(ប្រឆាំងជាមួយនឹងការចាប់ផ្ដើមចាក់ឫស ការបង្កើត រឹងមាំ ដែលមិនអាចផ្លាស់ប្ដូរបាន និងការកំណត់) ដោយដឹងថា បងប្អូនរួមជំនឿ(ដូចគ្នា)ឯទៀតៗ នៅក្នុងសកលលោកទាំងមូល (នៅក្នុងរូបការរបស់ព្រះគ្រិស្ដ) ក៏ត្រូវរងទុក្ខលំបាកដូចបងប្អូនដែរ។*

ដូចដែលយើងបានឃើញហើយ ទុក្ខលំបាកធ្លាក់មកលើយើងទាំងអស់គ្នា។ យើងគ្រប់គ្នាមានបទពិសោធន៍នូវទុក្ខព្រួយមួយចំនួន និងភាពឯកានៅក្នុងជីវិតនេះ ពីមួយពេល ទៅមួយពេល តែយើងមិននៅម្នាក់ឯងទេ។ ព្រះគម្ពីរបានប្រាប់យើងឲ្យតតាំងជាមួយនឹងមារៈ«តតាំង»ជាមួយវា«ស្មោះត្រង់ជាមួយនឹងជំនឿ»ខ៩ KIV) តែយើងអាចមានកម្លាំងដោយដឹងថាអ្នកដទៃយល់ពីអារម្មណ៍របស់យើង។

## *ព្រះអង្គធ្វើការដើម្បីឲ្យយើងបានទទួលផលល្អ*

ព្រះអង្គល្អនិងទ្រង់ស្មោះត្រង់។ កាលពីពីរបីឆ្នាំមុនខ្ញុំបានជួបជាមួយអារម្មណ៍រន្ធត់យ៉ាងខ្លាំង ដែលបានញែកខ្ញុំចេញពីមនុស្សនិងអ្វីៗដែលខ្ញុំស្រឡាញ់។ ព្រះគាប់ព្រះហឫទ័យឲ្យខ្ញុំធ្វើសកម្មភាព ប៉ុន្តែខ្ញុំមិនស្ដាប់បង្គាប់ដល់ទ្រង់ទេ។ ព្រះអង្គធ្វើការដើម្បីឲ្យខ្ញុំបានទទួលផលល្អ ទោះបីជាខ្ញុំអត់បានឃើញការល្អនៅពេលនោះក្ដី។ ពេលដែលខ្ញុំអត់បានធ្វើសកម្មភាព ព្រះធ្វើការក្នុងខ្ញុំនិងក្នុងអ្នកខ្លះនៅក្នុងជីវិតរបស់ខ្ញុំ។ នៅពេលនេះខ្ញុំដឹងថា វាគឺជាការមួយដ៏ល្អបំផុតដែលបានកើតឡើងដល់ខ្ញុំ តែពេលមួយ ខ្ញុំគិតថា លោកីយ៍ទាំងមូលបាក់បែកខ្ទេចខ្ទីអស់ហើយ។ ខ្ញុំអត់ប្រាកដទេថា ខ្ញុំអាចបានជាសះស្បើយវិញទេ។

សេចក្ដីស្លាប់និងការលែងលះមិនគ្រាន់តែជា ការបាត់បង់ដែលងើបមុខលែងរួចដែលមនុស្សបានប្រឈមមុខនោះទេ។ ការបាត់បង់ទំនាក់ទំនងអស់រយៈពេលយូរ ឬការងារដែលសំខាន់ចំពោះអ្នកក៏អាចជាគ្រោះថ្នាក់ដែរ។

របួសផ្ទាល់ខ្លួនអាចរារាំងអ្នកពីការស្វែងរកកិច្ចការកំសាន្ត ឬពីកីឡាដែលធ្លាប់ជាផ្នែកមួយដ៏សំខាន់នៅក្នុងជីវិតរបស់អ្នក អាចជាអារម្មណ៍ដ៏ពិបាកមួយដែរ។ តាមពិត ការបាត់បង់អ្នកណាម្នាក់ ឬអ្វីមួយ ដែលវាសំខាន់ខ្លាំងម្រាប់យើងជាការលំបាកយ៉ាង។

ខ្ញុំបានជាសះស្បើយទាំងស្រុងឡើងវិញ បានត្រូវចំណាយពេលអស់ជិត៣ឆ្នាំ ប៉ុន្តែ ខ្ញុំបានធ្វើអោយមានស្ថិរភាព ពិតជារីកចំរើនក្នុងកំឡុងពេលនោះ។ អ្វីមួយដែលចុងបញ្ចប់បានជួយខ្ញុំឲ្យបានជាពីការឈឺចាប់ដ៏ខ្លាំង គឺការយល់ដឹងពី *«ចំណងនៃព្រលឹង»*។

### ***«ចំណងនៃព្រលឹង»***

ការចំណាយពេលជាច្រើនជាមួយមនុស្សណាម្នាក់ ឬអ្វីមួយនោះនឹងនាំទៅរកចំណងនៃទំនាក់ទំនងជាមួយអ្នកនោះ ឬជាមួយអ្វីមួយនោះ។

ក្នុងនាមជាមនុស្ស យើងជាវិញ្ញាណ យើងមានព្រលឹង ហើយយើងរស់នៅក្នុងរូបកាយ។ ព្រលឹងអាចគិតការចាត់ចែងរបស់គំនិត បំណងចិត្តនិងអារម្មណ៍។

ការចូលរួមតម្រូវឲ្យចំណាយពេលវេលាទាំងកម្លាំងស្មារតី ការគិត និងគម្រោង ។ ជាទូទៅ យើងនិយាយភាគច្រើនអំពីអ្វីដែលទាក់ទងទៅនឹងគំនិត បំណងប្រាថ្នានិងអារម្មណ៍របស់យើង។ ដោយផ្តល់ការគិតបន្តិចបន្តួចពីវា យើងអាចឃើញថា «ព្រលឹង»របស់យើងចូលរួមជាមួយយ៉ាងដូចម្តេចនៅក្នុងមនុស្សនិងអ្វីៗដែលយើងបានដាក់ទុនពេលវេលានិងថាមពលភាគច្រើនបំផុតរបស់យើង។

បើសិនជាដៃរបស់ខ្ញុំចងភ្ជាប់ទៅខាងក្រោយហើយភ្ជាប់វានៅទីនោះ អត់បានធ្វើចលនា មួយឆ្នាំ វាអាចជះឥទ្ធិពលអាក្រក់ធ្វើឲ្យខូច។ បើសិនមិនបានស្រាយភ្លាមៗទេ ខ្ញុំអាចឃើញថា វាមិនគ្រាន់តែស្លេកស្លាំង ហើយខ្សោយតែប៉ុណ្ណោះទេ តែថែមទាំងពិការថែមទៀតផង។ វាមិនអាចទៅរួចសម្រាប់ខ្ញុំ ក្នុងការប្រើដៃនោះ

បានល្អទេ លុះត្រាតែវាចាប់ផ្ដើមមានកម្លាំងឡើងវិញហើយអាចធ្វើចលនាបាន។ យើងត្រូវតែរៀនតាមរបៀបថ្មីដើម្បីមានដំណើរការ និងអភិវឌ្ឍន៍សាច់ដុំដែលលែងលូតលាស់ដោយសារអត់បានប្រើវា។

វាមានសភាពដូចគ្នាជាមួយនឹងព្រលឹងរបស់យើងដែរ។ ពេលដែលយើងរួមចំណែកជាមួយមនុស្ស នៅកន្លែងណាមួយ ឬអ្វីមួយយូរពេក យើងនឹងអភិវឌ្ឍ «ចំណងនៃព្រលឹង» នៅពេលអ្នកនោះ ឬកន្លែងនោះ ឬអ្វីមួយនោះកំពុងតែយកចេញពីយើង ហើយយើងធ្វើហាក់បីដូចជាយើងកំពុងតែរួមចំណែកជាមួយនឹងការទាំងនោះដែរ។ វាដូចជាដៃដែលយើងចងទៅខាងក្រោយដូចគ្នាដែរ ទោះបីជាពេលក្រោយត្រូវបានស្រាយហើយក្ដី វានៅតែមាន «អារម្មណ៍» ថាជាប់ចំណងដូចមុនដដែល។ វាអត់បានដំណើរការល្អដូចដើមបានទេ ទាល់តែចំណាយពេលមួយរយៈ ហើយការខំប្រឹងធ្វើការដើម្បីឲ្យរូបកាយបានស្ដារឡើងវិញ។

ទោះបីជាយើងដើរចេញពីអ្នកណាម្នាក់ដោយស្ម័គ្រពីចិត្តឬពីអ្វីមួយក្ដី ព្រលឹងរបស់យើង អាចនៅតែចងនៅកន្លែងដែលវាធ្លាប់នៅ។ អារម្មណ៍ពិតជាខ្លាំង ហើយវាអាចធ្វើឲ្យយើងឈឺកាន់តែខ្លាំង ហើយមានភាពខ្ទោចផ្សារក្នុងអារម្មណ៍។ យើងត្រូវតែដឹងថា យើងអាចប្រើ «បំណងប្រាថ្នា» របស់យើង ដើម្បីសម្រេចក្នុងការធ្វើ ឬមិនធ្វើអ្វីមួយ។ ចេតនាសម្រេចចិត្តដ៏រឹងមាំនឹងកើតឡើងដោយពុះកញ្ជ្រោលនិងខ្ទោលឡើង។

«ចំណងព្រលឹង» មានត្រូវនិងមានខុស។ ការត្រឹមត្រូវនោះចេះថ្លឹងថ្លែងពេលវេលា ការដែលខុសនោះត្រូវតែដោះស្រាយ។

មិនថាអ្នកកំពុងជួបប្រទះជាមួយស្ថានភាពបែបណាទេនៅពេលនេះ បើសិនជាអ្នកដោះស្រាយមិនបានត្រឹមត្រូវទេ វានឹងធ្វើឲ្យអ្នកជាប់គាំង។ ទោះបីជាយ៉ាងណាក្ដី ព្រះជ្រាបពីរបៀបក្នុងការដោះស្រាយវា!

បើសិនជាអ្នកមានរបួសនៅក្នុងគ្រោះថ្នាក់ អ្នកត្រូវតែរៀនក្នុងការដើរសារជាថ្មី

ម្តងហើយម្តងទៀត។

ប្រសិនបើអ្នកបាត់បង់ប្តី ប្រពន្ធ របស់អ្នកដោយសារសេចក្តីស្លាប់ ឬលែងលះក្តី អ្នកត្រូវតែរៀនក្នុងការដោះស្រាយម្តងមួយៗ។ អ្នកត្រូវតែរៀនធ្វើអ្វីមួយដែលអ្នកភ្លេចពីរបៀបនៃការធ្វើវា ឬអ្វីដែលអ្នកមិនធ្លាប់ធ្វើពីមុន។ អ្នកប្រហែលជាត្រូវតែមានការងារធ្វើ ឬរៀនក្នុងការចំអិនម្ហូប ហើយថែទាំកុមារ ឬធ្វើការសម្រេចចិត្តដែលអ្នកអត់ធ្លាប់សម្រេចចិត្តហើយអ្នកអត់ធ្លាប់ដឹងពីមុន។

ប្រសិនបើ អ្នកបាត់បង់ការងាររបស់អ្នក អ្នកត្រូវតែរៀនពីរកទីផ្សារដោយខ្លួនឯងម្តងហើយម្តងទៀត ឬប្រហែលជាអាចផ្លាស់ប្តូរទីកន្លែងជាថ្មី និងស្ថានភាពថ្មី។

នៅពេលដែលអ្នកកំពុងធ្វើការថ្មីទាំងនោះ អ្នកអាចនៅតែមានការឈឺចាប់ តែអ្នកអាចស្កប់ចិត្ត ដោយដឹងថាអ្នកត្រូវធ្វើដំណើរទៅមុខ។ ពីមួយថ្ងៃទៅមួយថ្ងៃអ្នកកំពុងតែរីកចំរើន។ ព្រះបានសន្យាថា ទ្រង់គង់នៅជាមួយអ្នកពេលអ្នកមានបញ្ហា។ ពេលដែលអ្នកកំពុងតែរង់ចាំព្រះអង្គ ដើម្បីរំដោះអ្នក អ្នកអាចមានភាពកក់ក្តៅដោយដឹងថា ព្រះអង្គគង់នៅជាមួយអ្នកហើយធ្វើការជំនួសអ្នក ទោះបីជាអ្នកអត់បានឃើញអ្វីដែលទ្រង់កំពុងធ្វើនៅក្នុងលោកីយ៍នេះក្តី។ ព្រះគម្ពីរម៉ាថាយ២៨:២០ បានថ្លែងថា «...ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប។ អាម៉ែន។:៚

# ២

# ភាពឯការអាចប្រោសឲ្យជាបាន

*...ដ្បិតអញនឹងបំប្រែសេចក្តីសោកសៅរបស់គេទៅជាសេចក្តីអំណរវិញ ហើយកំសាន្តចិត្តគេ ព្រមទាំងឲ្យគេរីករាយចេញពីសេចក្តីទុក្ខព្រួយរបស់គេ។*

*យេរេមា៣១:១៣*

# ២

# ភាពឯកាអាចព្យាបាលឲ្យជាបាន

ភាពឯកាមិនមែនជាអំពើបាបទេ។ ដូច្នេះ បើអ្នកឯកា សូមកុំបន្ថែមអារម្មណ៍មានកំហុសទៅក្នុងបញ្ជីនៃការឈឺចាប់ខាងផ្លូវចិត្តរបស់អ្នកថែមទៀតឡើយ។

ភាពឯកាអាចព្យាបាលឲ្យជាបាន មិនថាកើតឡើងដោយសារអ្វីទេ។ អស់អ្នកដែលឈឺចាប់ភាគច្រើនដោយសារភាពឯកា គឺនៅក្នុងទំរង់នៃភាពទុក្ខព្រួយ ភាពអៀនខ្មាស់ ឬភាពអាម៉ាស់យ៉ាងខ្លាំង អស់អ្នកដែលយល់ខុស និងអស់អ្នកដែលជាអ្នកដឹកនាំ ការលែងលះនិងការនៅព្រៅ ស្រ្តីមេម៉ាយ ចាស់ជរា អស់អ្នកដែលមានអារម្មណ៍ថាគេបដិសេធ អស់អ្នកដែលមានអារម្មណ៍«មិនធម្មតា» ឬខុសពីអ្នកផ្សេងទៀត ទទួលការរំលោភបំពានផ្លូវភេទ អស់អ្នកដែលមិនអាចរក្សាទំនាក់ទំនងឲ្យបានល្អ ជាពិសេសជាមួយភេទផ្ទុយគ្នា អស់អ្នកដែលត្រូវតែផ្លាស់ប្តូរទីលំនៅ ឬប្តូរការងារ ឬបញ្ជីមានជាបន្តបន្ទាប់ទៀត។

មានហេតុជាច្រើនដែលធ្វើឲ្យឯកា។ តែមានមនុស្សជាច្រើនអត់ដឹងថា ពួកគេមិនចាំបាច់រស់នៅជាមួយវាទេ។ តែពួកគេអាចប្រឈមមុខហើយដោះស្រាយជាមួយវាបាន។

ពាក្យនេះមកពីឫសគល់នៃពាក្យ*(Lone)(ឯកឯង)* វចនានុក្រមវេបស្ទើរឲ្យនិយមន័យថា «គ្មានអ្នកនៅជាមួយៈ ញែកដោយឡែកពីអ្នកដទៃ... ទីលំនៅ ឬ ការឈរដោយខ្លួនឯង»។ Lonely(ភាពឯកោ) គឺជាគុណនាម មានន័យថា «នៅឆ្ងាយដាច់ពីគេ... ភាពឯកោ... ដែលខកចិត្តដោយសារការនៅម្នាក់ឯង»។ ហើយពាក្យ Lonesome មានន័យថា «ការខកចិត្ត បណ្តាលមកពីខ្វះអត់មានអ្នកមិត្តភាព... ការបោះបង់ចោល...»។

ភាពឯកាជាញឹកញាប់សំដែងឲ្យឃើញពីការឈឺចាប់ខាងក្នុង អ្វីៗដែលទទេ

ឬការទទូចចង់បានអ្វីមួយយ៉ាងខ្លាំង។ វាគឺជាការទទួលឥទ្ធិពលដោយបូកជាមួយអារម្មណ៍កណ្ដោចកណ្ដែង គ្មានប្រយោជន៍ ឬគ្មានគោលបំណងច្បាស់លាស់។ ផ្នែកដែលរងគ្រោះដោយសារឥទ្ធិពលនៃភាពឯកាជាញឹកញាប់នោះធ្វើឲ្យមានភាពតានតឹង ដែលនៅក្នុងករណីខ្លះ អាចនាំទៅរកការធ្វើអត្តឃាតខ្លួនឯង។

វាគួរឲ្យស្ដាយក្នុងការនិយាយបែបនេះ តែមានមនុស្សជាច្រើនបានធ្វើអត្តឃាតខ្លួនឯង ព្រោះពួកគេអត់ដឹងពីរបៀបក្នុងការដោះស្រាយជាមួយនឹងភាពឯកា ឬដោយសារពួកគេអត់ប្រឈមមុខបានត្រឹមត្រូវ និងដោះស្រាយជាមួយវាដោយឥរិយាបថនៃការប្រាកដនិយម។ សូម្បីតែគ្រិស្តបរិស័ទក៏ធ្លាក់ទៅក្នុងការរងគ្រោះដែលគំរាមកំហែងដោយខ្មាំងសត្រូវដែរ។

*ម្នាក់ឯងមិនមែនមានន័យថាឯកានោះទេ*

វចនានុក្រមបានឲ្យអត្ថន័យពាក្យ ម្នាក់ឯងជា «ឯកោ... អត់មានអ្វីដែលត្រូវដាក់បន្ថែម...ញែកដោយឡែកពីអ្នកដទៃ...» យោងតាមវចនានុក្រមវេបស្ទើរ ពាក្យ *ឯកានិងការកើតទុក្ខបណ្ដាលមកពីឯកា*អាចនាំរកចំណុចមួយដែលមានអារម្មណ៍ថាឯកោដែលជាលទ្ធផលនៃការខ្វះមិត្តភាព។»

តើអ្នកនៅតែម្នាក់ឯង(ឯករាជ្យ ញែកដោយឡែក នៅតែម្នាក់ឯង) តើអ្នកឯកា ឬកើតទុក្ខដោយសារតែភាពឯកោ(តែឯង បោះបង់ចោល ខកចិត្តដោយសារតែអត់មានមិត្តភាព)មែនទេ? វាមានភាពខុសគ្នា។

វាពិតជាការសំខាន់ណាស់ក្នុងការដឹងថា បើសិនជាអ្នកគ្រាន់តែនៅម្នាក់ឯងមិនមែនមានន័យថា អ្នកត្រូវឯកា ឬកើតទុក្ខដោយសារតែភាពឯកានោះឡើយ។

ទោះបីជាស្ថិតនៅក្នុងស្ថានភាពដែលមានមិត្តភាពជាមួយមនុស្សផ្សេងៗក្ដី មិនអាចធានាថាលែងមានវត្តមាននៃភាពឯកានោះទេ។

កាលៈទេសៈដែលបង្កើតឲ្យមានភាពឯកាគឺស្ថានភាពដែលបានកន្លងផុតទៅ

ហើយ។ មនុស្សដែលបានចាកចេញពីមិត្តសម្លាញ់ហើយធ្វើដំណើរទៅផ្ទះថ្មីនៅក្នុងទីក្រុងថ្មីអាចមានបទពិសោធន៍នៃភាពឯកាបណ្ដោះអាសន្ននេះ តែគាត់នឹងបង្កើតមិត្តភ័ក្រថ្មី។

តែមានស្ថានការជាច្រើនដែលបង្កើតឲ្យមានអារម្មណ៍ឯកាបានយូរហួសពីធម្មតា តែការទាំងនេះអាចដោះស្រាយបាន។

នៅពេលដែលមិនអាចឃាត់មិនឲ្យមានភាពឯកាបាននោះ តែងតែមានចម្លើយជានិច្ចចំពោះភាពឯកានោះដែរ!

## ***ភាពឯកាបណ្ដាលមកពីវិបត្តិ ឬ ការប៉ះទង្គិច***

ជាច្រើនដងភាពឯកាកើតឡើងមកពីការប៉ះទង្គិច ឬ វិបត្តិដោយសារមនុស្សដែលជាទីស្រឡាញ់បានបាត់បង់ជីវិត ដូចជា(ស្វាមី ភរិយា កូន ឪពុកម្ដាយ មិត្តភ័ក្រជិតស្និទ្ធ ឬញាតិសណ្ដាន) ការលែងលះ ឬការនៅបែកគ្នាជាដើម។ពេលមានអ្វីមួយកើតឡើងធ្វើឲ្យយើងដឹងពីអ្វីៗដែល វាមិនអាចដូចអ្វីដែលវាធ្លាប់មានពីមុនទេ ជាញឹកញាប់វាបង្កើតឲ្យមានវិបត្តិ ឬការមិនសប្បាយចិត្តនៅក្នុងជីវិតរបស់យើងដែលអាចនាំយើងទៅរកអារម្មណ៍ឯកានិងអស់សង្ឃឹមផងដែរ។

ជាធម្មជាតិ ស្ថានភាពវិបត្តិតម្រូវឲ្យយើងចេញពីផ្លូវមួយទៅផ្លូវមួយទៀត ដើម្បីឲ្យបានប្រសើរឡើង ឬកាន់តែអាក្រក់ឡើង ដើម្បីឲ្យមានជ័យជំនះ ឬបរាជ័យ។

យើងទាំងអស់គ្នាធ្លាប់ទស្សនាខ្សែភាពយន្តដែលបរិយាយពីការឈឺធ្ងន់ឬមានរបួសធ្ងន់ដែលវេជ្ជបណ្ឌិតបានហៅគ្រួសារអ្នកនោះមកប្រាប់ថា «ខ្ញុំបានព្យាយាមអស់ពីសមត្ថភាពហើយ អ្នកជំងឺបានដល់ចំណុចវិបត្តិធ្ងន់ធ្ងរហើយ។ អ្វីដែលកើតឡើងនៅពេលនេះគឺ ហួសពីសមត្ថភាពរបស់ខ្ញុំហើយ»។ អ្វីដែលវេជ្ជបណ្ឌិតមានប្រសាសន៍ នោះគឺមិនយូរប៉ុន្មានអ្នកជំងឺនោះនឹងឈឺកាន់តែធ្ងន់ ឬអាចឈានដល់ការបាត់បង់ជីវិត។

វិបត្តិតែងតែបង្កឲ្យមានការផ្លាស់ប្ដូរ ហើយការផ្លាស់ប្ដូរបែបនេះគឺពិបាកសំរាប់មនុស្សគ្រប់គ្នាដែលប្រឡូកជាមួយ។

## ***ដំណើរការនៃទុក្ខព្រួយប្រឆាំងនឹងវិញ្ញាណនៃទុក្ខព្រួយ***

ពាក្យទុក្ខព្រួយសំដៅលើ «ភាពតានតឹងក្នុងចិត្តយ៉ាងខ្លាំងចំពោះការបាត់បង់: ទុក្ខព្រួយ»។ សោកស្ដាយគឺ «មានអារម្មណ៍ទុក្ខព្រួយ» ការមានអារម្មណ៍តានតឹងក្នុងចិត្តខ្លាំង ពេញទៅដោយភាពសោកសៅ កាន់ទុក្ខ ការមានអារម្មណ៍ទុក្ខព្រួយ

*ដំណើរការ* នៃទុក្ខព្រួយគឺសំខាន់ហើយធ្វើឲ្យមានសុខភាពល្អ ទាំងផ្លូវចិត្តអារម្មណ៍និងសូម្បីតែផ្លូវកាយ។ មនុស្សដែលបដិសេធមិនព្រមទុក្ខព្រួយគឺជាញឹកញាប់មិនព្រមទទួលស្គាល់ការពិត ហើយនៅទីបញ្ចប់ទទួលរងការបំផ្លិចបំផ្លាញជីវិតរបស់គេទាំងស្រុង។

*វិញ្ញាណ* នៃទុក្ខព្រួយ គឺ ជាបញ្ហាផ្សេងមួយទៀតដោយឡែក។ បើមិនតតាំងនឹងវាទេ វានឹងសង្កត់សង្កិន ហើយបំផ្លាញជីវិតអស់អ្នកដែលទទួលរងការឈឺចាប់ដោយសារការបាត់បង់នោះ។ បើមិនបានប្រឈមមុខជាមួយវា ឬមិនបានគ្រប់គ្រងវាទេ វានឹងលួចសុខភាព កម្លាំង ភាពស្វាហាប់ និងជីវិតផងដែរ។

ខ្ញុំសូមឲ្យឧទាហរណ៍ដល់អ្នក!

មិត្តភ័ក្ររបស់ខ្ញុំបាត់បង់កូនប្រុសរបស់នាង នៅក្នុងសមរភូមិដ៏យូរដោយសារជំងឺរោគគោលិកាស។ ពេលកូនប្រុសនោះស្លាប់ ជាធម្មតាវាមានការពិបាកសម្រាប់មនុស្សគ្រប់គ្នានៅក្នុងគ្រួសារ។ ពួកគេពិតជាឆ្លងកាត់ដំណើរការនៃទុក្ខព្រួយ ព្រោះវាជាធម្មជាតិរបស់មនុស្ស។

តែមិត្តសម្លាញ់នេះបានមកជួបខ្ញុំដោយចៃដន្យ ដែលបានបញ្ចេញឲ្យខ្ញុំឃើញវិញ្ញាណនៃទុក្ខព្រួយ។ នាងបាននិយាយថា នៅថ្ងៃមួយ នាងបានបោកខោអាវ ហើយនាងចាប់ផ្ដើមគិតពីកូនប្រុសរបស់នាង រំពេចនោះនាងមានអារម្មណ៍ថាអាវ

ក្រៅបានរុំនៅជុំវិញខ្លួននាងជុំវិញ។ វាមានអារម្មណ៍ថា ស្រងូតស្រងាត់ និងទុក្ខព្រួយ ហើយនាងមានអារម្មណ៍ខ្លួនឯងថានាងស្ទើរតែ «លិចទៅក្នុង» ការនោះ។

ព្រះបានប្រទានឲ្យនាងបានដឹងថា វាជាវិញ្ញាណនៃទុក្ខព្រួយមកដាក់សម្ពាធលើនាង។ នាងបានចាប់យកអាវមួយរបស់កូនប្រុសនាង មករុំនៅជុំវិញខ្លួននាង។ ហើយប្រាប់ទៅវិញ្ញាណអាក្រក់ដែលនាងប្រើវាជា«សំលៀកបំពាក់នៃការសរសើរ»វិញ។ (អេសាយ៦:៣) បន្ទាប់មកនាងចាប់ផ្ដើមរាំហើយស្រែកសរសើរព្រះអម្ចាស់។ពេលនាងធ្វើបែបនោះនាងមានអារម្មណ៍ថាភាពតានតឹងបានចាកចេញពីនាង

ស្ត្រីម្នាក់នេះអាចបើកទ្វារសម្រាប់បញ្ហាធំដែលមានយូរមកហើយ ដែលនាងអត់បានប្រឈមមុខជាមួយវាដោយស្វាហាប់ ហើយអត់បានដោះស្រាយជាមួយនឹងការសង្កត់សង្កិនរបស់វិញ្ញាណនៃទុក្ខព្រួយនោះ។

## *ការសោកសៅប្រែជាអំណរសប្បាយ*

*មានពរហើយ អស់អ្នកដែលយំសោក ដ្បិតអ្នកទាំងនោះនឹងបានសេចក្ដីកំសាន្តចិត្ត!*

*ម៉ាថាយ៥:៤*

ព្រះគម្ពីរបានផ្ដល់បទគម្ពីរយោងមួយចំនួនចំពោះអស់អ្នកដែលទុក្ខព្រួយ។

នៅក្នុងយេរេមា៣១:១៣ ព្រះអម្ចាស់មានបន្ទូលតាមរយៈព្យាការីថា «ពេលនោះ ស្ត្រីក្រមុំនឹងនាំគ្នារាំយ៉ាងសប្បាយ ហើយពួកយុវជន និងពួកចាស់ទុំ ក៏នឹងរាំយ៉ាងសប្បាយដែរ។ យើងនឹងធ្វើឲ្យទុក្ខព្រួយរបស់ពួកគេ ប្រែទៅជាអំណររីករាយ យើងនឹងសំរាលទុក្ខពួកគេ ហើយធ្វើឲ្យពួកគេមានអំណរសប្បាយ ឡើងវិញ»។

នៅក្នុងបទគម្ពីរនេះយើងឃើញថា វាជាព្រះឫទ័យព្រះក្នុងការសំរាលទុក្ខអ្នកដែលទុក្ខព្រួយ ហេតុដូច្នេះហើយ យើងអាចដឹងជាក់ថា ការសំរាលទុក្ខអាចនឹង

មកដល់បន្ទាប់ពីទុក្ខសោក។ បើសិនជាអត់មានការសំរាលទុក្ខទេ ដូច្នេះមានអ្វីដែលមិនត្រឹមត្រូវហើយ។

នៅក្នុងអេសាយ៦១:១-៣ យើងអានព្រះបន្ទូលសន្យាទាំងអស់នេះ:

ព្រះវិញ្ញាណរបស់ព្រះជាអម្ចាស់ សណ្ឋិតលើខ្ញុំ ដ្បិតព្រះអម្ចាស់បានចាក់ប្រេងអភិសេកខ្ញុំ ឲ្យនាំដំណឹងល្អទៅប្រាប់អ្នកដែលត្រូវគេជិះជាន់ ជួយថែទាំអ្នកដែលបាក់ទឹកចិត្ត ប្រកាសប្រាប់ជនជាប់ជាឈ្លើយថា ពួកគេនឹងរួចខ្លួន(ទាំងខាងរូបកាយនិងព្រលឹងវិញ្ញាណ) ហើយប្រាប់អ្នកជាប់ឃុំឃាំងថា ពួកគេនឹងមានសេរីភាព។

ព្រមទាំងប្រកាសពីឆ្នាំដែលព្រះអម្ចាស់សំដែង (ព្រះហឫទ័យមេត្តាករុណា) និងពីថ្ងៃកំណត់ដែលព្រះរបស់យើង ដាក់ទោសមនុស្សអាក្រក់ ហើយសំរាលទុក្ខអស់អ្នកដែលកាន់ទុក្ខ។

គឺឲ្យអ្នកក្រុងស៊ីយ៉ូនដែលកាន់ទុក្ខនោះ ទទួលមកុដនៅលើក្បាលជំនួសផេះ ឲ្យគេលាបប្រេងសំដែងអំណរសប្បាយ ជំនួសភាពក្រៀមក្រំនៃការកាន់ទុក្ខ ឲ្យគេស្លៀកពាក់យ៉ាងថ្លៃថ្នូរ ជំនួសខោអាវដាច់ដាច(ការល្ហួងលោមចិត្តនិងអំណរ) ។ ពេលនោះ គេនឹងប្រដូចអ្នកក្រុងយេរូសាឡឹម ទៅនឹងដើមឈើសក្ការៈនៃព្រះដ៏សុចរិត ជាសួនឧទ្យានរបស់ព្រះអម្ចាស់ ដើម្បីបង្ហាញភាពថ្កុំថ្កើងរបស់ព្រះអង្គ។

វាច្បាស់ណាស់ពីគោលការណ៍ ដែលយើងបានឃើញអំពីការរៀបចំនៅក្នុងបទគម្ពីរនេះ ទ្រង់គឺជាអ្នកដែលស្តារឡើងវិញទាំងស្រុង។ ព្រះអង្គគាប់ព្រះហឫទ័យពិសេសដល់អស់អ្នកដែលឈឺចាប់ហើយស្វែងរកការស្តារអំណាររបស់ពួកគេឡើងវិញ។

អ្នកអាចសោកស្តាយនូវអ្វីដែលបានបាត់បង់ តែអ្នកមិនត្រូវស្ថិតនៅក្នុងស្ថានភាពបែបនោះអស់មួយជីវិតរបស់អ្នកទេ។ ព្រះអង្គបានសន្យាថានឹងប្រែទុក្ខព្រួយ

របស់អ្នកជាអំណោយរីករាយវិញ។ អ្នកត្រូវកាន់ខ្ជាប់ចំពោះសេចក្តីសន្យានោះ នៅពេលដែលអ្នកកំពុងស្ថិតក្នុងដំណើរការនៃទុក្ខព្រួយនោះ។ ធ្វើដូច្នេះ អ្នកនឹងមានក្តីសង្ឃឹមសម្រាប់អនាគត។

### *ក្តីសង្ឃឹមដាក់នៅចំពោះមុខយើង*

*ការអស់សង្ឃឹមតែងតែនាំឲ្យព្រួយចិត្ត រីឯការសម្រេចដូចបំណង ប្រៀបបាននឹងដើមឈើដែលមានជីវិត។*

*សុភាសិត ១៣:១២*

នៅពេលមានទុក្ខព្រួយចំពោះការបាត់បង់ ជារឿយៗគឺជាការសំខាន់ហើយអាចធ្វើឲ្យមានភាពធម្មតាវិញ ចូរប្រយ័ត្នមិនត្រូវឲ្យធ្លាក់ទៅក្នុងការបាក់ទឹកចិត្តនិងភាពអស់សង្ឃឹម ដែលជាបន្ទុកធ្ងន់ពិបាកក្នុងការទ្រាំទ្រ។

ផ្ទុយពីការបណ្តោយឲ្យធ្លាក់ទៅក្នុងភាពអស់សង្ឃឹម សូមយកចិត្តទុកដាក់ជាមួយពាក្យរបស់ដាវីឌនៅក្នុងទំនុកតម្កើង ២៧:១៣,១៤:

*ឱព្រះអម្ចាស់អើយ សូមតើនឡើង សូមយាងទៅប្រឈមមុខនឹងពួកគេ ឲ្យពួកគេបរាជ័យ! សូមយកព្រះខ័នរបស់ព្រះអង្គមករំដោះ ទូលបង្គំឲ្យរួចពីកណ្តាប់ដៃរបស់ជនពាល។*

*ឱព្រះអម្ចាស់អើយ សូមដេញពួកគេចេញពីចំណោម មនុស្សលោកដោយឫទ្ធិបារមីរបស់ព្រះអង្គ សូមដាក់ទោសពួកគេ ឲ្យជីវិតពួកគេ រងទុក្ខវេទនាយ៉ាងខ្លាំង តាំងពីកូនរហូតដល់ចៅ។*

មិនថាមានរឿងអ្វីកើតឡើងនៅលើលោកីយ៍នេះទេ ត្រូវតែមានសង្ឃឹមក្នុងព្រះអង្គជានិច្ច។

នៅក្នុងហេព្រើ ៦:១៧ ព្រះគម្ពីរបានថ្លែងថា ព្រះអង្គបានសន្យាជាមួយយើងស្របតាមព្រះបំណងរបស់ព្រះអង្គថានឹងព្រះទានពរដល់យើងដោយការគាំទ្រព្រះ

បន្ទូលសន្យារបស់ព្រះអង្គជាមួយនឹងពាក្យសម្បថ «...ព្រះជាម្ចាស់ក៏សព្វព្រះហឫទ័យបង្ហាញឲ្យអស់អ្នក ដែលទទួលមត៌កតាមព្រះបន្ទូលសន្យា បានដឹងរឹតតែច្បាស់ថា បើព្រះអង្គសម្រេចព្រះហឫទ័យយ៉ាងណាហើយនោះ ទ្រង់មិនប្រែប្រួលទេ។ ហេតុនេះ ព្រះអង្គមានព្រះបន្ទូលស្បថថែមលើព្រះបន្ទូលសន្យាទៀត។ ចំពោះយើងដែលបានលះបង់អ្វីៗទាំងអស់ ដើម្បីឈោងចាប់យកសេចក្តីសង្ឃឹមដែលព្រះអង្គដាក់នៅខាងមុខយើង ព្រះអង្គក៏បានលើកទឹកចិត្តយើងយ៉ាងខ្លាំងដោយមានព្រះបន្ទូលទាំងពីរយ៉ាងដែលពុំចេះប្រែប្រួល ហើយព្រះជាម្ចាស់មិនចេះកុហក ក្នុងព្រះបន្ទូលនេះឡើយ។» (ខ១៨)

នៅក្នុងខ១៩បានបន្តទៀតថា «(ពេលនេះ)យើងមាន(សេចក្តីសង្ឃឹម)នេះប្រៀបបីដូចជាយុថ្កាមួយដ៏ជាប់មាំមួន (មិនអាចរអិលហើយវាមិនអាចបាក់បែកទោះបីជាមានអ្នកជាន់ពីលើវាក្តី ជាក្តីសង្ឃឹម) សម្រាប់ព្រលឹងរបស់យើង ហើយក៏បានចូលហួសវាំងននទៅក្នុងទីសក្ការៈ(នៅក្នុងវត្តមានរបស់ព្រះ)ថែមទៀតផង។

យុថ្ការបស់កប៉ាល់ការពារកប៉ាល់កុំឲ្យអណ្តែតទៅឆ្ងាយពេលមានព្យុះ។ សេចក្តីសង្ឃឹមធ្វើការដូចគ្នាសម្រាប់ព្រលឹងរបស់យើង។ សេចក្តីសង្ឃឹមប្រៀបបានយុថ្កាដែលការពារយើងឲ្យនៅតែដំណើរការ នៅពេលដែលយើងឃ្លេងឃ្លោងទៅនេះទៅនោះដោយសារព្យុះជីវិត។

អ្នកអាចមិនយល់ច្រើនប៉ុន្មានពេលអ្នកទទួលរងទុក្ខលំបាក និងការឈឺចាប់ដោយសារការបាត់បង់ ដែលកំពុងហែកហួរដល់ព្រលឹងរបស់អ្នក តែត្រូវដឹងហើយកាន់ខ្ជាប់ជាមួយសេចក្តីពិតមួយនេះគឺៈ ព្រះស្រឡាញ់អ្នក ទ្រង់រៀបចំអនាគតល្អសម្រាប់អ្នក។ ចូរមានសង្ឃឹមក្នុងព្រះអង្គ ហើយទុកចិត្តដល់ព្រះអង្គ ទ្រង់នឹងប្រែការសោកសៅរបស់អ្នកទៅជាអំណររីករាយវិញ ហើយប្រទានដល់អ្នកនូវភាពស្រស់ស្អាតជំនួសផេះ ទោះបីជាអ្នកឆ្លងកាត់ដំណាក់ការសោកសៅផ្សេងៗក្តី។

# ៣

# ប្រាំពីរដំណាក់កាលនៃភាពសោកសៅ

*ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ។*

*ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ នោះទ្រង់នឹងដំរង់អស់ទាំងផ្លូវច្រករបស់ឯង។*

*សុភាសិត ៣:៥,៦*

# ប្រាំពីរដំណាក់កាលនៃភាពសោកសៅ

បន្ទាប់ពីមានបទពិសោធន៍ជាមួយសោកនាដកម្ម ឬការបាត់បង់ ភាគច្រើនយើងឆ្លងកាត់ដំណើរការនៃទុក្ខព្រួយមួយចំនួន។ជាទូទៅមានប្រាំពីរដំណាក់កាលសំខាន់ៗ ឬទិដ្ឋភាពនៃដំណើរការនេះ។ សូមមើលការទាំងនេះមួយម្តងៗ ដើម្បីឲ្យអាចយល់ពីអ្វីដែលបានកើតឡើងចំពោះយើងនៅក្នុងដំណើរការនេះ ហើយអ្វីដែលយើងអាចធ្វើដើម្បីយកចំណេញពីការនោះ។

***ដំណាក់កាលទី១: ការតក់ស្លុតនិងការបដិសេធន៍***

ការទាំងនេះជាធម្មតាគឺជាការដំបូង ដែលជួបប្រទះនៅពេលមានសោកនាដកម្ម ឬការបាត់បង់កើតឡើង។ ព្រះអង្គប្រើការទាំងនោះដើម្បីការពារនិងប្រឆាំងជាមួយកាបំផ្លិចបំផ្លាញ។

***ការតក់ស្លុត:***

ការតក់ស្លុតគឺជាអ្វីមួយដែលជាការប៉ះពាល់នៃគំនិត ឬជាអារម្មណ៍ហឹង្សា ជាកំហឹងដែលមិនបានរំពឹងទុក។

ការតក់ស្លុតតាមពិតជាប្រព័ន្ធការពារខាងក្នុង។វាផ្តល់ពេលដល់យើងឲ្យយើងស្តប់ចិត្តចំពោះអ្វីដែលបានផ្លាស់ប្តូរ។ វាការពារយើងពីការប្រឈមជាមួយនឹងគ្រប់ទាំងការពិតនៅក្នុងពេលតែមួយ។

មុនពេលយើងបន្តទៅមុខទៀតយើងត្រូវតែរៀបចំផ្នត់គំនិតជាថ្មី។ ការតក់ស្លុតផ្តល់ពេលឲ្យយើងដើម្បីអភិវឌ្ឍន៍ការគិតរបៀបថ្មីអំពីជីវិតនិងអនាគតរបស់យើង។

ដើម្បីងាយយល់ ចូរពិចារណាអំពីម៉ាស៊ីនស័រថយន្ត។ ពួកគេបានរចនាដើម្បីកាត់

បន្ថយរថយន្តពីការប៉ះទង្គិចដោយអចេតនានៅតាមផ្លូវ។ បើគ្មានវាទេ វាអាចនឹងធ្វើឲ្យបែកខ្ទេចខ្ទីដោយសារវាប៉ះទង្គិចចុះឡើង ពេលធ្វើដំណើរ។

ជាញឹកញាប់យើងក៏ដូចគ្នាដែរ។ យើងកំពុងធ្វើដំណើរតាមផ្លូវនៃជីវិត ហើយភាគច្រើនយើងអត់បានរំពឹងថាត្រូវប៉ះទង្គិចហើយជល់នឹងថ្ម។ ហេតុដូច្នេះហើយយើងអត់រួចរាល់ជាមួយនឹងវា នៅពេលដែលយើងបានជួបវាភ្លាមៗ។ ព្រះវិញ្ញាណដ៏វិសុទ្ធបានដាក់ «ម៉ាំរីស័» ការពារពេលមានការប៉ះទង្គិច រហូតទាល់តែយើងអាចកែសម្រួលឡើងវិញ និងកែសម្រួលឲ្យសមស្របចំពោះការគិតរបស់យើងទៅនឹងការបត់បែននៅពេលកំពុងបើកបរ។

ដំណាក់កាល នៃការតក់ស្លុតអាចបាត់ទៅវិញ បន្ទាប់ពីពីរបីនាទីទៅពីរបីសប្តាហ៍។ តែបើសិនជាបន្តឲ្យវាលើសពីនេះ មានរឿងអ្វីមិនប្រក្រតីហើយ។

ការតក់ស្លុតធម្មតា ដូចជាការបាត់បង់ស្មារតីមួយភ្លែត ប៉ុន្តែយើងមិនត្រូវនៅក្នុងការបាត់បង់ស្មារតីរហូតទេ។ យើងត្រូវបន្តទៅមុខទៀត។ ការតក់ស្លុតគឺការគេចវេសពីការពិតបណ្តោះអាសន្ន តែបើមិនមែនបណ្តោះអាសន្នទេ វាអាចនាំឲ្យមានបញ្ហាកាន់តែខ្លាំង។

ខ្ញុំសូមរំលឹកកាលពីខ្ញុំនៅជាមួយម្តាយមីងរបស់ខ្ញុំ ពេលឪពុកធំរបស់ខ្ញុំបានស្លាប់ទៅ។ គាត់ឈឺអស់ពេលមួយរយៈ ទោះបីជាយ៉ាងនោះក្តី វាមិនអាចជៀសរួចពីសេចក្តីស្លាប់ទេ ម្តាយមីងរបស់ខ្ញុំនៅតែបន្តនិយាយម្តងហើយម្តងទៀត «ខ្ញុំមិនជឿថាវាអាចកើតឡើងបានទេ ខ្ញុំមិនជឿថាគាត់ស្លាប់ទេ»។ នាងកំពុងតែស្ថិតក្នុងការចាប់ផ្តើមនៃការតក់ស្លុត ដែលជាញឹកញាប់វាមកដល់នៅពេលសោកនាដកម្មនៃការបាត់បង់។

ពេលមនុស្សឆ្លងកាត់ការតក់ស្លុត ការល្អបំផុតមិនត្រូវអសកម្មយូរពេកទេ។ ស្ត្រីម្នាក់ជាបុគ្គលិករបស់ខ្ញុំមានបទពិសោធន៍ជាមួយការនេះ វិបត្តនៃការបំផ្លិចបំផ្លាញ។ ខ្ញុំចាំបានថា នាងបាននិយាយថា «ព្រះអង្គប្រាប់ខ្ញុំថាឲ្យបន្តទៅមុខទៀត

ដូច្នេះខ្ញុំត្រូវតែមកធ្វើការ»។

នាងបានចែកចាយ តែនាងអត់ដឹងច្បាស់ពីគុណភាពការងាររបស់នាងនឹងទៅជាយ៉ាងណា តែនាងដឹងថា វាប្រកបដោយ មហន្តរាយសម្រាប់នាង បើសិនជានាងអនុញ្ញាតការមិនខ្វល់ដែលកំពុងតែមករកនាងហើយគ្រប់គ្រង និងទាញគាត់ឲ្យធ្លាក់ចុះ។ នៅថ្ងៃមួយនាងបានបាត់បង់អ្វីដែលនាងគិតថាអ្វីៗគ្រប់យ៉ាងសំខាន់ចំពោះជីវិតរបស់នាង។ អារម្មណ៍ទូទៅរបស់នាងគឺ «តើអ្វីដែលត្រូវប្រើ? ហេតុអ្វីបានព្យាយាមធ្វើអ្វីៗគ្រប់យ៉ាង?» នាងដឹងថា បើសិនជានាងអាចរស់បាន នាងត្រូវតែតទល់នឹងអារម្មណ៍ទាំងនោះជាមួយនឹងសកម្មភាពវិជ្ជមាន។

ពេលដែលអ្នកឆ្លងកាត់ការតក់ស្លុតដោយសារសោកនាដកម្ម នៃការបាត់បង់ក្នុងមានជាអ្នកជឿអ្នកត្រូវដឹងការបែងចែករវាងព្រលឹងនិងវិញ្ញាណ។ ទោះបីជានៅពេលមានសោតនាដកម្ម ឬបាត់បង់ អ្នកត្រូវតែសង្កេតមើលឲ្យឃើញពីភាពខុសគ្នារវាងអារម្មណ៍របស់មនុស្ស និង ការដឹកនាំដ៏ពិតពីព្រះវិញ្ញាណដ៏វិសុទ្ធ។

***ការបដិសេធន៍:***

ការបដិសេធន៍ការមិនទទួលស្គាល់ មិនព្រមប្រឈមមុខនឹងការពិតដែល ជាញឹកញាប់កើតឡើងដោយសារអារម្មណ៍និងជំងឺផ្លូវចិត្តក្នុងការខ្វែងគំនិតគ្នាផ្សេងៗ

ព្រះបានពង្រឹងយើងជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីឲ្យយើងមានអំណាចក្នុងការប្រឈមមុខជាមួយនឹងការពិតដោយកាន់ព្រះហស្តព្រះអង្គ ក្នុងការដើរឆ្លងកាត់ជ្រលងនៃភពងងឹត ដើម្បីយកឈ្នះគ្រប់ទាំងឧបសគ្គដែលមាននៅក្នុងជីវិត។

ជាមួយនឹងវិញ្ញាណរបស់ព្រះដែលគង់នៅក្នុងយើង ហើយទតមកលើយើង យើងអាចនិយាយជាមួយស្តេចដាវីឌថា «ទោះបីទូលបង្គំដើរកាត់ជ្រលងភ្នំ(ជ្រៅ ឬងងិតសូន្យសុង)នៃសេចក្តីស្លាប់ ក៏ដោយ ក៏ទូលបង្គំមិនខ្លាចអ្វីសោះឡើយ ដ្បិតព្រះអង្គគង់នៅជាមួយទូលបង្គំ ព្រះអង្គ(ការពារ)និងរក្សា(ដឹកនាំ)ទូលបង្គំជានិច្ច។

(ទំនុកតម្កើង២៣:៤)។

ទោះបីជាដើរកាត់ជ្រលងភ្នំនៃសេចក្ដីស្លាប់នៅក្នុងជីវិតរបស់យើងក្ដីយើងអាចរស់នៅជាមួយសេចក្ដីសង្ឃឹម។

ក្នុងការនិយាយពីសេចក្ដីសង្ឃឹម សូមគិតម្ដងទៀតពីលោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌ-នេកោ ដែលនៅក្នុងភ្លើងដ៏សន្ធោសន្ធៅ(ដានីអ៊ែល៣:៨-២៧)។ ទោះបីជាពួកគេមានបទពិសោធន៍ក្នុងការបោះចូលទៅក្នុងឡដែលមានកំដៅក្ដៅខ្លាំង ជាងធម្មតាដល់ទៅប្រាំពីរដង ដែលមិនធ្លាប់មានពីមុនមកក្ដី ព្រះអម្ចាស់ គង់នៅជាមួយនឹងពួកគេនៅក្នុងភ្លើងនរកដែលឆេះសន្ធោសន្ធៅនោះ។

យើងអាចមើលទៅបទគម្ពីរដែលនៅខាងលើនេះ ដើម្បីលើកទឹកចិត្តខ្លួនយើងនៅពេលណាដែលយើងឃើញថាខ្លួនយើងនៅក្នុងកន្លែងបែបនោះ។ ដូចដែលព្រះបានធ្វើជាមួយកូនចៅហេព្រឺ ដែលនៅក្នុងភ្លើងដែលឆេះសន្ធោសន្ធៅ ដូច្នេះហើយពួកគេអាចចេញរួចពីការរងេ្វងហើយអត់មានរបួសអ្វីដល់ពួកគេសោះ ដូច្នេះ ព្រះអង្គគង់ជាមួយពួកគេមិនថាពួកគេស្ថិតក្នុងស្ថានភាពបែបណា ដែលពួកគេបានជួបនៅក្នុងជីវិតនោះទ្បើយ។

វាជាព្រះហឫទ័យរបស់ព្រះសម្រាប់យើងក្នុងការឲ្យយើងប្រឈមមុខនឹងសេចក្ដីពិត ដើម្បីឆ្លងកាត់ហើយអាចចេញរួចដោយជ័យជំនះនៅគ្រប់ទាំងផ្លូវ។ ការប្រឈមមុខនិងការពិតគឺជារឿងពិបាក តែការដែលរត់ចេញពីការពិតនោះពិបាកជាង

## *ដំណាក់កាលទីពីរ: កំហឹង*

ដំណាក់កាលទីពីរ គឺងាយចំណាំដោយសារកំហឹង: ខឹងជាមួយនឹងព្រះ ខឹងជាមួយមារ ខឹងជាមួយខ្លួនឯង និងខឹងជាមួយមនុស្សដែលធ្វើឲ្យឈឺចាប់និងបាត់បង់ ទោះបីជាអ្នកនោះស្លាប់ហើយក្ដី។

### *ខឹងជាមួយព្រះ:*

យើងជឿថាព្រះអង្គជាព្រះដ៏ល្អ ទ្រង់ជាអ្នកដែលគ្រប់គ្រងជីវិតរបស់យើង។ ហេតុដូច្នេះហើយ ពេលសោកនាដកម្មប៉ះទង្គិច ឬការបាត់បង់កើតឡើង យើងអត់ដឹងថាហេតុអ្វីបានជាព្រះអត់ការពារ ការទាំងនោះកុំឲ្យកើតឡើងចំពោះយើង ហើយធ្វើឲ្យយើងឈឺចាប់យ៉ាងខ្លាំង។

ការប្រឈមមុខជាមួយការបាត់បង់ដែលគួរឲ្យសោកស្តាយ ជាញឹកញាប់យើងបានខឹងហើយសួរថា «បើព្រះអង្គល្អ ហើយពេញដោយព្រះចេស្តាមែន ហេតុអ្វីបានជាព្រះអង្គបណ្តោយឲ្យការអាក្រក់កើតឡើងចំពោះមនុស្សល្អដូច្នេះ?» ការនេះបានក្លាយជាបញ្ហាដ៏ធំនៅពេលយើងជួបខ្លួនឯង បុត្រធីតារបស់ព្រះអង្គផ្ទាល់ តើអ្នកណាគឺជាអ្នកដែលឈឺចាប់។

នៅក្នុងពេលបែបនេះ ហេតុផលដែលចង់ស្រែកចេញមកក្រៅ «*ការនេះវាអត់មានន័យទាល់តែសោះ*» សំណួរសួរដដែលៗថា «ហេតុអ្វី ព្រះអង្គហេតុអ្វី?» ធ្វើទុក្ខដល់អស់អ្នកដែលទុក្ខព្រួយចំពោះការបាត់បង់នៅក្នុងជីវិតរបស់ពួកគេ ដូចដែល វាបានធ្វើទុក្ខដល់អ្នកដែលឯកានិងអ្នកដែលត្រូវគេបដិសេធ។

នៅក្នុង១កូរិនថូស១៣:១២ លោកប៉ុលបានបង្ហាញឲ្យឃើញថានឹងមានសំណួរខ្លះអត់មានចម្លើយដើម្បីដោះស្រាយបាននៅក្នុងជីវិតៈ

> *សព្វថ្ងៃនេះយើងស្គាល់ព្រះជាម្ចាស់មិនច្បាស់ទេ(ស្រពិចស្រពិល) គឺស្គាល់ព្រាលៗ(មិនច្បាស់ដូចពាក្យបណ្តៅ ឬ ប្រស្នា) ដូចជាមើលក្នុងកញ្ចក់ នៅពេលខាងមុខ(ពេលល្អឥតខ្ចោះមកដល់) ទើបយើងឃើញព្រះអង្គទល់មុខគ្នា។ សព្វថ្ងៃ ខ្ញុំស្គាល់ព្រះអង្គបានត្រឹមតែមួយផ្នែកប៉ុណ្ណោះ(មិនទាន់ល្អឥតខ្ចោះនៅឡើយ) ពេលខាងមុខទើបខ្ញុំស្គាល់ព្រះអង្គច្បាស់ ដូចព្រះអង្គស្គាល់ខ្ញុំយ៉ាងច្បាស់ដែរ។*

ហេតុផលហួសប្រមាណ ដែលព្យាយាមក្នុងការស្វែងរកអ្វីមួយដែលយើងអត់អាចរកចម្លើយបាន ការឈឺចាប់នឹងនាំឲ្យមានការភាន់ច្រឡំ តែនៅក្នុងសុភាសិត

៣:៥-៦បានប្រាប់យើងថាការទុកចិត្តព្រះនាំមកនូវការធានារ៉ាប់រងនិងការណែនាំៈ

*កុំពឹងលើការចេះដឹងរបស់ខ្លួនឡើយ តែត្រូវទុកចិត្តលើព្រះអម្ចាស់ទាំងស្រុង។*

*ចូរនឹកដល់ព្រះអម្ចាស់ក្នុងគ្រប់កិច្ចការដែលកូនធ្វើ នោះព្រះអង្គនឹងត្រួសត្រាយផ្លូវរបស់កូន។*

យើងជួបជាមួយវិបត្តិនៅក្នុងជីវិត យើងត្រូវការការណែនាំ។ បទគម្ពីរនេះប្រាប់យើងថា ការទុកចិត្តព្រះជាវិធីដើម្បីស្វែងរកទិសដៅនោះ។

*ការទុកចិត្ត ទាមទាអនុញ្ញាតឲ្យសំណួរដែលគ្មានចម្លើយខ្លះមាននៅក្នុងជីវិតរបស់អ្នក!*

ការពិតនេះពិបាកសម្រាប់យើងក្នុងការដោះស្រាយព្រោះនិស្ស័យរបស់មនុស្សចង់យល់អ្វីៗគ្រប់យ៉ាង។ នៅក្នុងរ៉ូម៨:៦បានប្រាប់យើងថា «ការគិតខាងលោកីយ៍នាំឲ្យស្លាប់ រីឯការគិតខាងព្រះវិញ្ញាណនាំឲ្យមានជីវិត...»។

យើងចង់ឲ្យអ្វីមួយមានន័យសមហេតុសមផល តែព្រះវិញ្ញាណដ៏វិសុទ្ធអាចធ្វើឲ្យយើងមានសន្តិភាពក្នុងចិត្ត របស់យើងចំពោះអ្វី ដែលឥតសមហេតុសមផលទាល់តែសោះចំពោះគ្រប់ទាំងគំនិតខាងលោកីយ៍របស់អ្នក។

មិនថាអ្នកទទួលរងការឈឺចាប់ខ្លាំងប៉ុណ្ណាក្តីពីការបាត់បង់ឬ សោកនាដកម្មក្តី ព្រះវិញ្ញាណដ៏វិសុទ្ធអាចប្រទានដល់អ្នកនូវសេចក្តីសុខសាន្តពេញលេញដែលពេលខ្លះគ្រប់យ៉ាងនឹងបានត្រឹមត្រូវឡើងវិញ។

ការខឹងជាមួយនឹងព្រះគឺអត់ប្រយោជន៍ទេ ព្រោះមានតែទ្រង់ទេ ដែលអាចជួយអ្នកបាន។ មានតែព្រះអង្គតែមួយគត់ដែលអាចនាំការលួងលោមចិត្តបានយូរហើយប្រោសឲ្យជានូវអ្វីដែលយើងត្រូវការ។ ខ្ញុំសូមលើកទឹកចិត្តដល់អ្នកឲ្យបន្តជឿថា ព្រះអង្គល្អ ហើយដឹងថាអ្វីដែលកើតឡើង មិនអាចផ្លាស់ប្តូរការពិតបាននោះ

បានទេ។ ទោះបីជាអ្នកអត់យល់ពីស្ថានភាពរបស់អ្នកក្តី ចូរបន្តជឿហើយនិយាយថា ព្រះអង្គល្អ ព្រោះទ្រង់ល្អមែន!

នៅក្នុងទំនុកតម្កើង៣៤:៨ អ្នកនិពន្ធទំនុកតម្កើងបានលើកទឹកចិត្តយើងថា « ចូរពិសោធមើលដោយខ្លួនឯងចុះ ដើម្បីឲ្យដឹងថា ព្រះអម្ចាស់(ព្រះអម្ចាស់របស់យើង) មានព្រះហឫទ័យសប្បុរសដ៏លើសលប់! អ្នកណាពឹងផ្អែកលើព្រះអង្គ អ្នកនោះមានសុភមង្គល(មានពរ សំណាង គួរច្រណែន)ហើយ!»។

ហើយនៅក្នុងទំនុកតម្កើង៨៦:៥ បានថ្លែងពីព្រះអង្គថា «ឱព្រះអម្ចាស់អើយ មានតែព្រះអង្គទេ ដែលប្រកបដោយព្រះហឫទ័យសប្បុរស និងចេះអត់អោនឲ្យយើងខ្ញុំ(កំហុសរបស់យើង បោះបង់វាចោល ឲ្យវាចេញផុតពីយើងទាំងស្រុងនិងរហូតទៅ) ព្រះអង្គមានព្រះហឫទ័យមេត្តាករុណាដ៏លើសលប់ ចំពោះអស់អ្នកដែលអង្វររកព្រះអង្គ»។

ចុងក្រោយ នៅក្នុងទំនុកតម្កើង១៣៦:១ បានប្រាប់យើងថា «ចូរលើកតម្កើងព្រះអម្ចាស់ ដ្បិតព្រះអង្គមានព្រះហឫទ័យសប្បុរស ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេរហូតទៅ!»។

ព្រះអង្គល្អ តែមារចង់ឲ្យយើងជឿថា យើងមិនត្រូវទុកចិត្តព្រះទេ ហើយជឿថា ព្រះអង្គមិនយកព្រះហឫទ័យទុកដាក់នឹងយើងទេ។ បើអ្នកមានការសង្ស័យចំពោះក្តីស្រឡាញ់របស់ព្រះសម្រាប់អ្នក ព្រះអង្គស្មោះត្រង់ជាមួយនឹងការយកព្រះហឫទ័យទុកដាក់ចំពោះអ្នក សូមពិចារណាពាក្យរបស់លោកសាវកប៉ូលចំពោះប្រធានបទនេះ*ដែលបានសរសេរនៅក្នុងរ៉ូម ៨:៣៥-៣៩:*

> *តើនរណាអាច បំបែកយើងចេញពីព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រិស្តបាន? ទុក្ខវេទនា ឬការតប់ប្រមល់ អន្ទះអន្ទែង ការបៀតបៀន ការស្រេកឃ្លាន ខ្វះសម្លៀកបំពាក់ គ្រោះថ្នាក់ ឬមួយត្រូវគេសម្លាប់?*
> *ដូចមានចែងទុកមកថា:ព្រោះតែព្រះអង្គ យើងត្រូវគេរកសម្លាប់ពីព្រឹក*

*ដល់ល្ងាច គេចាត់ទុកយើងដូចជាចៀមដែលត្រូវគេ យកទៅសម្លាប់។*

*ក៏ប៉ុន្តែ ក្នុងការទាំងនោះ យើងមានជ័យជំនះលើសពីអ្នកមានជ័យជំនះទៅទៀត ដោយព្រះអម្ចាស់ដែលបានស្រឡាញ់យើង។*

*ខ្ញុំជឿជាក់(ដឹងច្បាស់)ថា ទោះបីសេចក្ដីស្លាប់ក្ដី ជីវិតក្ដី ទេវតាក្ដី វត្ថុស័ក្ដិសិទ្ធិនានាក្ដី បច្ចុប្បន្នកាលក្ដី អនាគតកាលក្ដី អំណាចនានាក្ដី*

*អ្វីៗដែលនៅស្ថានលើក្ដី នៅស្ថានក្រោមក្ដី ឬអ្វីៗផ្សេងទៀតដែលព្រះជាម្ចាស់បង្កើតមកក្ដី ក៏ពុំអាចបំបែកយើងចេញពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ដែលទ្រង់ បានសំដែងឲ្យយើងឃើញ ក្នុងព្រះគ្រិស្តយេស៊ូ ជាអម្ចាស់នៃយើងបានឡើយ។*

កុំខឹងជាមួយព្រះធ្វើអ្វី។ ចូរទទួលអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ សូមស្ដាប់ព្រះបន្ទូលរបស់ព្រះយេស៊ូនៅក្នុងបទគម្ពីរនេះ:

*«កុំរន្ធត់ចិត្តធ្វើអ្វី(កុំខ្វល់ខ្វាយ ព្រួយចិត្តឡើយ) អ្នករាល់គ្នាជឿលើព្រះជាម្ចាស់ហើយ សុំជឿលើខ្ញុំផង។*

*ខ្ញុំនឹងទូលអង្វរព្រះបិតា ហើយទ្រង់ប្រទានព្រះដ៏ជួយការពារមួយអង្គទៀតជា(អ្នកលួងលោមចិត្ត អ្នកជំនួយ អ្នកទូលអង្វរ អ្នកគាំទ្រ អ្នកផ្ដល់កម្លាំង និង ជាអ្នកជំនួយពេលអ្នកត្រូវការ) ឲ្យគង់នៅជាមួយអ្នករាល់គ្នាជាដរាបតរៀងទៅ។*

*ខ្ញុំមិនចោលអ្នករាល់គ្នាឲ្យនៅកំព្រាឡើយ(គ្មានភាពកក់ក្ដៅ បោះបង់ចោល នៅឯកា កំសត់ អត់មានជំនួយ) ខ្ញុំនឹងមករកអ្នករាល់គ្នាវិញ។*

*យ៉ូហាន១៤:១,៦,១៨*

ចូរទទួលការកំសាន្តចិត្តពីព្រះបន្ទូលទាំងនេះ ហើយតទល់នឹងមារដែលព្យាយាមធ្វើការក្នុងអ្នកដើម្បីយកកំហឹងចេញពីអ្នកហើយនិងការខកចិត្ត ចំពោះព្រះ

ចេញមក។

## ***ខឹងជាមួយនឹងអារក្ស***

ព្រះគម្ពីរថ្លែងថា យើងត្រូវតែស្អប់ការអាក្រក់ (អេម៉ុស៥:១៥) អារក្សគឺជាប្រភព នៃការអាក្រក់គ្រប់យ៉ាង ហើយការខឹងជាមួយនឹងអារក្សគឺត្រឹមត្រូវ។ បើសិនជា កំហឹងនោះបង្ហាញស្របតាមគំរូរបស់ព្រះគម្ពីរ។

នៅក្នុងអេភេសូ៦:១២ បានប្រាប់យើងថា «ដ្បិតយើងមិនមែនតយុទ្ធ ទល់នឹង មនុស្សទេ គឺតយុទ្ធទល់នឹងវត្ថុស័ក្តិសិទ្ធិ ទល់នឹងអ្វីៗដែលមានអំណាច ទល់នឹង មេត្រួតត្រាក្នុងលោកីយ៍ដ៏ងងឹតនេះ ហើយតយុទ្ធទល់នឹងឥទ្ធិពលអរូបដ៏អាក្រក់ ទាំងឡាយដែលនៅស្ថានលើដែរ»។ នៅក្នុងគម្ពីរបកប្រែ Amplified បានប្រាប់ថា យើងធ្វើសង្គ្រាមប្រឆាំងនឹង មេត្រួតត្រារបស់លោកីយ៍ដ៏ងងិតបច្ចុប្បន្ននេះ យើង ប្រឆាំងជាមួយឥទ្ធិពលនៃវិញ្ញាណអាក្រក់...»

សង្គ្រាមរបស់យើងពិតជាមិនមែនតយុទ្ធជាមួយព្រះ ឬជាមួយនឹងមនុស្សទេ តែតយុទ្ធជាមួយសត្រូវនៃព្រលឹងរបស់យើង។តើយើងអាចខឹងនឹងវិញ្ញាណអាក្រក់ យ៉ាងដូចម្តេចដើម្បីឲ្យសំដែងដោយមានឥទ្ធិពល? សូមឲ្យខ្ញុំផ្តល់ឧទាហរណ៍នៅក្នុង ជីវិតរបស់ខ្ញុំផ្ទាល់។

អស់ពេលជាច្រើនឆ្នាំកន្លងមកហើយ ខ្ញុំខឹងជាមួយនឹងសាតាំងព្រោះអស់រយៈ ពេលដប់បួនឆ្នាំនៃការរំលោភបំពានផ្លូវភេទកាលពីខ្ញុំនៅពីកុមារដែលខ្ញុំបានទ្រាំ។ តែខ្ញុំបានបញ្ចេញកំហឹងតាមរបៀបដែលមិនត្រឹមត្រូវ។ ខ្ញុំចាប់ផ្តើមមានចិត្តរឹងរូស ហើយឆេវឆាវក្នុងការធ្វើការជាមួយមនុស្ស។ ខ្ញុំបានដឹងថា យើងអាចយកឈ្នះការ អាក្រក់ដោយសារការល្អ(រ៉ូម ១២:២១)។

ខ្ញុំបានខឹងជាមួយនឹងអារក្សព្រោះវាបានលួចកុមារភាពរបស់ខ្ញុំ សកម្មភាព របស់ខ្ញុំដូចជាវាដែរ អារក្សអត់បានសងថ្លៃសម្រាប់ការបាត់បង់របស់ខ្ញុំទេ។ ពេល

នេះខ្ញុំប្រកាសដំណឹងល្អ ជួយមនុស្សដែលទទួលរងការឈឺចាប់ ខ្ញុំបានឃើញជីវិតរាប់មិនអស់បានស្តារឡើងវិញ ហើយនៅពេលដែលខ្ញុំធ្វើដូច្នោះ ខ្ញុំបានយកឈ្នះការអាក្រក់របស់សាតាំងដែលបានធ្វើចំពោះខ្ញុំ ដោយការដែលខ្ញុំធ្វើការល្អចំពោះអ្នកដទៃតាមរយៈការនាំដំណឹងល្អរបស់ព្រះដល់ពួកគេ។

*នេះគឺជារបៀបដើម្បីតតាំងចំពោះអារក្ស!*

ពេលអ្នកបានទទួលរងការឈឺចាប់ បើអ្នកមានចំណែកជួយដល់អ្នកដទៃលឿនប៉ុណ្ណា អ្នកនឹងបានប្រសើរឡើងលឿនប៉ុណ្ណោះ។ ការឈោងចាប់ដល់អ្នកដែលទទួលរងការឈឺចាប់ អាចជួយអ្នកឲ្យបំភ្លេចការឈឺចាប់របស់ខ្លួនឯងផ្ទាល់។

ការតែមួយគត់ដែលសងសឹកចំពោះអារក្ស សម្រាប់ការឈឺចាប់និងការបំផ្លិចបំផ្លាញនៅក្នុងជីវិតរបស់អ្នកផ្ទាល់គឺត្រូវតែស្វាហាប់ ហើយត្រូវខំធ្វើការថ្វាយព្រះយេស៊ូ។

## *ការខឹងខ្លួនឯង:*

ពេលមហន្តរាយប៉ះទង្គិច ជាញឹកញាប់មានសំណួរកើតឡើង «តើខ្ញុំអាចធ្វើអ្វីមួយដើម្បីការពារវាកុំឲ្យវាកើតឡើងបានទេ?»

ស្ត្រីម្នាក់ដែលខ្ញុំបានលើកមកនិយាយ បន្ទាប់ពីស្វាមីរបស់នាងបានស្លាប់ដោយសារជំងឺគាំងបេះដូង ខ្ញុំនៅតែចាំ ពីអ្វីដែលនាងធ្លាប់និយាយថានាងមានអារម្មណ៍មិនល្អសោះ។ នាងបានស្តីបន្ទោសខ្លួនឯងចំពោះការទាមទារ ដែលនាងចង់ជួបជាមួយវេជ្ជបណ្ឌិត។

បន្ទាប់ពីមហន្តរាយ ជាពិសេសពេលបាត់បង់អ្នកដែលជាទីស្រឡាញ់ មនុស្ស

គិតពីអ្វីមួយដែលពួកគេចង់និយាយ ឬចង់ធ្វើ និងគិតពីអ្វីដែលពួកគេអត់បាននិយាយនិងអត់បានធ្វើ។

យើងទាំងអស់គ្នាអាចរកឃើញការជាច្រើន ដែលយើងសោកស្តាយនៅក្នុង

ជីវិតរបស់យើង តែការសោកស្តាយមិនគ្រាន់តែធ្វើឲ្យឈឺចាប់ខ្លាំងលើសអ្វីៗដែលយើងធ្លាប់មានបទពិសោធន៍នោះទេ។ ជាញឹកញាប់សាតាំង កេងចំណេញពីហេតុការណ៍នោះដោយដាក់ការស្តីបន្ទោសលើយើង។ គាក់ទិចរបស់វា គឺបោះយើងទៅក្នុងឆាកជីវិតនៃការមានកំហុស ការចោទប្រកាន់និងការស្អប់ខ្លួនឯង។

នៅក្នុងភីលីព៣:១៣,១៤ លោកសាវកប៉ូលបានថ្លែងថា «...ខ្ញុំមានបំណងតែមួយ(ក្តីប៉ងប្រាថ្នាតែមួយរបស់ខ្ញុំ) គឺបំភ្លេចអ្វីៗទាំងអស់ដែលខ្ញុំរត់ហួសមកហើយ ដើម្បីផ្ចង់ចិត្តឆ្ពោះទៅរកអ្វីៗដែលនៅខាងមុខ។ ខ្ញុំរត់តម្រង់ទៅរក ទីដៅ...»។

ខ្ញុំស្រឡាញ់ពាក្យ *«ផ្ចង់ចិត្ត»* បានប្រាប់ខ្ញុំថា ការប្រឈមមុខជាមួយនឹងស្ថានភាពបែបណាក្តី ខ្ញុំត្រូវតែ«តម្រង់ទៅមុខ» នៅពេលនោះហើយត្រូវតែតយុទ្ធជាមួយខ្មាំងសត្រូវដើម្បីយកជ័យជំនះ។

*ទីបញ្ចប់តែងតែនាំឲ្យមានការចាប់ផ្តើមថ្មីជានិច្ច។*

ការវាយលុករបស់សាតាំង គឺរាំងយើងពីកន្លែងថ្មីដែលព្រះបានរៀបចំទុកសម្រាប់យើង។ វាចង់ដាក់អន្ទាក់យើងនៅជាប់នឹងអតីតហើយធ្វើឲ្យយើងរស់នៅក្នុងទុក្ខវេទនារហូត។ ការខឹងខ្លួនឯងនិងការស្តីបន្ទោសខ្លួនឯងអត់អាចធ្វើអ្វីបានទាំងអស់ តែបានធ្វើឲ្យបំណងចិត្តរបស់មារបានសម្រេចនៅក្នុងជីវិតរបស់យើង។

ខ្ញុំលើកទឹកចិត្តអ្នក សូមកុំធ្វើទុក្ខដល់ខ្លួនឯងជាមួយនឹងការសោកស្តាយ។

សាតាំងព្យាយាមជានិច្ចដើម្បីវាលុកអ្នក ពេលអ្នកស្ថិតក្នុងស្ថានភាពទន់ខ្សោយបំផុត។ កំហុស ការសោកស្តាយ និងវិប្បដិសារីគឺជាអាវុធដែលវាចូលចិត្ត។ ចូរពិចារណាលើការលើកទឹកចិត្ត មិនមែនលើការបាក់ទឹកចិត្តទេ។

*ចូរចងចាំៈ កុំខឹងជាមួយនឹងព្រះ ហើយកុំខឹងជាមួយនឹងខ្លួនឯង។ ចូរខឹងជាមួយនឹងមារ ហើយបញ្ចេញកំហឹងនោះឲ្យបានត្រឹមត្រូវដោយយកឈ្នះអំពើអាក្រក់ដោយអំពើល្អវិញ។*

***ការខឹងជាមួយនឹងអ្នកដទៃ:***

ជាការធម្មតាទេ ក្នុងការបញ្ចេញកំហឹងចំពោះអ្នកណាម្នាក់ដែលធ្វើឲ្យអ្នកឈឺចាប់នឹងមានទុក្ខវេទនា ទោះបីជាអ្នកនោះស្លាប់ហើយក្តី។

ម្តាយមីងខ្ញុំបានប្រាប់ខ្ញុំបន្ទាប់ពីឪពុកមារបស់ខ្ញុំស្លាប់ ពេលខ្លះនាងវាយខ្នើយរបស់នាងហើយស្រែក «ហេតុអ្វីបានជាបងទៅចោលអូនដូច្នេះ?» ពិតណាស់វិញ្ញាណរបស់នាងដឹងថា គាត់មិនមានបំណងចាកចោលពីនាងទេ តែអារម្មណ៍របស់នាងជាអ្នកនិយាយ។

យើងបានដឹងថា អារម្មណ៍មានសម្លេង ហើយពេលវាមានរបួស វាអាចនឹងមានប្រតិកម្មដូចជាសត្វដែលមានរបួសដែរ។ សត្វដែលមានបួសអាចគ្រោះថ្នាក់បានយ៉ាងលឿន អាម្មណ៍ក៏ដូចគ្នាដែរ បើសិនជាពួកគេដើរតាមអារម្មណ៍នោះ។

ពេលទទួលរងការឈឺចាប់ដោយសារការបាត់បង់ វាគឺជាការសំខាន់ក្នុងការមិនអនុញ្ញាតឲ្យអារម្មណ៍នៃការឈឺចាប់នោះក្លាយទៅជាការតូចចិត្ត ឬក្លាយជាភាពជូរល្វីង។ ពេលការលះលែងធ្វើឲ្យបាត់បង់ វាគឺជាការងាយដែលធ្វើឲ្យមានសេចក្តីសម្អប់ដល់ម្នាក់ដែលធ្វើឲ្យមានការបែកផ្លូវគ្នា ឬអាចធ្វើឲ្យមានការសងសឹកដោយធ្វើឲ្យគេឈឺចាប់វិញ។

កុំខាតពេលនៅក្នុងជីវិតរបស់អ្នកជាមួយនឹងភាពជូរល្វីង។ផ្ទុយទៅវិញទុកចិត្ត

ព្រះក្នុងការយកអ្វីដែលបានកើតឡើង ហើយអនុញ្ញាតឲ្យការនោះធ្វើឲ្យអ្នកបានប្រសើរឡើង។ ដូចគ្នាជាមួយអ្វីដែលធ្វើឲ្យអ្នកឈឺចាប់ វាក៏ធ្វើឲ្យអ្នកដទៃជាច្រើនទៀតឈឺចាប់ដូចអ្នកដែរ។ ចូរទូលទៅព្រះឲ្យប្រទានដល់អ្នកនូវ «មកុដ» នៅលើក្បាលជំនួស«ផេះ»វិញ។ សូមទ្រង់អនុញ្ញាតឲ្យអ្នកជួយអ្នកដទៃដែលកំពុងខំប្រឹងឆ្លងកាត់ភាពសោកសៅនិងភាពឯកា។

ទោះបីជា អ្នកដែលជាទីស្រឡាញ់ស្លាប់ក្តី នឹងមានពេលដែលអ្នកមានអារម្មណ៍ខឹងនឹងអ្នកនោះដែលបានចាកចេញពីអ្នកទៅដែរ។ អ្នកអាចគិតថា «អ្នក

អាចរស់នៅបាន បើសិនជាខំព្យាយាមជាងនេះ»។ ឬ «តើបងអាចចាកចោលពីអូន ទុកឲ្យអូនចិញ្ចឹមកូនហើយប្រឈមមុខជាមួយការទទួលខុសត្រូវដ៏ធ្ងន់ទាំងនេះតែម្នាក់ឯងដូច្នេះឬ?»

ទោះបីជាការគិតបែបនេះវាហាក់បីដូចជាគួរឲ្យអស់សំណើច ចំពោះមនុស្សដែលមាំមួននៅក្នុងពេលធម្មតាក្តី តែពេលមហន្តរាយវាយលុកហើយភាពសោកសៅបានចាប់ផ្តើម ជាញឹកញាប់មានទំនោរទៅរកការ «ស្តីបន្ទោស» អ្នកដទៃចំពោះទុក្ខវេទនាដែលពួកគេមានអារម្មណ៍។ ការគិតនិងអារម្មណ៍អាចមិនប្រក្រតីលោតពីការខឹងជាមួយនឹងព្រះ ទៅខឹងជាមួយខ្លួនឯង ពីការខឹងជាមួយខ្លួនឯងទៅខឹងជាមួយនឹងមារ ហើយពីការខឹងជាមួយមារទៅខឹងជាមួយអ្នកដែលទទួលខុសត្រូវចំពោះការបាត់បង់ថែមទៀត។ ការវិលជុំនេះអាចបន្តជាច្រើនដងហើយអាចធ្វើឲ្យមានការវិលវល់ដែរ។

ពេលណាយើងឈឺចាប់ ជាធម្មតានិស្ស័យរបស់មនុស្ស ឆ្លើយតបចំពោះការឈឺចាប់នោះគឺចេញជាកំហឹង ហើយព្យាយាមការពារខ្លួនឯងប្រឆាំងជាមួយការឈឺចាប់ដែលយើងមានបទពិសោធន៍មិនអាចទ្រាំបាននោះ។

ហេតុដូច្នេះហើយ បានជាវាសំខាន់ក្នុងការយល់ពីដំណើរការនៃភាពទុក្ខសោកនិងការយល់ដឹងអំពីអារម្មណ៍ដែលតាមមកជាមួយវា។ជាញឹកញាប់នៅក្នុងអតីត យើងធ្លាប់បានបង្រៀនឲ្យដាក់អារម្មណ៍បន្តិចបន្តួច ឬកុំឲ្យតម្លៃលើអារម្មណ៍របស់យើងឡើយ ដើម្បីបដិសេធអារម្មណ៍នោះថា វាមិនសំខាន់ទេ។

ដោយសារការបាត់បង់ភាពសំខាន់នៃការបាត់បង់នៅក្នុងជីវិតរបស់អ្នក គឺមិនមែនជាពេលដែលត្រូវបដិសេធអារម្មណ៍របស់អ្នកឬដោះស្រាយជាមួយបញ្ហាផ្សេងទៀតដែលធ្វើឲ្យមានការនឿយណាយ ឬអារម្មណ៍ព្រួយចិត្តនោះទេ។ ផ្ទុយទៅវិញអ្នកត្រូវប្រឈមមុខជាមួយនឹងអារម្មណ៍របស់អ្នកនិងដោះស្រាយជាមួយនឹងវា។

ចម្លើយគឺមិនត្រូវព្យាយាមបង្ក្រាបអារម្មណ៍ តែត្រូវដឹងពីអារម្មណ៍ថាវាយ៉ាងដូច

ម្ដេច ហើយបញ្ចេញអារម្មណ៍នោះដោយមានឫកពាត្រឹមត្រូវ។

*ដំណាក់កាលទី៣: អារម្មណ៍ដែលពុំអាចគ្រប់គ្រងបាន*

មនុស្សដែលមានបទពិសោធន៍ជាមួយនឹងមហន្តរាយ ជាញឹកញាប់ឆ្លងកាត់អារម្មណ៍ជាច្រើនដំណាក់កាល រួមមាន យំខ្សឹបខ្សួលនិងពាគសរសៃប្រសាទ។ ការទាំងនេះអាចចូលហើយចេញទៅវិញពេលមានសង្ឃឹមឡើងវិញបន្តិច។ ក្នុងមួយនាទីមនុស្សមានអារម្មណ៍ថា គាត់នឹងបានប្រសើរឡើង ហើយមួយម៉ោងក្រោយមក ភាពសោកសៅយ៉ាងច្រើនលើសលប់មាននៅក្នុងគាត់។

ទោះបីជាអស់អ្នកដែលជាធម្មតាមិនមែនជាមនុស្សដែលដើរដោយអារម្មណ៍ក្ដី អាចមានបទពិសោធន៍ជាមួយបញ្ហាខាងអារម្មណ៍ដ៏ធំដែរ នៅពេលមានការបាត់បង់។ មនុស្សម្នាក់ដែលមិនដែលយំសោះអាចយំអណ្ដើតអណ្ដកដែលមិនអាចគ្រប់គ្រងបាននៅក្នុងពេលណាមួយ។

ជាទូទៅ មនុស្សខ្លាចអារម្មណ៍ និងការបង្ហាញពីអារម្មណ៍ដែលមិនអាចគ្រប់គ្រងបាន អាចធ្វើឲ្យមានពេញការភ័យខ្លាច។

បើសិនជាអ្នកកំពុងឆ្លងកាត់ការលំបាកខាងអារម្មណ៍នៅពេលនេះ ខ្ញុំលើកទឹកចិត្តអ្នក «កុំខ្លាច»ព្រោះអ្វីដែលអ្នកកំពុងតែជួបនៅពេលនេះនឹងកន្លងផុតទៅ។ ការមានប្រាជ្ញា និង ការមានជំនួយជាច្រើនដែលមកពីព្រះវិញ្ញាណដ៏វិសុទ្ធនឹងនាំអ្នកឆ្លងកាត់ពេលវេលាដ៏អាក្រក់បំផុតបាន។

មានអ្នកខ្លះ បដិសេធមិនបង្ហាញទឹកភ្នែក ឬបង្ហាញអារម្មណ៍ណាមួយមកក្រៅ ដែលវាមិនមែនជាការល្អទេ។ ការលាក់អារម្មណ៍គឺជាអំណាចមួយយ៉ាងខ្លាំងដែលចំបាច់ត្រូវតែបញ្ចេញមកក្រៅ។ ប្រសិនបើអ្នកមិនបញ្ចេញអារម្មណ៍របស់អ្នកនៅពេលដែលមានការស្មុគស្មាញយ៉ាងខ្លាំងនោះទេ ដូចជាការដែលបាត់បង់មនុស្សដែលជាទីស្រឡាញ់ម្នាក់ អារម្មណ៍ទាំងនោះនឹងបំផ្លាញបន្តិចម្ដងៗនៅខាងក្នុង

អ្នកហើយវាអាចបំផ្លាញផ្លូវចិត្តរបស់អ្នក បំផ្លាញអារម្មណ៍ហើយលើសពីនេះទៀត វាបំផ្លាញសុខភាពខាងរូបកាយរបស់អ្នកថែមទៀតផងដែរ។

ពេលដែលព្រះប្រទានឲ្យយើងមានដំណក់ទឹកភ្នែក និងមានលទ្ធភាពអាចយំបាន នោះមានន័យថា នឹងមានពេលណាមួយនៅក្នុងជីវិតដែលយើងត្រូវតែយំ។

ព្រះគម្ពីរបានសំដែងឲ្យឃើញពីខគម្ពីរយោងមួយចំនួនចំពោះទឹកភ្នែកនេះ។ ឧទាហរណ៍ នៅក្នុងទំនុកតម្កើង៥៦:៨ អ្នកនិពន្ធរបស់គម្ពីរទំនុកតម្កើងសំដៅទៅលើដបដែលបានត្រងទឹកភ្នែករបស់គាត់ទុក។ នៅក្នុងវិវរណៈ ២១:៤ ដែលថ្លែងអំពីផ្ទៃមេឃនិងផែនដីថ្មី ដែលនៅថ្ងៃមួយព្រះនឹងនាំប្រជារាស្ត្ររបស់ព្រះអង្គ ជាអ្វីដែលយើងបានអាន «ព្រះអង្គនឹងជូតទឹកភ្នែក ចេញអស់ពីភ្នែករបស់គេ សេចក្ដីស្លាប់លែងមានទៀតហើយ ការកាន់ទុក្ខ ការសោកសង្រេង និងទុក្ខលំបាក ក៏លែងមានទៀតដែរ ដ្បិតអ្វីៗដែលកើតមានកាលពីមុននោះ បាត់អស់ទៅហើយ»។

មានការយំសោកដែលធម្មតានិងយំសោកដែលមិនធម្មតា។ ការបញ្ចេញអារម្មណ៍មានរបួសបានត្រឹមត្រូវគឺជារឿងធម្មតា តែចូរដឹងអំពីការអាណិតខ្លួនឯង។ បើទុកវាមិនបានប្រឈមមុខទេ វានឹងក្លាយទៅជាសត្វចម្លែកដែលនឹងធ្វើឲ្យអ្នកខ្លួនឯងបែរទៅរកអ្វីដែលកាន់តែយ៉ាប់ជាងមុន។

ក្ដីមេត្តាគឺជាអំណោយទានដែលព្រះបានដាក់នៅក្នុងយើងម្នាក់ៗដើម្បីសំដែងចេញមកខាងក្រៅដល់អ្នកណាម្នាក់ផ្សេងទៀត ដែលទទួលរងការឈឺចាប់។ ក្ដីមេត្តា បានប្រឡប់មករកយើងវិញ ជាការអាណិតនិងធ្វើឲ្យយើងជាប់គាំង។

ការអាណិតខ្លួនឯងធ្វើឲ្យយើងញៀនផងដែរ។ អ្នកអាចគិតថាវាគឺជារបៀបនៃការបំរើដល់ខ្លួនឯងផ្ទាល់ តែតាមពិតជាគឺជារបៀបដែលសាតាំងរារាំងអ្នកពីការធ្វើដំណើរឆ្លងការមហន្តរាយវិញទេ។

អ្នកត្រូវតែដឹងផងដែរ ពីការប្រើទឹកភ្នែកក្នុងការគ្រប់គ្រងអ្នកដទៃ។ ពេលដែលអ្នកឈឺចាប់ អ្នកត្រូវការអ្នកដទៃឲ្យបង្ហាញក្ដីស្រឡាញ់និងក្ដីមេត្តាដល់អ្នក។

ពីពេលមួយទៅពេលមួយយើងគ្រប់គ្នា មិនថាយើងខ្លាំង ឬយើងជាមនុស្សឯករាជ្យប៉ុណ្ណាទេ យើងត្រូវការជំនួយពីគ្នាទៅវិញទៅមកនៅពេលណាមួយមិនខាន។ តែយើងត្រូវចងចាំថា ទោះបីជាមានពេលដែលយើងត្រូវការ ការយកចិត្តទុកដាក់ពិសេសនៅពេលណាមួយក្ដី អ្នកដទៃមិនអាចដោះស្រាយបញ្ហារបស់អ្នកបានទេ។

ពេលយើងមើលទៅអ្នកដទៃ ការរំពឹងឲ្យពួកគេជួយធ្វើឲ្យការឈឺចាប់របស់យើងបានកន្លងផុតទៅ យើងកំពុងតែគិតខុសហើយ។

ជាដំបូងយើងត្រូវដឹងថា មនុស្សមិនអាចផ្ដល់អ្វីគ្រប់យ៉ាងដែលយើងត្រូវការបាននោះទេ។ ទីពីរ ការរំពឹងឲ្យអ្នកដទៃបំពេញសេចក្ដីត្រូវការផ្ទាល់ខ្លួនរបស់យើងវានឹងមានការប៉ះពាល់ដល់ទំនាក់ទំនងរបស់យើង។ ជាពិសេស ប្រសិនបើឥរិយាបថឯករាជ្យនៅតែបន្តពន្យារពេលយូរថែមទៀតនោះ។

អាចយល់បានសម្រាប់ស្ត្រីម្នាក់ ដែលបាត់បង់ស្វាមីរបស់នាងហើយនាងចង់ឲ្យកូនៗរបស់នាងបានបំពេញការបាត់បង់នោះនៅក្នុងជីវិតរបស់នាងវិញ។

នេះគឺជាការល្អ ប្រសិនបើស្ត្រីនោះពិតជាមានបំណងក្នុងការ«ប្រគល់»លះបង់ខ្លួនរបស់នាងជាច្រើននៅពេលនេះសម្រាប់កូនៗរបស់នាង ដែលនាងបានផ្ដល់ពេលវេលានិងលទ្ធភាពក្នុងការធ្វើការនេះ។តែប្រសិនបើស្ត្រីនោះធ្វើការនោះដោយបង្ខំកូនៗឲ្យទទួលខុសត្រូវលើរូបនាង ពួកគេនឹងមិនសប្បាយចិត្តឡើយ។

ជាធម្មតា មនុស្សម្នាក់ៗមានជីវិតខ្លួនឯងផ្ទាល់ក្នុងការរស់នៅ ហើយមិនថាមានសេចក្ដីស្រឡាញ់ច្រើនប៉ុណ្ណារវាងមនុស្សម្នាក់ៗ គ្មានអ្នកណាចង់ឲ្យគេគ្រប់គ្រង ឬប្រើប្រាស់ដោយហេតុផលអាត្មានិយមនោះទេ។

បើសិនជាអ្នកមានបទពិសោធន៍ជាមួយនឹងការឈឺចាប់ ឬសៅហ្មងក្នុងចិត្តនៅពេលនេះ។ ខ្ញុំលើកទឹកចិត្តអ្នកឲ្យទុកចិត្តលើព្រះ ហើយអនុញ្ញាតឲ្យទ្រង់បានបំពេញភាពស្កប់ចិត្តនៅក្នុងទំនាក់ទំនងដែលយល់ឃើញថាល្អ ហើយត្រឹមត្រូវ។ ព្រះអង្គជ្រាបថា អ្នកមានសេចក្ដីត្រូវការផ្សេងៗនៅពេលនេះ។ ព្រះអង្គជ្រាបថា

ភាពខ្វះខាតនៅក្នុងជីវិតរបស់យើងដែលចាំបាច់ត្រូវការបំពេញ។ ពេលវាកើតឡើង ព្រះអង្គនឹងបំពេញភាពខ្វះខាតនៅក្នុងជីវិតរបស់យើងនោះ ប្រសិនបើយើងរង់ចាំទ្រង់ ហើយបដិសេធក្នុងការប្រើអារម្មណ៍របស់យើងទៅគ្រប់គ្រងអ្នកដទៃ។

មនុស្សជាធម្មតាមិនបានធ្វើការនោះអស់ពីចិត្តទេ។ យើងប្រហែលជាគ្រាន់តែពេលឈឺចាប់ ហើយស្វែងរកអ្វីមួយដែលអាចសម្រាលការឈឺចាប់នោះ។ តែវិធីរបស់ព្រះវិញមិនមែនបន្ធូរបន្ទុកពីអ្នកណាម្នាក់ ហើយបន្ថែមបន្ទុកដល់អ្នកណាម្នាក់ទៀតនោះទេ។

មហន្តរាយបន្សល់ទុកដល់យើងនូវភាពទន់ខ្សោយ ហើយសាតាំងព្យាយាមកេងចំណេញពីយើងក្នុងខណៈពេលដែលយើងទន់ខ្សោយនោះ។ អារក្សអត់មានអារម្មណ៍ខ្មាស់ពេលដែលវាវាយលុកយើង ក្នុងពេលដែលយើងដួលហើយនោះទេ។ វាឃើញ ភាពឯកាទាំងនោះ កំឡុងពេលនៃការឈឺចាប់គឺជាឱកាសមាសសម្រាប់វាក្នុងការនាំយើងទៅរកចំណងនិងទុក្ខវេទនារហូត។

*តុល្យភាព* នឹងបិទទ្វារនៅចំពោះមុខសាតាំង។

អស់ពេលជាច្រើនឆ្នាំ ខ្ញុំបានដឹងថា យើងត្រូវតែរៀនក្នុងការឆ្លងកាត់ការជាច្រើននៅក្នុងជីវិតរបស់យើងម្នាក់ៗ។ ការនោះមិនមែនមានន័យថា យើងមិនត្រូវការមនុស្សទេ យើងត្រូវការមនុស្ស។ អ្នកដទៃពិតជាព្រះបានប្រើក្នុងការនាំការកំសាន្តចិត្តដល់យើង ពេលយើងឈឺចាប់។ ប៉ុន្តែ ប្រសិនបើ «សេចក្តីត្រូវការ» របស់យើងឲ្យអ្នកដទៃអត់មានតុល្យភាពនោះ វាអាចរាំងព្រះអង្គក្នុងការធ្វើការនៅក្នុងជីវិតរបស់យើង។

អារម្មណ៍របស់ខ្ញុំធ្វើឲ្យខ្ញុំមានការឈឺចាប់អស់រយៈពេលជាច្រើនឆ្នាំដោយសារ

ការរំលោភបំពានផ្លូវភេទពីកុមារភាពរបស់ខ្ញុំ។ នៅក្នុងពេលនោះខ្ញុំរំពឹងស្វាមីរបស់ខ្ញុំក្នុងការបំពេញសេចក្តីត្រូវការខាងអារម្មណ៍របស់ខ្ញុំហើយនិងបំពេញភាពខ្វះខាតនៅក្នុងជីវិតរបស់ខ្ញុំ ដែលដោយសារការមានទំនាក់ទំនងខុសជាមួយនឹងឪពុក

របស់ខ្ញុំ។ ពិតណាស់ ព្រះអម្ចាស់ប្រើស្វាមីរបស់ខ្ញុំក្នុងការនាំការប្រោសឲ្យជាផ្នែកអារម្មណ៍ទាំងស្រុងនៅក្នុងជីវិតរបស់ខ្ញុំ។ តែខ្ញុំបានដឹងថា ខ្ញុំត្រូវតែខំធ្វើការថែមទៀត ជាមួយព្រះក្នុងការឆ្លងកាត់បញ្ហារបស់ខ្ញុំភាគច្រើនបំផុតជាមួយព្រះអង្គតែមួយគត់។

អត្ថប្រយោជន៍មួយក្នុងការគ្មានអ្នកណាម្នាក់ដើម្បីទៅរកនោះ គឺជាព្រះដែលយើងត្រូវចូលទៅរក ហើយចាក់ឫសយ៉ាងជ្រៅ«នៅក្នុងទ្រង់»ព្រះអង្គគឺជាថ្មដា ជាគ្រឹះរឹងមាំដែលមិនដែលរង្គើរឡើយ។ មិនថាមានអ្វីផ្សេងនៅជុំវិញកំពុងអង្រួនយើងក្តី ព្រះអង្គនៅតែដដែរ។

បើសិនជាអ្នកកំពុងទុក្ខសោក ហើយមានភាពឯកាដោយសារតែមហន្តរាយនៅក្នុងជីវិតរបស់អ្នក ចូរធ្វើឲ្យការនោះទៅជាឱកាសនៃការមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះវរបិតា ព្រះរាជបុត្រានិងព្រះវិញ្ញាណដ៏វិសុទ្ធវិញ។

*ចូរចងចាំៈ សាតាំងចង់ប្រើពេលមានទុក្ខលំបាកនោះដើម្បីបំផ្លាញអ្នក តែអ្វីដែលធ្វើឲ្យអ្នកឈឺចាប់នោះ ព្រះអង្គនឹងធ្វើឲ្យវាក្លាយទៅជាការល្អសម្រាប់អ្នកវិញ*

*នៅពេលដែលអ្នកព្រមឲ្យព្រះអង្គធ្វើការនោះ។* (លោកប្បត្តិ ៥០:២០; រ៉ូម ៨:២៨)

***ដំណាក់កាលទី៤: ភាពតានតឹង***

បើអ្នកមានអារម្មណ៍តានតឹង កុំមានអារម្មណ៍មិនល្អមានចំពោះខ្លួនឯងឡើយ។ មនុស្សគ្រប់គ្នាមានបទពិសោធន៍ជាមួយនឹងភាពតានតឹង នៅពេលណាមួយ ឬនៅពេលណាមួយផ្សេងទៀត។

នៅពេលភាពសោកសៅហួរចូលដល់ព្រលឹង អារម្មណ៍នៃភាពតានតឹង គឺពិត

ជាសំខាន់ សូម្បីតែនៅក្នុងចំណោមមនុស្សដែលស្គាល់ហើយស្រឡាញ់ព្រះក្តី។ នៅក្នុងទំនុកតម្កើង ស្តេចដាវីឌ បានថ្លែងថា គាត់គឺជាមនុស្សដែលព្រះគាប់ព្រះហឫទ័យ បាននិយាយពីអារម្មណ៍តានតឹង។ បើសិនជាមនុស្សរបស់ព្រះជាម្ចាស់

ដូចជាស្តេចដាវីឌត្រូវតែជួបប្រទះជាមួយភាពតានតឹងទៅហើយ ដូច្នេះហើយទាំងអស់គ្នាក៏ត្រូវតែជួបដែរ។

ភាពតានតឹងបណ្តោះអាសន្នមួយរយៈ វាគ្រាន់តែជាអារម្មណ៍របស់មនុស្សផ្សេងៗ ដែលគ្រប់គ្នាមានបទពិសោធន៍នៅក្នុងដំណើរការសោកសៅធម្មតា។ តែដូចជាអារម្មណ៍មួយទៀតដែរ ចូលមកជាមួយនឹងការសោកសៅ ភាពតានតឹងដែលអត់បានត្រួតពិនិត្យ អាចធ្វើឲ្យមានបញ្ហាធំ។

ពាក្យ តានតឹងសំដៅលើសភាពនៃការស្ថិតនៅក្រោម ឬទីកន្លែងដែលលិចលង់នៅក្រោមកំរិតធម្មតា។ បើគិតឲ្យងាយពីវាគឺដូច្នេះ: ព្រះយេស៊ូគឺជាសិរីរុងរឿងរបស់យើង ហើយប្រោសយើងឲ្យងើបមុខឡើងវិញបាន។ (ទំនុកតម្កើង៣:៣) តែនៅក្នុងពេលដែល ព្រះយេស៊ូលើកមុខយើងឡើងហើយលើកយើងឡើងទៀត សាតាំងមក*ដើម្បីនឹងទាញយើងទំលាក់ចុះវិញ* ហើយកប់យើងនៅក្នុងស្នាមរបួសការឈឺចាប់និងបញ្ហាផ្សេងៗ។

ភាពតានតឹងលួចថាមពលរបស់មនុស្ស។ គេនឹងក្លាយទៅជាមនុស្សស្ពឹកនិងខ្ជិលច្រអូស គ្មានបំណងចង់បានអ្វីទាំងអស់។ បើសិនជាសភាពនៃភាពតានតឹងនៅតែបន្តហើយមានភាពតានតឹងកាន់តែខ្លាំងឡើងនោះ គ្រប់ទាំងចលនាត្រូវតែខំប្រឹងប្រែង។ មនុស្សដែលមានភាពតានតឹង ជាញឹកញាប់ គេងច្រើនជាងធម្មតាដើម្បីជៀសវាងពីជីវិតដែលខ្វះខាតនោះ។

ភាពតានតឹង តាមពិតអាចក្លាយទៅជាការរត់គេច ឬការលាក់បំពួនក្នុងករណីខ្លះ។ វាអាចប្រើដើម្បីជៀសវាងក្នុងការដោះស្រាយជាមួយនឹងជីវិតនិងបញ្ហារបស់ជីវិតនោះផងដែរ។ **ការប្រឈមមុខជាមួយនឹងបញ្ហាតែងតែពិបាកជាងការរត់គេចពីបញ្ហាជានិច្ច។**

នៅក្នុងករណីរបស់ខ្ញុំផ្ទាល់ ខ្ញុំបានរត់គេចពីបញ្ហានៅក្នុងជីវិតរបស់ខ្ញុំដែលកើតឡើងដោយសារការរំលោភបំពានផ្លូវភេទរហូតទាល់តែខ្ញុំមានអាយុ៣២ឆ្នាំ។ ពេល

ដែលខ្ញុំពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ការមួយដំបូងដែលព្រះអង្គចាប់ផ្ដើមធ្វើនៅក្នុងជីវិតរបស់ខ្ញុំគឺនាំខ្ញុំទៅកាន់សេចក្ដីពិត ដូចដែលព្រះយេស៊ូបានសន្យាថាព្រះអង្គនឹងធ្វើ(យ៉ូហាន១៦:៣)។ ព្រះយេស៊ូក៏មានបន្ទូលផងដែរថា សេចក្ដីពិតនឹងដោះយើងឲ្យរួច(យ៉ូហាន៨:៣២) តែត្រូវតែប្រឈមមុខជាមួយនឹងសេចក្ដីពិតនោះប្រសិនបើវាមានផលប៉ះពាល់វិជ្ជមានកើតឡើងនៅក្នុងជីវិតរបស់យើង។

ចូរមើលក្នុងបទគម្ពីរ ឲ្យឃើញពីរបៀបដែលស្ដេចដាវីឌឆ្លើយតបជាមួយនឹងបញ្ហានៃភាពតានតឹងដែលមានតាំងពីយូរលង់ណាស់មកហើយ។ក្នុងទំនុកតម្កើង ៤២:៥-១១ លោកបានសរសេរពីសភាពលិចលង់នៃអារម្មណ៍របស់គាត់:

*ខ្ញុំនិយាយមកខ្លួនឯងថា: «ឯងស្រយុតចិត្តធ្វើអ្វី ឯងថ្ងូរធ្វើអ្វី ចូរផ្ញើជីវិតលើព្រះជាម្ចាស់ទៅ!»ខ្ញុំមុខជាសរសើរតម្កើងព្រះអង្គតទៅមុខទៀត ព្រះអង្គសង្គ្រោះខ្ញុំ។*

*ព្រះនៃទូលបង្គំអើយ ទូលបង្គំស្រយុតចិត្តជាខ្លាំង ហេតុនេះហើយ*

*បានជាទូលបង្គំនឹកឃើញ ព្រះអង្គពីកន្លែងដែលទូលបង្គំនៅនេះ គឺភូមិភាគទន្លេយ័រដាន់ ភ្នំហ៊ើរម៉ូន និងភ្នំមីតសារ។*

*ព្រះអង្គបានធ្វើឲ្យទុក្ខកង្វល់ ធ្លាក់មកលើទូលបង្គំ ដូចទឹកជ្រោះហូរធ្លាក់ពីលើភ្នំ លាន់ឮគគ្រឹកគគ្រេង។*

*នៅពេលថ្ងៃព្រះអម្ចាស់សំដែង ព្រះហឫទ័យមេត្តាករុណាចំពោះខ្ញុំ នៅពេលយប់ ខ្ញុំច្រៀងបទតម្កើងព្រះអង្គបទចំរៀងនេះជាពាក្យអធិស្ឋានចំពោះ ព្រះជាម្ចាស់នៃជីវិតខ្ញុំ។*

*ខ្ញុំទូលព្រះជាម្ចាស់ ដែលជាថ្មដារបស់ខ្ញុំថា ហេតុអ្វីបានជាព្រះអង្គបំភ្លេចទូលបង្គំ? ហេតុអ្វីបានជាទូលបង្គំត្រូវរងទុក្ខលំបាក ហើយត្រូវខ្មាំងសត្រូវសង្កត់សង្កិនដូច្នេះ?។*

*ខ្មាំងសត្រូវនាំគ្នាជេរប្រមាថទូលបង្គំ ធ្វើឲ្យទូលបង្គំឈឺចុកចាប់សព្វសព៌ាង្គកាយ គេចេះតែពោលមកទូលបង្គំគ្រប់ពេល គ្រប់វេលាថា «តើព្រះរបស់ឯងនៅឯណា?»។*

*ខ្ញុំនិយាយមកខ្លួនឯងថា «ឯងស្រយុតចិត្តធ្វើអ្វី ឯងថ្ងូរធ្វើអ្វី ចូរផ្ញើជីវិតលើព្រះជាម្ចាស់ទៅ!»ខ្ញុំមុខជាសរសើរតម្កើងព្រះអង្គតទៅមុខទៀត ព្រះអង្គសង្គ្រោះខ្ញុំ ហើយព្រះអង្គជាព្រះនៃខ្ញុំ។*

ខ្ញុំស្រឡាញ់បទគម្ពីរទាំងនេះ ព្រោះស្តេចដាវីឌដឹងថាមានអារម្មណ៍តានតឹងវាយលុកព្រះអង្គហើយហូរចូលមកក្នុងព្រលឹងរបស់ព្រះអង្គ លើសពីនេះ ទ្រង់តយុទ្ធជាមួយនឹងវា។ ម៉្យាងវិញទៀត ទោះបីជាព្រះអង្គមានអារម្មណ៍តានតឹងក៏ដោយ ទ្រង់មិនបានបណ្តោយតាមអារម្មណ៍នោះទេ។ ទ្រង់មានបន្ទូលទៅកាន់អង្គឯងអំពីស្ថានភាពរបស់ទ្រង់។យើងក៏ត្រូវនិយាយទៅកាន់ខ្លួនយើងដែរនៅពេលដូច្នេះ ដាវីឌចងចាំការល្អដោយមានគោលបំណងច្បាស់លាស់ ដើម្បីឲ្យព្រលឹងរបស់ព្រះអង្គមិនពេញដោយគំនិតអវិជ្ជមាននិងឥទ្ធិពលរបស់វាឡើយ។

ដើម្បីការពារខ្លួនឯងផ្ទាល់ វាគឺជាការសំខាន់ណាស់ដែលយើងត្រូវតយុទ្ធជាមួយនឹងភាពតានតឹងដែលមានតាំងពីយូរលង់ណាស់មកហើយ។ វាមិនអាចទៅរួចទេ ក្នុងការឆ្លងកាត់ដំណើរការនៃការសោកសៅដែលត្រឹមត្រូវដោយអត់មានបទពិសោធន៍ជាមួយអារម្មណ៍ព្រួយចិត្ត អារម្មណ៍បាត់បង់និងអារម្មណ៍តានតឹងនោះ។ ប៉ុន្តែម្តងទៀត បំណងចិត្តរបស់ខ្ញុំគឺនាំពាក្យប្រម្រាមទាក់ទងនឹងស្ថានការណ៍ដែលអត់មានតុល្យភាព ដែលមានហួសពីធម្មតាហើយបានឆ្លងផុតបន្ទាត់ប្រភេទនៃការបំផ្លាញ។

អារម្មណ៍ធម្មតានិងការបញ្ចេញអារម្មណ៍បានត្រឹមត្រូវគឺជារឿងល្អ។ តែពេលដែលយើងអនុញ្ញាតឲ្យអារម្មណ៍គ្រប់គ្រងយើង វាអាចក្លាយទៅមហន្តរាយយ៉ាងខ្លាំង។ កុំទប់អារម្មណ៍របស់អ្នក តែកុំផ្តល់ឲ្យអារម្មណ៍នោះដឹកនាំនៅក្នុងជីវិតរបស់អ្នកទាំងស្រុងឡើយ។

អស់អ្នកណាដែលបដិសេធមិនព្រមអនុវត្តន៍ការគ្រប់គ្រងចិត្តខ្លួនឯង ហើយអនុញ្ញាតឲ្យអារម្មណ៍របស់គាត់អត់មានការត្រួតត្រានោះ ទីបំផុតនឹងរស់នៅក្នុងជីវិតដែលបំផ្លាញខ្លួនឯង។

អារម្មណ៍គឺជាអំណោយទានមកពីព្រះ។ អារម្មណ៍ពិតជាសំខាន់ណាស់សម្រាប់ការរស់នៅរបស់មនុស្ស។ គ្មានអ្នកណាម្នាក់ចង់រស់នៅដោយគ្មានអារម្មណ៍នោះទេ។ តែនៅពេលជាមួយគ្នានោះ យើងមិនអាចរស់នៅក្នុងជីវិតរបស់យើងតាមមនោសញ្ចេតនានិងតាមអារម្មណ៍របស់យើងទេ។ ហេតុផលមួយគឺអារម្មណ៍របស់យើងអត់មានស្ថេរភាពទាល់តែសោះ។ ហើយអាចមានអារម្មណ៍រាប់ពាន់ខុសៗគ្នានៅក្នុងកំឡុងពេលមួយខែចំពោះស្ថានភាពដូចគ្នា។

បទពិសោធន៍មនុស្ស ខ្វះការរក្សាតុល្យភាពនេះ នៅក្នុងអារម្មណ៍របស់ពួកគេជាពិសេសនៅក្នុងពេលមានវិបត្តិនិងមហន្តរាយ ដែលនាំយើងចូលទៅរកដំណាក់កាលពីធម្មតាមួយទៀតនៃដំណើរការរបស់ការសោកសៅ។

## *ដំណាក់កាលទី៥: រលកនៃអារម្មណ៍ដ៏លើសលប់*

ពេលដែលអ្នកឆ្លងកាត់ដំណើរការនៃភាពសោកសៅ វានឹងក្លាយជាពេលដែលអ្នកមានអារម្មណ៍ថា អ្នកបានខិតខំឆ្លងកាត់អារម្មណ៍របួសដោយសារមហន្តរាយឬក៏ការបាត់បង់។ វាគឺជារឿងធម្មជាតិក្នុងការគ្មានកម្លាំងដោយសារអារម្មណ៍ឈឺចាប់គ្រប់យ៉ាងរបស់អ្នក និងការបានធូស្បើយហើយទីបញ្ចប់វានឹងរលាយបាត់ទៅរហូត។ ទោះបីជាយ៉ាងណាក្តី វាមិនអាចកើតឡើងបែបនោះរហូតទេ។ ជាទូទៅពេលវេលានៃការធូរស្រាលទាំងនោះកើតឡើង ដោយសារការធ្វើចលនាយ៉ាងរហ័សដូចជាអារម្មណ៍ដ៏លើសលប់ជាដើម។

វាគឺជាវិធីល្អក្នុងការគិតពីអារម្មណ៍លិចនិងអណ្តែត គឺជារូបភាពនៃសមុទ្រដែលមានរលកធំៗបោកបក់លើច្រាំងដោយសន្តិភាព និងស៊ីចង្វាក់គ្នានៅចន្លោះរវាងរលកនិងច្រាំង។

ដំបូង ហាក់បីដូចជាអត់មានការបែកបាក់ដោយសាររលកនៃការខូច ចិត្តដែលបានបោកបក់មកលើអ្នកនិងបំភ័យអ្នកដើម្បីធ្វើឲ្យអ្នកដួលចុះ។ នេះគឺជាអារម្មណ៍សកលមួយដែលមានសារៈសំខាន់ចំពោះមនុស្ស គ្រប់គ្នានៅគ្រប់ទាំងកន្លែងនៅក្នុងប្រវត្តិសាស្ត្រ។ បើអ្នកនឹកចាំបទគម្ពីរនៅក្នុងទំនុកតម្កើង៤២:៦,៧ អ្នកនឹងចងចាំពីរបៀបដែលដាវីឌសរសេរអំពីការខូចចិត្តរបស់គាត់«*ព្រះនៃទូលបង្គំអើយ ទូលបង្គំស្រយុតចិត្តជាខ្លាំង (ហើយទូលបង្គំឃើញថាបន្ទុកធ្ងន់ដែលធ្វើឲ្យទូលបង្គំទ្រាំមិនបាន...ព្រះអង្គធ្វើឲ្យទុក្ខកង្វល់ធ្លាក់លើទូលបង្គំដូច ទឹកជ្រោះហូរធ្លាក់ពីលើភ្នំលាន់ឮគគ្រឹកគគ្រេង*»។

បន្ទាប់ពីបន្តិចក្រោយមក វានឹងចាប់ផ្តើមក្លាយជាសភាពធម្មតាវិញ រវាងការកើនឡើងរបស់រលក។ នៅក្នុងពេលដូច្នោះអាចគិតឃើញថា ការឈឺចាប់មិនអាចត្រឡប់មកវិញបានទេ។ បន្ទាប់មកពេលអ្នករំពឹងលើវាតិចពេក វានឹងត្រឡប់មកវិញយ៉ាងពេញកម្លាំង។ ពេលខ្លះអាចកើតឡើងដោយសារហេតុផលនៃការចងចាំ

និងគ្រប់ទាំងអារម្មណ៍ចាស់ៗដែលត្រឡប់មកវិញជាមួយនឹងសេចក្តីសងសឹក។

ខួបគម្រប់បុណ្យសព ការបាត់បង់ ឬការបែកបាក់ និងការពិសេសផ្សេងទៀតដែលបង្ហាញឲ្យឃើញនាពេលខាងមុខដូចជាវិស្សមកាលនិងខួបកំណើត វាពិតជាពិបាកក្នុងការដោះស្រាយ។

គេប្រាប់ខ្ញុំថា កំរិតនៃការសម្លាប់ខ្លួនកើតឡើងយ៉ាងខ្លាំងនៅក្នុងរដូវវិស្សម

កាល ។ ចូរស្រមៃមើលថាវាពិបាកប៉ុណ្ណាសម្រាប់មនុស្សក្នុងការដោះស្រាយ ពេលមនុស្សជាទីស្រឡាញ់ម្នាក់បានស្លាប់ ឬអាចមហន្តរាយផ្សេងៗកើតឡើង បើសិនជាគេមិនស្គាល់ព្រះអម្ចាស់និងមិនស្គាល់ពីព្រះវត្តមានដ៏អស់កល្បរបស់ទ្រង់។

ពួកយើងដែលជាអ្នកមានជំនឿលើព្រះយេស៊ូគ្រិស្ត បានទទួលការលួងលោមចិត្តពីព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទោះបីជាយ៉ាងនេះក្តី នៅតែមានភាពលំបាកសម្រាប់យើង។ ដូច្នេះយើងអាចស្រមៃអំពីអ្នកដែលទ្រាំការឈឺចាប់ដែលគេមាន

ដែលពួកគេអត់មានអ្វីទាំងអស់នៅក្នុងពួកគេរួចស្រេចទៅហើយនោះ ពួកគេបានបាត់បង់អ្នកណាម្នាក់ ឬអ្វីមួយដែលពិតជាសំខាន់សម្រាប់ពួកគេ។

នៅក្នុងពេលកំពុងតែព្យាយាមដូច្នេះ ខ្ញុំដឹងច្បាស់ថា វាគឺជាការងាយស្រួលសម្រាប់សាតាំងក្នុងការធ្វើឲ្យពួកគេជឿ គ្មានអ្វីចង់ឲ្យរស់នៅទៀតទេ ការឈឺចាប់ដែលពួកគេបានជួបនោះ វាច្រើនហួសពេកដែលពួកគេមិនអាចទ្រាំបាន។

ពេលខ្លះ ខ្ញុំឮមនុស្សនិយាយជាមុន «ខ្ញុំមានការភ័យខ្លាចចំពោះព្រឹត្តការណ៍នៃពិធីបុណ្យនោះណាស់ ខ្ញុំតែងតែមានភាពតានតឹងខ្លាំងណាស់នៅថ្ងៃនោះ»។

ការខ្លាចដ៏ខ្លាំងគឺជាអ្នកនាំមុខនៃភាពភ័យខ្លាច ហើយវាមិនដែលនាំព្រះពរទេ ពេលដែលខ្ញុំចាប់ផ្តើមមានការភ័យខ្លាចអ្វីមួយយ៉ាងខ្លាំង ព្រះវិញ្ញាណដ៏វិសុទ្ធតែងតែរំលឹកខ្ញុំដោយសុភាព នៅពេលដែលខ្ញុំកំពុងតែរៀបចំខ្លួនរបស់ខ្ញុំឲ្យធ្លាក់ទៅក្នុងសេចក្តីទុក្ខលំបាក។

នៅពេលដែលអ្នកមានអារម្មណ៍ចាប់ផ្តើមជួបប្រទះជាមួយនឹងអារម្មណ៍នៃការភ័យខ្លាចយ៉ាងខ្លាំងនោះ ខ្ញុំសូមណែនាំថា អ្នកត្រូវអធិស្ឋានហើយទូលដល់ព្រះ សូមឲ្យព្រះអម្ចាស់ប្រទានកម្លាំងដល់អ្នក ក្នុងការប្រឆាំងអារម្មណ៍ដ៏លើសលប់របស់អ្នក។

ពេលខ្លះយើងមានការភ័យរន្ធត់នឹងអ្វីមួយដោយមិនដឹងខ្លួន។ ការសូមជំនួយពីព្រះនឹងនាំអ្នកឲ្យដឹងអ្វីដែលនឹងកើតឡើង វានឹងពង្រឹងយើងឲ្យប្រសើរឡើងដើម្បីជៀងវាងការលិចលង់ទៅក្នុងការភ័ន្តច្រឡំ ការវង្វេងស្មារតីនិងការភ័យខ្លាច។

## *ដំណាក់កាលទី៦:ការភ័ន្តច្រឡំ ការវង្វេងស្មារតីនិងការភ័យខ្លាច*

ការប្រឈមមុខជាមួយនឹងការផ្លាស់ប្រែនៅក្នុងជីវិតរបស់យើងគឺជាពេលវេលាដែលមានអារម្មណ៍ដ៏លំបាកបំផុត ដែលយើងត្រូវតែទ្រាំទ្រ។ សូម្បីតែការផ្លាស់ប្រែជាជម្រើសរបស់យើងផ្ទាល់ក្តីជាពើយៗវាពិបាកសម្រាប់យើងក្នុងការដោះស្រាយ។

ប្រសិនបើការផ្លាស់ប្រែនោះកើតឡើងបណ្ដាលមកពីមហន្តរាយ ការបាត់បង់ ឬវិបត្តិអ្វីមួយ ដូច្នេះការភ័ន្តច្រឡំ ការវង្វេងស្មារតីនិងការភ័យខ្លាចនោះគឺជារឿងធម្មតា។ រំពេចនោះផែនការសម្រាប់អនាគតរបស់យើងត្រូវបានបរាជ័យ។ វិស្សមកាល ការទិញផ្ទះ គម្រោងចូលនិវត្តន៍នៅក្នុងក្រុមហ៊ុនត្រូវបានបរាជ័យ ឬគម្រោងនៃការថែរក្សាត្រូវបានលុបចោលដោយមិនបានរំពឹងទុកជាមុន។

វាត្រូវការពេលក្នុងការស្វែងរកទិសដៅថ្មី។ នៅក្នុងពេលដូច្នេះ ក្នុងពេលតែមួយ មានសំណួរជាច្រើនបានលេចមកប្រឆាំងជាមួយនឹងគំនិតរបស់យើង ហើយមានសំណួរជាច្រើនអាចបង្ខំចង់បានចម្លើយភ្លាមៗ។

ទោះបីជាមិត្តសម្លាញ់ស្គាល់ចិត្ត និងញាតិសន្តានអាចសួរហើយសួរទៀត «តើអ្នកនឹងធ្វើអ្វីនៅពេលនេះ? តើអ្នករស់នៅឯណា? តើអ្នកត្រឡប់មកធ្វើការវិញក្នុងពេលឆាប់ៗនេះ ឬមួយអ្នកនៅតែបន្តសម្រាកថែមទៀត?»

សំណួរទាំងនេះគឺជាសំណួរដែលមានសុពលភាព ហើយត្រូវតែមានចម្លើយនៅទីបញ្ចប់។

ប្រសិនបើអ្នកជួបប្រទះជាមួយនឹងហេតុការណ៍ដែលធ្វើឲ្យជីវិតរបស់អ្នកផ្លាស់ប្រែមួយប៉ព្រិចភ្នែកដោយសារតែមហន្តរាយ ឬការបាត់បង់អ្វីមួយ នោះអ្នកត្រូវតែធ្វើការសម្រេចចិត្តយ៉ាងច្បាស់លាស់អំពីអនាគតអ្នក។ ប៉ុន្តែអ្នកអាចមានអារម្មណ៍ថាអ្នកមិនទាន់រួចរាល់នៅឡើយក្នុងការសម្រេចចិត្តការនោះ!

នៅក្នុងពេលនោះ ទោះបីគំនិតរបស់អ្នកមិនទាន់ច្បាស់លាស់នៅឡើយក្ដី។ អ្នកអាចគិតថាអ្នកបានសម្រេចចិត្ត ហើយរំពេចនោះ អ្នកផ្លាស់ប្រែគំនិតរបស់អ្នក ។ អារម្មណ៍របស់អ្នកចាប់ផ្ដើមលេងល្បិចជាមួយអ្នក។ វាប្រែប្រួលចុះឡើង ការសម្រេចចិត្តនឹងពិបាកជាងពេលធម្មតាទៅទៀត។

ជាទូទៅការភ័ន្តច្រឡំ ការវង្វេងស្មារតីនិងការភ័យខ្លាចនៅជាមួយគ្នាជានិច្ច។ អ្នកអាចសួរសំណួរខ្លួនឯងដូចជា «តើខ្ញុំធ្វើយ៉ាងដូចម្ដេចជាមួយថវិការបស់ខ្ញុំ? តើ

អ្នកណានឹងថែទាំការទាំងនេះ ខ្ញុំមិនធ្លាប់ប្រើវាទេ?»

ពេលប្រឈមមុខជាមួយនឹងសំណួរមានបញ្ហាដូច្នេះ ខ្ញុំសូមណែនាំឲ្យអ្នកពិចារណាលើខគម្ពីរនេះពីកណ្ឌគម្ពីរហេប្រើរ។ វាតែងតែផ្ដល់ដល់ខ្ញុំនូវការកំសាន្ដចិត្តនិងក្ដីសង្ឃឹម ហើយខ្ញុំជឿថាវាក៏អាចលើកទឹកចិត្តដូចគ្នាដែរៈ

> *... ដ្បិតព្រះជាម្ចាស់មានព្រះបន្ទូលថាៈ «យើងនឹងមិនទុកអ្នកចោល ហើយក៏មិនបោះបង់អ្នកចោលដែរ»។*
>
> *ហេប្រឺ១៣:៥*

ពេលអ្នកមិនដឹងអ្វីត្រូវធ្វើ ឬ មិនដឹងពីអនាគតយ៉ាងដូចម្ដេច វាគឺជាការជួយសម្រាលទុក្ខដោយសារការស្គាល់ព្រះមួយអង្គដែលជ្រាប។ នៅក្នុងទំនុកតម្កើង ១៣៩:១៥-១៧ អ្នកនិពន្ធទំនុកតម្កើងបានអះអាងជាមួយយើងថា ព្រះបិតារបស់យើងដែលនៅស្ថានសួគ៌ ទ្រង់ជ្រាប យ៉ាងច្បាស់អំពីអតីត បច្ចុប្បន្ននិងអនាគតរបស់យើងៈ

> *នៅពេលទូលបង្គំកកើតឡើងក្នុងទីលាក់កំបាំង គឺនៅក្នុងផ្ទៃមាតា រូបកាយរបស់ទូលបង្គំមិនបានលាក់កំបាំងនឹងព្រះអង្គទេ។*
>
> *កាលទូលបង្គំមិនទាន់មានរូបរាងកាយនៅឡើយ ព្រះអង្គទតឃើញទូលបង្គំរួចស្រេចទៅហើយ ព្រះអង្គក៏បានកំណត់ចំនួនថ្ងៃនៃអាយុជីវិតរបស់ទូលបង្គំទុកក្នុងបញ្ជីរបស់ព្រះអង្គ មុននឹងថ្ងៃទាំងនោះមកដល់ទៅទៀត។*
>
> *ឱព្រះជាម្ចាស់អើយ ព្រះតម្រិះរបស់ព្រះអង្គជ្រៅជ្រះណាស់ហើយមានច្រើនឥតគណនាទៀតផង។*

ព្រះអង្គជា ជាអាល់ផា និងជាអូមេកា ជាដើមដំបូង និងជាចុងបង្អស់។ នៅក្នុងករណីនេះ ព្រះអង្គជាអ្វីគ្រប់យ៉ាងនៅក្នុងចន្លោះនោះផងដែរ។ ព្រះអង្គជ្រាប

ស្ថានភាពរបស់យើង នឹងដឹកហើយនាំយើង បើយើងទុកចិត្តព្រះឲ្យធ្វើការនោះ។

ព្រះបិតារបស់យើងនៅស្ថានសួគ៌ ជាធម្មតាប្រទានអ្វីៗដែលយើងត្រូវការនៅថ្ងៃណាមួយមិនខាន។ ព្រះគុណផ្តល់មកពីមួយថ្ងៃទៅមួយថ្ងៃ។ ដោយហេតុនេះហើយ វាពិបាកក្នុងការមើលវែងឆ្ងាយទៅកាន់អនាគត ហើយអត់មានអារម្មណ៍ភ័យខ្លាច។

ពេលយើងមើលទៅមុខ ជាញឹកញាប់យើងមានអារម្មណ៍ថា យើងមិនអាចប្រឈមមុខការលំបាកដែលអាចកើតឡើង។ តែយើងមើលទៅឯទុក្ខលំបាកនោះ ដោយអត់មើលពីព្រះគុណរបស់ព្រះដែលប្រទានមកលើយើង។

*ពេលយើងមកដល់ទីកន្លែងនោះ យើងនឹងឃើញព្រះគុណ។*

អស់ពេលរាប់ពាន់ឆ្នាំ នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងជំពូក២៣បានបំពេញផ្នែកកំសាន្តចិត្តដល់មនុស្សរាប់លាននាក់ដែលសោកសៅនិងមនុស្សដែលឯកា។ នៅពេលដែលមានការភ័ន្តច្រឡំ វង្វេងស្មារតីនិងមានការភ័យខ្លាច បានប្រើវាជាយុទ្ធថ្កាសម្រាប់ព្រលឹងរបស់អ្នកៈ

> *ព្រះអម្ចាស់ជាគង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វីសោះឡើយ។ ព្រះអង្គឲ្យខ្ញុំសំរាកនៅតាមវាលស្មៅខៀវខ្ចី ព្រះអង្គនាំខ្ញុំឆ្ពោះទៅកន្លែងស្ងាត់ នៅក្បែរមាត់ទឹក។*
>
> *ព្រះអង្គប្រទានឲ្យខ្ញុំមានកម្លាំងឡើងវិញ ព្រះអង្គនាំខ្ញុំដើរក្នុងផ្លូវដ៏សុចរិត ដោយយល់ដល់ព្រះកិត្តិនាមរបស់ព្រះអង្គ។*
>
> *ទោះបីទូលបង្គំដើរកាត់ជ្រលងភ្នំ នៃសេចក្តីស្លាប់ក៏ដោយ ក៏ទូលបង្គំមិនខ្លាចអ្វីសោះឡើយ ដ្បិតព្រះអង្គគង់នៅជាមួយទូលបង្គំ ព្រះអង្គការពារ និងរក្សាទូលបង្គំជានិច្ច។*
>
> *ព្រះអង្គរៀបចំពិធីជប់លៀងឲ្យទូលបង្គំ នៅមុខបច្ចាមិត្តរបស់ទូល*

*បង្គំព្រះអង្គបានចាក់ប្រេងលើទូលបង្គំ ដើម្បីលើកកិត្តិយសទូលបង្គំ ហើយព្រះអង្គបានបំពេញពែង ទូលបង្គំយ៉ាងហូរហៀរ។*

*ខ្ញុំដឹងជាក់ច្បាស់ណាស់ថា ព្រះអង្គនឹងប្រទានសុភមង្គលឲ្យទូលបង្គំ ហើយព្រះអង្គប្រណីសន្ដោសទូលបង្គំ យ៉ាងស្មោះស្ម័គ្រជារៀងរាល់ថ្ងៃអស់មួយជីវិត។ ដរាបណាខ្ញុំនៅមានជីវិត ខ្ញុំនឹងវិលត្រឡប់មកក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ជានិច្ច។*

*ទំនុកតម្កើង២៣:១-៦*

## ***ដំណាក់កាល៧ រោគសញ្ញានៃរូបកាយ***

វាលេចឲ្យឃើញជាញឹកញាប់ថា មនុស្សដែលសោកសៅចំពោះការស្លាប់ ឬការប៉ះទង្គិចយ៉ាងខ្លាំង ដោយសារការបាត់បង់ដែលចាប់ផ្ដើមមានបទពិសោធន៍ដោយសាររោគសញ្ញានៃរូបកាយ។ វាហាក់បីដូចជាច្រើនហួសពេកក្នុងការទ្រាំ ក្នុងការមានអារម្មណ៍មិនល្អខាងក្នុងចិត្ត ឆាប់រំជួលចិត្ត និងខាងរូបកាយ។

អារម្មណ៍មិនសប្បាយចិត្តអាចផ្ដល់មក នូវភាពស្មុគស្មាញយ៉ាងខ្លាំងនៅក្នុងរូបកាយ។ ភាពទន់ខ្សោយដែលមានរួចមកហើយ ធ្វើឲ្យមានភាពស្មុគស្មាញហួសកំរិតរបស់ពួកគេ។ ជាច្រើនដងលទ្ធផលនោះគឺការឈឺចាប់ខាងរូបកាយ ជំងឺឬរោគាផ្សេងៗ។

ការឈឺចាប់ផ្សេងៗនៅក្នុងក្បាល ឈឺក ឈឺខ្នង ឬឈឺក្រពះមិនមែនខុសពីធម្មតាទេ ពេលអ្នកស្ថិតនៅក្រោមភាពស្មុគស្មាញយ៉ាងខ្លាំងនោះ។ មានការមួយដែលអាចបន្ធូរភាពស្មុគស្មាញនោះគឺការហាត់ប្រាណខាងរូបកាយ។

នៅក្នុងពេលដែលមានភាពសោកសៅ គោលការណ៍សំខាន់ ជាញឹកញាប់នោះគឺគ្រាន់តែអង្គុយហើយ«គិត»(រំពឹងគិត)។ ទោះបីជាធម្មជាតិនេះល្អឥតខ្ចោះក្ដី គោលការណ៍នេះត្រូវតែយកឈ្នះវាដោយការបង្ខំយ៉ាងខ្លាំងនិងសកម្មភាពវិជ្ជមាន

ប្រសិនបើអ្នកកំពុងឆ្លងកាត់ដំណើរការនៃភាពសោកសៅ ខ្ញុំសូមណែនាំថា យ៉ាងហោចណាស់អ្នកត្រូវដើរឲ្យបានឆ្ងាយ។ ប្រសិនបើអ្នកដើររួចហើយ ខ្ញុំសូមណែនាំដូច្នេះចូរខំធ្វើការហាត់ប្រាណឲ្យបានច្រើនថែមទៀត។

*ចូរចងចាំៈ អ្នកកំពុងតែមានទុកព្រួយស្រាប់ផង ដូច្នេះកុំធ្វើវាជ្រុលពេក។*

តែវាបានបង្ហាញថា ការហាត់ប្រាណ ត្រូវតែធ្វើឲ្យកាត់បន្ថយភាពស្មុគស្មាញខាងផ្លូវចិត្ត អារម្មណ៍និងខាងរូបកាយ ហើយសម្រាកការតឹងសាច់ដុំ។

ការបាត់បង់ចំណង់ចិត្តជាមួយនឹងអាហារ ពិតណាស់ វាគឺជាការមួយដែលសំខាន់ផងដែរ នៅពេលសោកសៅ យើងអាចយល់បានពីការនេះ។ យ៉ាងណាក្តីវាអាចបង្កឲ្យគ្រោះថ្នាក់ចំពោះសុខភាពរបស់អ្នក នៅពេលដែលអ្នកឈប់មិនញ៉ាំយូរពេក។ បើអ្នកអត់អាចញ៉ាំច្រើនបាន ចូរព្យាយាមញ៉ាំចំណីអាហារដែលល្អមានគុណភាព។

ទោះបីជាវាអាចមានការលំបាក ចូរឲ្យមានភាពច្បាស់លាស់សម្រាប់ការគេង។ ភាពអស់កម្លាំង និងភាពទន់ខ្សោយ ស្តមស្តាំង ហើយការមានភាពស្មុគស្មាញខ្លាំងពេកខាងរូបកាយគឺកំពុងអញ្ជើញរោគា និង ជម្ងឺមកដាក់ខ្លួនហើយ។ ហេតុដូច្នេះហើយចាំបាច់ត្រូវធ្វើលំហាត់ប្រាណខាងរូបកាយនេះ។ ការចិញ្ចឹមនិងការសម្រាកឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន នឹងជួយគំនិត ហើយរូបកាយធ្វើឲ្យ

មានសុខភាពល្អក្នុងកំឡុងពេលស្មុគស្មាញទាំងនេះ។

ខ្ញុំជឿថា វាពិតជាសំខាន់ណាស់ នៅពេលដែលភាពសោកសៅនិងភាពឯកាក្នុងការដឹងថា ការអ្វីដែលអ្នកមានអារម្មណ៍និងនៅក្នុងដំណាក់កាលនៃការសោកសៅផ្សេងៗដែលអ្នកបានជួបប្រទះគឺគ្រប់យ៉ាងហាក់បីដូចជាធម្មតា ហើយត្រូវតែធ្វើវាតាមលំដាប់លំដោយដើម្បីប្រឡប់ទៅរកអារម្មណ៍ដែលមានផាសុកភាពវិញ។

ដូចដែលយើងបានចំណាំ ការទប់អារម្មណ៍និងមនោសញ្ចេតនាវាជាប្រព័ន្ធដ៏

ពិបាកណាស់។ បើអ្នកបញ្ចេញវាមិនបានត្រឹមត្រូវទេ វាអាចធ្វើឲ្យមានការខូចខាតជាច្រើន។

*ចូរចងចាំ: ពេលអារម្មណ៍អវិជ្ជមានត្រូវបានទប់ស្កាត់ នៅទីបញ្ចប់វានឹងចេញមកតាមផ្លូវផ្សេង។*

ជាញឹកញាប់យើងគិតថា យើងលាក់បាំងអ្វីៗនៅខាងក្នុង តែវាចេញមកខាងក្រៅតាមរយៈឥរិយាបថរបស់យើងនិងការសន្ទនារបស់យើង ទោះបីជានៅក្នុងរូបកាយខាងសាច់ឈាមនេះក្តី។

នៅក្នុងការដោះស្រាយ ជាមួយប្រាំពីរដំណាក់កាលនៃដំណើរការរបស់ភាពសោកសៅ គន្លឹះគឺ*ការមានតុល្យភាព* ។

# ៤

# ការជាសះស្បើយពី
# មហន្តរាយនិងការបាត់បង់

*«ព្រះវិញ្ញាណព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ពីព្រោះទ្រង់បានចាក់ប្រេងតាំងខ្ញុំ ឲ្យផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ ទ្រង់បានចាត់ខ្ញុំឲ្យមកដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង ហើយប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់ពួកឈ្លើយ និងសេចក្តីភ្លឺឡើងវិញដល់មនុស្សខ្វាក់ ហើយឲ្យដោះមនុស្ស ដែលត្រូវគេជិះជាន់ឲ្យរួច»*

*លូកា ៤:១៨*

## ៤

# ការជាសះស្បើយពី
# គ្រោះមហន្តរាយនិងការបាត់បង់

អ្វីក៏ដោយ ដែលបានកើតឡើងធ្វើឲ្យអ្នកមានការឈឺចាប់ ដោយសារភាពសោកសៅនិងភាពឯកា មានការមួយដែលអ្នកត្រូវតែដឹងច្បាស់គឺៈ អ្នកនឹងទទួលការដឹកនាំពីព្រះជាម្ចាស់នៅក្នុងការជាសះស្បើយមកវិញរបស់អ្នក។ ព្រះអង្គពិតជាឲ្យអ្នកដឹងនៅពេលអ្នកបានផ្លាស់ប្រែបួសហេតុ ឬការចេញផុតពីតុល្យភាព ប្រសិនបើអ្នកព្រមស្តាប់ព្រះវិញ្ញាណដ៏វិសុទ្ធ។

វាមិនអាចទៅរួចទេ ក្នុងការរៀបចំចំនួននៃពេលវេលាច្បាស់លាស់ ដែលវាអាចដំណើរការបានតាមដំណើរការនៃភាពសោកសៅនោះ។ មនុស្សម្នាក់ៗបានជួបនិងស្ថានភាពផ្សេងៗខុសពីគ្នា។ ប៉ុន្តែ ទោះបីជាយ៉ាងណាក្តី មិនថាវាវែងប៉ុណ្ណាទេ វានឹងដល់ពេលមួយ ដែលព្រះអម្ចាស់នឹងមានបន្ទូលថា «ដល់ពេលហើយ ត្រូវក្រោកឈរឡើងហើយធ្វើការតទៅទៀត។ អ្នកត្រូវបោះបង់ចោលអតីតកាលរបស់អ្នកហើយបញ្ចប់មេរៀនដែលខ្ញុំបានដាក់នៅក្នុងជីវិតរបស់អ្នក។ *«ខ្ញុំនឹងមិនទុកអ្នកចោល ហើយក៏មិនបោះបង់អ្នកចោលដែរ ដូច្នេះចូរមានចិត្តក្លាហាននិងមានកម្លាំងឡើង! ចូរអង់អាចហើយធ្វើដំណើរទៅមុខទៀត!»*

### *ករណីនីមួយៗគឺខុសគ្នា*

ជាទូទៅ ប្រាំមួយខែដំបូងនៅក្នុងដំណើរការនៃភាពសោកសៅគឺជាពេលដ៏លំបាកបំផុត។ វាអាចវែងបន្តិច ឬខ្លីបន្តិចអាស្រ័យលើស្ថានភាព។ មានកត្តាជាច្រើនចូលរួមចំណែកដែលត្រូវនឹងស្ថានភាពនិមួយៗនោះ:

១. ការបាត់បង់ភ្លាមៗ: បើសិនជាមនុស្សម្នាក់ឈឺក្នុងរយៈពេលវែង គ្រួសារ

លែងមានទឹកចិត្ត និងមានអារម្មណ៍រៀបចំសម្រាប់ការស្លាប់របស់អ្នកដែលពួកគេស្រឡាញ់។ ប្រសិនបើបាត់បង់ភ្លាមៗ ឬការបាត់បង់ដែលនឹកស្មានមិនដល់ ការបាត់បង់អាចមានរបួសច្រើននិងមានការលំបាកច្រើនក្នុងការសម្រាប់ខ្លួនតាម។

២. វត្តមាននិងអវត្តមាននៃសមាជិកគាំទ្រ។ ប្រសិនបើស្វាមី ឬភរិយាស្លាប់ឧទារណ៍ វានឹងនាំឲ្យមានការផ្លាស់ប្តូរ ប្រសិនបើនៅមានកូនៗដើម្បីកំសាន្តចិត្តម្តាយ ឬឪពុកដែលនៅរស់។ បើសិនបាត់បង់កូនវិញ មានកូនមួយទៀតជួយបំពេញកន្លែងដែលអត់មាននោះនៅក្នុងផ្ទះ ជំនួសកូនដែលស្លាប់ទៅហើយ។

៣. គុណភាពនៃទំនាក់ទំនងរវាងការមានអ្នកស្លាប់ចោលនិងការបាត់បង់អ្នកដែលជាទីស្រឡាញ់។ ប្រសិនបើទំនាក់ទំនងស៊ីជម្រៅ ស្រឡាញ់ខ្លាំង ដំណើរការនៃភាពសោកសៅនឹងចំណាយពេលយូរ ហើយពិបាកជាងទំនាក់ទំនងដែលមិនសូវស៊ីជម្រៅនៅឡើយ។

៤. បុគ្គលិកលក្ខណៈរបស់បុគ្គលដែលនៅរស់។ នេះគឺជាសេចក្តីពិតដ៏ពិសេសមួយនៃការស្លាប់របស់ស្វាមីភរិយាមួយ។ មានអ្នកខ្លះនៅក្នុងចំណុះរបស់អ្នកមួយទៀតហើយពួកគេត្រូវតែខំប្រឹងប្រែងដើម្បីទទួលការដឹកនាំ គ្រប់គ្រង និងបន្តដំណើរនៅក្នុងជីវិត។

៥. ការមានទំនាក់ទំនងស៊ីជម្រៅរវាងមនុស្សសោកសៅនិងព្រះអម្ចាស់ព្រះយេស៊ូគ្រិស្ត។ នេះគឺជាកត្តាសំខាន់។ មហន្តរាយ ឬការបាត់បង់ជាញឹកញាប់ធ្វើឲ្យមនុស្សស្វែងរកទំនាក់ទំនងជាមួយព្រះអម្ចាស់ ប្រាកដណាស់ នឹងនាំមកនូវការកំសាន្តចិត្ត។ តែចំពោះមនុស្សដែលបានស្គាល់ទ្រង់រួចមកហើយ «និងអំណាចនៃការរស់ឡើងវិញរបស់ព្រះអង្គ»តែប៉ុណ្ណោះ(ភីលីព៣:១០)នឹងនាំឲ្យមានការប្រោសឲ្យជាកាន់តែឆាប់ឡើងជាងម្នាក់ដែលមានអត់មានទំនាក់ទំនងស្គាល់ព្រះអម្ចាស់ ឬអស់អ្នកដែលចាប់ផ្តើមមានទំនាក់ទំនងសើរៗជាមួយព្រះអង្គ។

ដូចជាអ្វីដែលខ្ញុំបានពន្យល់ពីចំណុចផ្សេងៗ នៃដំណាក់កាលដែលតម្រូវសំ

រាប់ការជាសះស្បើយពីមហន្តរាយនិងការបាត់បង់ ខ្ញុំចង់ចែកចាយជាមួយអ្នក ករណីពិតៗពីរដែលខ្ញុំបានដឹង។

***ករណីទីមួយ:***

ខ្ញុំស្គាល់ស្ត្រីម្នាក់ជាអ្នកជឿព្រះរឹងមាំ នាងបានចូលរួមជាមួយកិច្ចការបំរើព្រះ អស់ពេលជាច្រើនឆ្នាំ។

នាងនិងស្វាមីរបស់នាងបានរៀបការអស់រយៈពេលម្ភៃឆ្នាំ ឬច្រើនជាងនោះ។ ទោះបីជាគាត់អះអាងជាគ្រិស្តបរិស័ទក្តី គាត់អត់បានបង្ហាញពីផលផ្លែនៃទំនាក់ទំនងរបស់គាត់ជាមួយព្រះអម្ចាស់ឡើយ។ គាត់ពិតជាមិនបានប្រព្រឹត្តជាមួយភរិយារបស់គាត់បានត្រឹមត្រូវទេ ហើយគាត់បានធ្វើការនោះអស់ពេលជាច្រើនឆ្នាំកន្លងមកហើយ។

ការងាររបស់បុរសម្នាក់នេះ សំខាន់ជាងអ្វីៗផ្សេងទៀតនៅក្នុងជីវិតរបស់គាត់។ គាត់អាត្មានិយម គិតតែពីខ្លួនឯង ហើយពេលខ្លះឥរិយាបថរបស់គាត់ឃោរឃៅយ៉ាងខ្លាំងចំពោះភរិយារបស់គាត់និងសេចក្តីត្រូវការរបស់នាង។

ស្ត្រីរូបនេះបានបន្តក្នុងការដើរជាមួយព្រះ ព្រះជាម្ចាស់បានប្រទានដល់នាងនូវកិច្ចការអធិស្ឋានពិសេសមួយសម្រាប់ស្វាមីរបស់នាង បានដាស់តឿននាងថា បើសិនជាគាត់មិនបានចុះចូលចំពោះព្រះអង្គ នៅក្នុងរយៈពេលប្រាំមួយខែទេ គាត់នឹងត្រូវស្លាប់។

ស្ត្រីរូបនេះបានអធិស្ឋាន ហើយបុរសម្នាក់នោះនៅតែបដិសេធមិនព្រមដោះស្រាយជាមួយព្រះអង្គទេ។ ដោយសារការមិនស្តាប់បង្គាប់ គាត់បានបើកទ្វារឲ្យសាតាំងធ្វើឲ្យគាត់មានអាយុខ្លី។ ជាលទ្ធផល បុរសនោះបានស្លាប់ដោយសាររោគគាំងបេះដូងភ្លាមៗ។

ទោះបីជាការបាត់បង់នោះ ពិបាកសម្រាប់ភរិយាក្តី វាមិនពិបាកដូចមនុស្ស

ម្នាក់ដែលមានសេចក្ដីសុខដោយសារមានទំនាក់ទំនងល្អជាមួយស្វាមីរបស់នាងទេ។ ព្រះបានដាស់តឿននាង ដែលបានធ្វើឲ្យនាងរួចរាល់ជាមុន។

ខ្ញុំសំគាល់ឃើញថា ពេលវេលានៃការជាសះស្បើយរបស់នាងវាពិតជាខ្លីខ្លាំងមែនទែន។ មានបញ្ហាជាច្រើននៅក្នុងជីវិតរបស់នាងដែលត្រូវតែដោះស្រាយ ជាមួយបញ្ហាថវិកា និងបញ្ហាផ្សេងៗ តែ សរុបមក ក្នុងរយៈពេលដ៏ខ្លី នាងអាចកែតម្រូវហើយធ្វើឲ្យជីវិតរបស់នាងបន្តទៅមុខទៀតបាន។

***ករណីទី ពីរ:***

ការមួយនេះ ជាប់ទាក់ទងជាមួយម្ដាយមីងរបស់ខ្ញុំ។ នាងនិងពូរបស់ខ្ញុំបានស្គាល់គ្នាតាំងតែគាត់នៅក្មេងមកម្ល៉េះ ហើយនាងបានរៀបការនៅពេលដែលគាត់មានអាយុដប់ប្រាំឆ្នាំ ហើយពូខ្ញុំចាស់ជាងតែពីរបីឆ្នាំទេ។ នាងមិនដែលមានមិត្តប្រុសផ្សេងទៀតទេ សូម្បីតែណាត់ជួបជាមួយប្រុសផ្សេងក៏គ្មានដែរ។

អ្នកទាំងពីរនាក់នេះអត់អាចមានកូនទេ ពួកគេបានធ្វើការជិតស្និទ្ធជាមួយគ្នាជាពិសេស។ ពួកគេធ្វើការ នៅហាងនំប៉័ងជាមួយគ្នា អស់រយៈពេលជាងសាមសិបឆ្នាំ។ ពួកគេធ្វើអ្វីគ្រប់យ៉ាងជាមួយគ្នា បំរើព្រះជាដៃគូមួយគ្នានៅក្នុងព័ន្ធកិច្ចរបស់ព្រះអម្ចាស់។

ពួកគេទាំងពីរនាក់ជួបជាមួយនឹងជំងឺជាច្រើននៅក្នុងជីវិតរបស់ពួកគេ ហើយបានចំណាយពេលយ៉ាងច្រើនក្នុងការថែទាំគ្នាទៅវិញទៅមក ធ្វើឲ្យពួកគេស្រឡាញ់ គ្នាកាន់តែច្រើនឡើង។

អ្នកទាំងពីរនេះបានជាប់ទាក់ទងក្នុងជីវិតរបស់គ្នាទៅវិញទៅមក។ ពួកគេស៊ុចង្វាក់គ្នាដូចដៃនិងស្រោមដៃអញ្ចឹង។ ពួកគេមានអំណរសប្បាយជាមួយគ្នាៈ ស្វូចត្រី ចំអិនម្ហូបអាហារ ទៅព្រះវិហារ។ល។

ទោះបីជាគាត់ធ្លាក់ខ្លួនឈឺជាច្រើនឆ្នាំហើយក្ដី ពេលដែលពូរបស់ខ្ញុំបានស្លាប់ទៅ ការបាត់បង់គាត់ពិតជាពិបាកសម្រាប់ម្ដាយមីងរបស់ខ្ញុំណាស់។ នៅពេល

ដែលម្តាយមីងរបស់ខ្ញុំស្ថិតជើង ដោយសារជម្ងឺសន្លាក់ឆ្អឹងនៅក្នុងជង្គង់របស់នាង តែ អត់អាចចេញសំបុត្រឲ្យវះកាត់ជង្គង់ដោយសារនាងមានជម្ងឺបេះដូង។ ហេតុដូច្នេះហើយមិនថាតិចឬច្រើន នាងនៅតែផ្ទះពីរបីឆ្នាំបន្ទាប់ពីពូរបស់ខ្ញុំបានស្លាប់ទៅ ដែលធ្វើឲ្យរបួសរបស់នាងកាន់តែខ្លាំងឡើង។

ដោយហេតុនេះហើយដើម្បីជួយសម្រាលស្ថានភាពទាំងនេះ គឺត្រូវចំណាយពេលរាប់ឆ្នាំដើម្បីឲ្យរបួសរបស់នាងបានជាសះស្បើយឡើងវិញ។

## *ការថ្វាយគឺជារឿងធម្មតា ការរស់នៅក្នុងភាពសោកសៅមិនមែនជារឿងធម្មតាទេ*

តាមរយៈពីរករណីនេះ យើងអាចមើលឃើញបានយ៉ាងងាយអំពីព្រឹត្តការណ៍ដូចគ្នា អាចជះឥទ្ធិពលដល់មនុស្សផ្សេងៗពីគ្នា។ ទោះបីជាអាចទៅរួចក្នុងការធ្វើឲ្យការទាយទុកជាមុនអំពីដំណើរការណ៍ នៃភាពសោកសៅនឹងត្រូវកន្លងផុតពិតប្រាកដ ដំណើរការណ៍នោះជាញឹកញាប់ហាក់បីដូចជាត្រូវឆ្លងកាត់វា។

ដំណើរការណ៍នេះអាចធ្វើដោយសន្សឹមៗហើយពិបាកក្នុងការកត់សំគាល់នៅពេលដំបូង តែវាអាចនឹងបង្ហាញឲ្យឃើញ *យ៉ាងច្បាស់នៅពេលណាមួយ។*

ដូចជាស្នាមរបួសដែលបានជាសះ អាចលែងមានភាពឈឺចាប់យូរណាស់មកហើយ តែការជាសះស្បើយទាំងស្រុងនោះតម្រូវឲ្យជាសន្សឹមៗជារៀងរាល់ថ្ងៃ។ ពេលរបួសខាងរូបកាយបដិសេធការជាសះស្បើយ វាគឺជាការចង្អុលបង្ហាញថាមានការឆ្លងរោគ ហើយត្រូវតែដោះស្រាយជាមួយវា។ ខ្ញុំជឿដូចគ្នាដែរថា វាពិតជាមានរបួសខាងអារម្មណ៍មែន។

អារម្មណ៍គឺជាផ្នែកមួយនៅខាងក្នុងយើងដែលគួរតែជាសះស្បើយដូចរូបកាយរបស់យើង។ ព្រះអង្គប្រទានអារម្មណ៍ដល់យើង ដូចព្រះអង្គប្រទានរូបកាយខាងរូបសាច់នេះដែរ។ ព្រះអង្គផ្តល់ការស្តារឡើងវិញនៃអារម្មណ៍របស់យើងក្នុងព្រះយេស៊ូគ្រិស្ត ដូចដែលព្រះអង្គបានផ្តល់ការប្រោសឲ្យជាខាងរូបកាយនៅក្នុងទ្រង់ដែរ។ ការទាំងពីរនេះគឺសម្រាប់យើងក្នុងនាមជាអ្នកជឿ។

កុំជឿការកុហករបស់សាតាំង។ វាព្យាយាមប្រាប់អ្នកថា អ្នកមិនអាចរួចផុតពីការឈឺចាប់បានទេផ្នែកផ្លូវចិត្តរបស់អ្នកក៏មិនអាចជាបានដែរ។នៅក្នុងកំឡុងពេលដែលអ្នកកំពុងតែបាត់បង់មនុស្សម្នាក់ឬបាត់បង់អ្វីមួយ វាមិនមែនមានន័យថា អ្នកត្រូវទទួលរងការឈឺចាប់រហូតជាមួយនឹងការសោកស្តាយនិងភាពឯកានោះទេ។

សូមទុកឱកាសឲ្យល្មម ភាពសោកសៅនឹងរលាយបង់ហើយអ្នកអាចផ្លាស់ប្តូរទៅរដូវកាលថ្មីមួយនៃជីវិត។ ប្រសិនបើការផ្លាស់ប្តូរនេះមិនបានលេចមកឲ្យឃើញនៅក្នុងពេលកំណត់ទេ វាបង្ហាញថា មានបញ្ហានៅកន្លែងណាមួយហើយៈ ដូចជាការមានឥរិយាបថនៃចិត្តគំនិតមិនត្រឹមត្រូវ ការបដិសេធន៍មិនព្រមប្រឈមមុខនឹងការពិត ឬប្រហែលបច្ចុប្បន្នមិនប្រក្រតីនិងការភ័យខ្លាចដែលអត់មានហេតុផល។

មិនថាឫសគល់នៃបញ្ហាជាអ្វីទេ ព្រះអង្គនឹងបើកសំដែងឲ្យអ្នកដឹង បើសិនជាអ្នកចំណាយពេលអានព្រះបន្ទូលទ្រង់ និង ស្វែងរកព្រះអង្គតាមរយៈការអធិស្ឋាននិងការសញ្ជឹងគិត។

*ចូរចាំនៅក្នុងចិត្តថា ការសោកសៅគឺជារឿងធម្មតា តែនឹងក្លាយជាមិនធម្មតាបើរស់នៅជាមួយវិញ្ញាណនៃការសោកសៅនោះ។*

## ***ការយកឈ្នះលើភាពសោកសៅនិងភាពឯកា***

ខ្ញុំចង់ចែកចាយជាមួយអ្នក ការសំខាន់ពីរចំណុចដើម្បីជួយអ្នកឲ្យអាចយកឈ្នះលើភាពសោកសៅនិងភាពឯកា ហើយអាចជាសះស្បើយផ្នែកខាងអារម្មណ៍ថែមទៀតផងៈ

### ***១. ចូរដឹងថាព្រះអង្គគង់ជាមួយអ្នកគ្រប់ពេល***

នៅក្នុងព្រះគម្ពីរម៉ាថាយ២៨:២០ ព្រះយេស៊ូមានបន្ទូល «... ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប។ អាម៉ែន»។ ហើយនៅក្នុងហេប្រឺ ១៣:៥ យើងអានឃើញថា ព្រះអង្គបានសន្យាថា «ខ្ញុំនឹងមិនទុកអ្នក

ចោល ហើយក៏មិនបោះបង់អ្នកចោលដែរ»។

ជាញឹកញាប់ភាពសោកសៅនិងភាពឯកា អាចនាំទៅរកការភ័យខ្លាច ដែលអាចធ្វើឲ្យមានមានសំណួរដែលមិនអាចឆ្លើយបានជាច្រើនដូចជាៈ ចុះបើសិនជាខ្ញុំឈឺហើយអត់អាចធ្វើការបានតើអ្នកណាអាចផ្គត់ផ្គង់ដល់ខ្ញុំ?»«ចុះបើសិនជាខ្ញុំនៅម្នាក់ឯងអស់មួយជីវិតរបស់ខ្ញុំ?» «ចុះបើសិនការឈឺចាប់នេះមិនអាចចេញពីខ្ញុំ?» «ចុះបើសិនជាបញ្ហាកើតឡើងហើយ ខ្ញុំអត់អាចដោះស្រាយដោយខ្លួនឯងបាន?»

«ចុះប្រសិន... ចុះប្រសិន... ចុះប្រសិន...» សំណួរទាំងនេះអាចបន្តទៅមុខជាច្រើនទៀតដែលគ្មានទីបញ្ចប់។

អ្នកមិនអាចឆ្លើយចំពោះសំណួរដែលនិយាយថា «ចុះបើសិនជា...» នៅក្នុងជីវិតបានទេ។ តែនៅពេលដែលអ្នកបានស្គាល់ថាព្រះយេស៊ូគង់ជាមួយអ្នក អ្នកអាចដឹងយ៉ាងប្រាកដថា ព្រះអង្គមានគ្រប់ទាំងចម្លើយដែលអ្នកត្រូវការ។

ចូរពិចារណាលើខគម្ពីរទាំងនេះ សូមឲ្យបទគម្ពីរទាំងនេះបានកំសាន្តចិត្តអ្នកៈ

*ឯព្រះដែលគង់នៅក្នុងទីលំនៅបរិសុទ្ធ ទ្រង់ជាឪពុកដល់ពួកកំព្រានិងជាចៅក្រមដល់ពួកមេម៉ាយ។*

*ព្រះទ្រង់ប្រោសមនុស្សត្រមោចឲ្យបែកជាគ្រួសារឡើង ទ្រង់នាំពួកឈ្លើយឲ្យចេញមកឯសេចក្តីចំរើនតែពួករឹងចចេសត្រូវអាស្រ័យនៅ ស្រុកហួតហែងវិញ។*

*ទំនុកតម្កើង៦៨:៥-៦*

*បើកាលណាឪពុកម្តាយលះចោលទូលបង្គំ នោះព្រះយេហូវ៉ាទ្រង់នឹងទទួលទូលបង្គំទុកវិញ។*

*ទំនុកតម្កើង២៧:១០*

*កុំឲ្យខ្លាចឲ្យសោះ ដ្បិតឯងនឹងមិនដែលត្រូវខ្មាសឡើយ ក៏កុំឲ្យរង្កៀសចិត្តដែរ ពីព្រោះឯងនឹងមិនដែលត្រូវមានសេចក្ដីខ្មាសទេ ឯងនឹងភ្លេចសេចក្ដីខ្មាសដែលឯងមានពីកាលនៅវ័យក្មេង ហើយឯងនឹងមិននឹកចាំពីសេចក្ដីដែលគេត្មះតិះដៀល ពីកាលនៅមេម៉ាយតទៅទៀតដែរ។*

*ដ្បិតព្រះដែលបង្កើតឯងមក ទ្រង់ជាប្ដីរបស់ឯងហើយ ព្រះនាមទ្រង់ គឺយេហូវ៉ានៃពួកពលបរិវារ ហើយព្រះដ៏ប្រោសលោះឯង គឺជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល គេនឹងហៅទ្រង់ថា ជាព្រះនៃលោកីយ៍ទាំងមូល។*

*អេសាយ៥៤:៤-៥*

*ទ្រង់ត្រូវគេមើលងាយ ហើយត្រូវមនុស្សបោះបង់ចោល ទ្រង់ជាមនុស្សទូទុក្ខ ហើយក៏ធ្លាប់ស្គាល់សេចក្ដីឈឺចាប់ ទ្រង់ត្រូវគេមើលងាយ ដូចជាអ្នកណាដែលមនុស្សគេចមុខចេញ ហើយយើងរាល់គ្នាមិនបានរាប់អានទ្រង់សោះ។*

*ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្ដីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្ដីទុក្ខព្រួយរបស់យើងពិត ប៉ុន្តែយើងរាល់គ្នាបានរាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរងវេទនា*

*តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់*

*អេសាយ៥៣:៣-៥*

ជម្ងឺរោគាក៏អាចនាំឲ្យមានភាពសោកសៅនឹងភាពឯកាផងដែរ។ ពេលយើងឈឺចាប់ហើយនិងការលំបាក នឹងហូរមកលើរូបកាយរបស់យើង យើងចង់ឲ្យអ្នកណាម្នាក់យល់ពីអារម្មណ៍មិនល្អដែលយើងមាន។ ទោះបីជាគ្រួសាររបស់យើងនិងមិត្តសម្លាញ់របស់យើងចង់ឲ្យពួកគេយល់ចិត្តយើងឲ្យបានច្រើនបំផុត យើងនៅតែឃើញថាខ្លួនយើងមានតែម្នាក់ឯងនៅក្នុងការឈឺចាប់របស់យើង។

ការមានជម្ងឺយូរពេកកាន់តែធ្វើឲ្យអាក្រក់ថែមទៀត ព្រោះមួយរយៈក្រោយមកយើងឃើញថា អ្នកដទៃអត់ចង់ឮពីអារម្មណ៍មិនល្អដែលយើងមាននោះទេ។ វាមិនគ្រាន់តែអត់បានលើកទឹកចិត្តពួកគេ តែវាក៏អត់បានជួយឲ្យយើងបានរីកចម្រើនដែរ ប្រសិនបើយើងនៅតែបន្តនិយាយតែអំពីទុក្ខលំបាករបស់យើងនោះ។

ពេលដែលអ្នកមានជម្ងឺ អ្នកនឹងមានសំណួរដូចគ្នាដែរ ពេលដែលអ្នកជួបប្រទះជាមួយមហន្តរាយ ឬ ការបាត់បង់៖ ចុះបើអត់ជា... តើអ្នកណាមើលថែខ្ញុំទេ? «ចុះបើ ខ្ញុំអត់ធ្វើអ្វីដែលខ្ញុំធ្លាប់ធ្វើ?» «ចុះបើខ្ញុំអត់អាចប្រឡប់ទៅធ្វើការវិញបាន តើអ្នកណានឹងផ្គត់ផ្គង់ខ្ញុំនិងគ្រួសារខ្ញុំ?» «ចុះបើ ខ្ញុំត្រូវតែរស់នៅជាមួយនឹងការឈឺចាប់បែបនេះអត់មួយជីវិតរបស់ខ្ញុំ?»

នៅក្នុងជម្ងឺ អ្នកត្រូវតែអនុវត្តន៍គោលការណ៍ដូចគ្នាដែលយើងបានពិភាក្សានៅក្នុងការពិចារណារបស់យើងអំពីភាពសោកសៅនិងភាពឯកា។ អ្នកត្រូវតែដឹងថាព្រះអង្គគឺជាព្រះដែលប្រោសអ្នកឲ្យជា ហើយជឿថា អំណាចរបស់ព្រះអង្គធ្វើការនៅក្នុងរូបកាយរបស់អ្នកដើម្បីប្រោសនិងស្តារអ្នកឡើងវិញ។

ចូរចងចាំថា «ជ័យជំនះបានបំបាត់មច្ចុរាជចោលហើយ!»(១កូរិន.១៥:៥៤) ហើយព្រះអង្គមានបន្ទូលទៀតថា«យើងគឺជាព្រះដែលប្រោសអ្នក»(និក្ខ១៥:២៥):

សូមចំណាយពេលឲ្យបានច្រើនជាមួយព្រះអម្ចាស់ហើយអនុញ្ញាតឲ្យជីវិតរស់ឡើងវិញរបស់ព្រះអង្គដែលនៅក្នុងអ្នក ក្នុងនាមជាអ្នកជឿបានបំរើដល់សេចក្តីត្រូវការខាងរូបកាយរបស់អ្នក។ ពេលអ្នកធ្វើដូច្នេះ ចូរពិចារណាព្រះបន្ទូលនៅក្នុងបទ

គម្ពីរទាំងនេះ:

*តើឯងមិនបានដឹង តើមិនបានឮទេឬអី ថាព្រះដ៏គង់នៅអស់កល្ប ជានិច្ច គឺព្រះយេហូវ៉ា ជាព្រះដែលបានបង្កើតផែនដី រហូតដល់ចុងបំផុត ទ្រង់មិនដែលល្វើយឡើយ ក៏មិនដែលអស់កំឡាំងផង គ្មានអ្នកណា អាចស្ទង់យល់យោបល់របស់ទ្រង់បានទេ។*

*ទ្រង់រមែងចំរើនកំឡាំង ដល់អ្នកដែលល្វើយ ហើយចំណែកអ្នក ដែលគ្មានកំឡាំងសោះ នោះទ្រង់ក៏ប្រទានឲ្យ។*

*ទោះទាំងពួកជំទង់ គេនឹងល្វើយហើយនឿយហត់ទៅបាន ពួកកំលោះក៏នឹងដួលជ្រលាកបានផង។*

*តែអស់អ្នកណាដែលសង្ឃឹមដល់ព្រះយេហូវ៉ាវិញ នោះនឹងមានកំឡាំងចំរើនជានិច្ច គេនឹងហើរឡើងទៅលើដោយស្លាប ដូចជាឥន្ទ្រី គេនឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ។*

*អេសាយ ៤០:២៨-៣១*

*ឱព្រលឹងអញអើយចូរសរសើរដល់ព្រះយេហូវ៉ាហើយគ្រប់ទាំងអស់ ដែលរួមនៅក្នុងខ្លួនអញចូរសរសើរដល់ព្រះនាមបរិសុទ្ធនៃទ្រង់ដែរ។*

*ព្រលឹងអញអើយ ចូរសរសើរដល់ព្រះយេហូវ៉ាចុះហើយកុំឲ្យភ្លេច បណ្តាព្រះគុណណាមួយរបស់ទ្រង់ឡើយ។*

*ដែលទ្រង់អត់ទោសចំពោះអស់ទាំងការទុច្ចរិតរបស់ឯងទ្រង់ ប្រោសជំងឺ ទាំងប៉ុន្មានរបស់ឯងឲ្យជា។*

*ក៏ជួយជីវិតឯងឲ្យរួចពីរណ្តៅហើយយកសេចក្តីសប្បុរស និងសេចក្តីមេត្តាករុណាបំពាក់ជាមកុដឲ្យឯងវិញ។*

*ព្រមទាំងប្រោសប្រទានឲ្យសំបកកាយនៃឯងបានស្កប់ស្កល់ដោយរបស់ល្អប្រយោជន៍ឲ្យវ័យក្មេងឯង បានកែឡើងជាថ្មី ដូចជាឥន្ទ្រីសូមសរសើរតម្កើងព្រះអម្ចាស់! ខ្ញុំសូមសរសើរតម្កើងព្រះនាមដ៏វិសុទ្ធ របស់ព្រះអង្គអស់ពីដួងចិត្ត!*

*ទំនុកតម្កើង១០៣:១-៥*

ម្តងទៀត ចូរដឹងថាអ្នកមិននៅម្នាក់ឯងទេ។ ព្រះអម្ចាស់គង់នៅជាមួយអ្នក។ ព្រះអង្គជ្រាបពីអ្វីដែលអ្នកបានឆ្លងកាត់ ហើយទ្រង់បានសន្យាថានឹងគង់ជាមួយអ្នកក្នុងគ្រប់ទាំងទុក្ខលំបាកនៅក្នុងជីវិតរបស់អ្នក។ ពេលអ្នកមាន«អារម្មណ៍» ថានៅឯកាបំផុតនិងថាត្រូវគេបោះបង់ចោល ចូរបើកមាត់ដោយជំនឿ ហើយនិយាយឲ្យខ្លាំងៗថា «*ខ្ញុំមិននៅម្នាក់ឯងទេ* ព្រោះព្រះអង្គគង់ជាមួយខ្ញុំ!»

អំឡុងពេលពេលអ្នកកំពុងរងចាំសំរាប់ការប្រោសឲ្យជាចំពោះខ្លួនអ្នក បានបង្ហាញឲ្យឃើញឡើង ចូរប្រកាសការនេះឲ្យឮៈ «អំណាចនៃការប្រោសឲ្យជារបស់ព្រះកំពុងធ្វើការក្នុងខ្ញុំនៅពេលនេះ»។

សូមអានហើយប្រកាសបទគម្ពីរនេះផងដែរ ដែលអះអាងអំពីអំណាចនិងវត្តមានរបស់ព្រះអង្គៈ

*មើល នឹងមានពេលវេលាមក ក៏មកដល់ហើយ នោះអ្នករាល់គ្នានឹងត្រូវខ្ចាត់ខ្ចាយទៅដោយខ្លួនៗ ទាំងទុកខ្ញុំចោលឲ្យនៅតែឯកឯង តែខ្ញុំមិននៅតែឯកឯងទេ គឺមានព្រះវរបិតាគង់ជាមួយនឹងខ្ញុំដែរ។*

*ខ្ញុំប្រាប់សេចក្តីទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នា បានសេចក្តីសុខសាន្តដោយសារខ្ញុំ នៅលោកីយ៍នេះ នោះអ្នករាល់គ្នាមានសេចក្តីវេទនាមែន ប៉ុន្តែ ត្រូវសង្ឃឹមឡើង ដ្បិតខ្ញុំបានឈ្នះលោកីយ៍ហើយ។*

*យ៉ូហាន១៦:៣២-៣៣*

## *២. «ចូរខំប្រឹងយ៉ាងម៉ឺងម៉ាត់» ក្នុងការចូលទៅក្នុងជីវិត*

មិនមែនអ្វីៗនៅក្នុងជីវិតរបស់អ្នកត្រូវបានបញ្ចប់ហើយនោះទេ គ្រាន់តែមួយចំណែកប៉ុណ្ណោះដែលបានចប់។ រដូវកាលមួយបានកន្លងផុតទៅ រដូវកាលថ្មីចាប់ផ្ដើម ប្រសិនបើអ្នករួចរាល់ក្នុងការបញ្ចេញសកម្មភាព។

កុំអង្គុយអសកម្ម ហើយរង់ចាំអ្វីមួយកើតឡើង ឬអ្នកណាម្នាក់នាំយកអ្វីដល់យើង។ ចូរអធិស្ឋាន ហើយបោះជំហានដោយជំនឿ។

ខ្ញុំបានចែកចាយជាមួយអ្នកពីមុនហើយអំពីម្ដាយមីងខ្ញុំ ពីការលំបាកយ៉ាងណារបស់នាងក្នុងការចាប់ផ្ដើមជីវិតថ្មីបន្ទាប់ពីពូរបស់ខ្ញុំបានស្លាប់ទៅ។ គ្មានការលំបាកណាដែលនាងបានឆ្លងកាត់ដូចការលំបាកនេះទេ។ ពេលនេះនាងបានធ្វើដំណើរជាមួយខ្ញុំនិងស្វាមីរបស់ខ្ញុំជួយព័ន្ធកិច្ចរបស់យើងក្នុងការបំរើមនុស្សផ្សេងៗ។ នៅក្នុងការប្រជុំរបស់យើង នាងលក់ការសែតដែលយើងបានធ្វើសិក្ខាសាលា នៅផ្ទះនាងបានចំអិនអាហារសម្រាប់យើង នាងជួយមើលថៃចៅៗរបស់យើងថែមទៀតផងប្រសិនបើនាងមានពេល។

ការទាំងអស់នេះជាប្រយោជន៍ដ៏លើសលប់សម្រាប់យើង និងសម្រាប់នគរព្រះ។ នាងបានខំប្រឹងយ៉ាងម៉ឺងម៉ាត់ ក្នុងការចូលទៅក្នុងការរស់នៅក្នុងជីវិតថ្មី ហើយជាបន្តបន្ទាប់ បានក្លាយជាព្រះពរសម្រាប់អ្នកដទៃ។

ប្រសិនបើអ្នកនៅម្នាក់ឯង កុំគ្រាន់តែអង្គុយបន់ឲ្យអ្នកបានជួបអ្នកផ្សេងៗទៀត។*ចូរចេញទៅហើយបង្កើតមិត្តសម្លាញ់!* ចូរស្វែងរកអ្នកដទៃម្នាក់ទៀតដែលនៅម្នាក់ឯងដូចអ្នកដែរ អ្នកនោះអាចឯកោជាងអ្នកផង ហើយធ្វើជាមិត្តសម្លាញ់ជាមួយអ្នកនោះ។ អ្នកនឹងបានច្រូតពីអ្វីដែលអ្នកបានព្រោះ។ ព្រះអង្គនឹងប្រទានមិត្តភាពនោះមកដល់អ្នកវិញ ធ្វើឲ្យទ្វេគុណឡើងសម្រាប់អ្នក។

សាន់ដ្រាជាកូនស្រីរបស់យើង បានឆ្លងកាត់ភាពឯកោនៅពេលដែលនាងនៅវ័យក្មេង។ មិត្តសម្លាញ់របស់នាងខ្លះបានចេញពីមហាវិទ្យាល័យ ខ្លះទៀតរៀបការ

ដូច្នេះនាងចំណាយពេលល្ងាចៗភាគច្រើនឯកោតែម្នាក់ឯងនៅផ្ទះ។

ជំនួសដោយការអង្គុយម្នាក់ឯងឯកោអាណិតខ្លួនឯង នាងចាប់ផ្តើមខំប្រឹងយ៉ាងម៉ឺងម៉ាត់ក្នុងការបោះជំហានទៅមុខ ទៅកន្លែងមួយដោយខ្លួនរបស់នាង។ នាងអាចចូលរួមនៅព្រះវិហារតែម្នាក់ឯង ឬទៅច្រៀងតែម្នាក់ឯងជាមួយក្រុមជំនុំផ្សេងដោយខ្លួនឯង។ វាមិនមែនជាការងាយស្រួលសម្រាប់នាងទេ តែនាងដឹងថានាងបានធ្វើអ្វីមួយក្រៅពីការអង្គុយហើយបន់ឲ្យមានមិត្តសម្លាញ់។

អ្នកអាចនិយាយថា «ចយស៍អើយ ខ្ញុំមិនប៉ងទេ តែខ្ញុំជឿ។» តែខ្ញុំចង់រំលឹកអ្នកថា ព្រះគម្ពីរបានបង្រៀនយើងថា ជំនឿរបស់យើងជម្រុញព្រះឲ្យធ្វើចលនា(យ៉ាកុប ២:១៧)។ ខ្ញុំមិនបានណែនាំអ្នកឲ្យធ្វើដោយសាច់ឈាមនោះទេ ឬដោយចំណងខាងសាច់ឈាមឡើយ ប៉ុន្តែខ្ញុំណែនាំឲ្យមានសេចក្តីក្លាហាន ហើយបោះជំហានតាមការដឹកនាំរបស់ព្រះ។

ពេលនេះសាន់ដ្រាបានរៀបការជាមួយ ស្ទីវ ជាក្មេងកំទ្បោះម្នាក់ដែលនាងបានជួបនៅពេលដែលនាងរង់ចាំម្នាក់ឯង។«សកម្មភាពម៉ឺងម៉ាត់» របស់នាងធ្វើឲ្យនាងមានជំនឿនិងគោលដៅ។

ដូចគ្នានឹងការដាក់«ចិត្តកាយ»ចំពោះការអធិស្ឋានរបស់អ្នកដែរ។ ចូរឲ្យភាពឯការបស់អ្នក បានប្រសូតមកជាក្តីមេត្តា នៅក្នុងអ្នកសម្រាប់អ្នកដទៃដែលមានភាពឯកា ហើយ*សម្រេចចិត្តក្នុងការធ្វើអ្វីមួយជាមួយនឹងការនោះ!*

ចូរអានហើយពិចារណាចំពោះបទគម្ពីរដែលមាននៅក្នុងផ្នែកខាងក្រោយនេះ ចូរអនុញ្ញាតឲ្យព្រះមានបន្ទូលមកកាន់អ្នក តាមរយៈបទគម្ពីរទាំងនោះនៅក្នុងស្ថានភាពបច្ចុប្បន្នរបស់អ្នក។

# ជំពូក ២

## ខព្រះគម្ពីរ

# ខព្រះគម្ពីរ
# ដើម្បីយកឈ្នះ
# ភាពឯកានិងភាពទុក្ខសោក

***ព្រះអង្គគង់ជាមួយអ្នកជានិច្ច***

*... ដ្បិតទ្រង់មានព្រះបន្ទូលថា «អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ»*

*ហេព្រើរ១៣:៥*

*...ដោយព្រោះវាបានយកអញជាទីស្រឡាញ់នោះអញនឹងជួយឲ្យរួចអញនឹងតាំងឡើងយ៉ាងខ្ពស់ពីព្រោះវាបានស្គាល់ឈ្មោះអញ។*

*វានឹងអំពាវនាវដល់អញ ហើយអញនឹងឆ្លើយតប អញនឹងនៅជាមួយនឹងវាក្នុងគ្រាទុក្ខលំបាកក៏នឹងដោះឲ្យរួចចេញ ហើយនឹងលើកមុខឲ្យ*

*ទំនុកដំកើង៩១:១៤-១៥*

***អ្នកអាចត្រូវបានបំបែកចេញពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់បានទេ***

*តើអ្នកណានឹងពង្រាត់យើងចេញពីសេចក្ដីស្រឡាញ់របស់ផងព្រះគ្រីស្ទបាន តើសេចក្ដីទុក្ខលំបាក ឬសេចក្ដីវេទនា សេចក្ដីបៀតបៀន សេចក្ដីអត់ឃ្លាន សេចក្ដីអាក្រាត សេចក្ដីអន្តរាយ ឬដាវឬអី។*

*ដ្បិតខ្ញុំជឿជាក់ថា ទោះស្លាប់ ឬរស់ ពួកទេវតា ឬអំណាចអ្វី ការអ្វីនៅជាន់នេះ ឬទៅមុខ ឬឥទ្ធិឫទ្ធិអ្វី។*

*ទីមានកំពស់ ទីជំពៅ ឬរបស់អ្វីដែលកើតមកឯទៀតក្តី នោះពុំអាចនឹងពង្រាត់យើង ចេញពីសេចក្តីស្រឡាញ់របស់ព្រះ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នាទៅ បានឡើយ។*

*រ៉ូម៨:៣៥,៣៨,៣៩*

## ***ព្រះអង្គនឹងថែរក្សាអ្នក***

*ព្រះអម្ចាស់ជាគង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វីសោះឡើយ។ ទំនុកតម្កើង២៣:១*

*ព្រះជាម្ចាស់ដែលគង់នៅក្នុងព្រះដំណាក់ដ៏វិសុទ្ធ* ព្រះអង្គជាឪពុករបស់ក្មេងកំព្រា ព្រះអង្គរកយុត្តិធម៌ឲ្យស្ត្រីមេម៉ាយ។*

*ព្រះជាម្ចាស់ប្រទានគ្រួសារឲ្យមនុស្សឯកោ ព្រះអង្គនាំអ្នកជាប់ឃុំឃាំង ឲ្យមានសេរីភាពពេញទី រីឯជនបះបោរវិញ គេនឹងក្នុងទីហួតហែង។*

*ទំនុកតម្កើង៦៨:៥-៦*

*ទោះបីឪពុកម្តាយរបស់ទូលបង្គំ បានបោះបង់ទូលបង្គំចោលក៏ដោយ ក៏ព្រះអម្ចាស់នៅតែទទួលទូលបង្គំជានិច្ច!។*

*ទំនុកតម្កើង២៧:១០*

*កុំឲ្យខ្លាចឲ្យសោះ ដ្បិតឯងនឹងមិនដែលត្រូវខ្មាសឡើយ ក៏កុំឲ្យរង្កៀសចិត្តដែរ ពីព្រោះឯងនឹងមិនដែលត្រូវមានសេចក្តីខ្មាសទេ ឯងនឹងភ្លេចសេចក្តីខ្មាសដែលឯងមានពីកាលនៅវ័យក្មេង ហើយឯងនឹងមិននឹកចាំពីសេចក្តីដែលគេត្មះតិះដៀល ពីកាលនៅមេម៉ាយតទៅទៀតដែរ*

*ដ្បិតព្រះដែលបង្កើតឯងមក ទ្រង់ជាប្តីរបស់ឯងហើយ ព្រះនាមទ្រង់គឺយេហូវ៉ានៃពួកពលបរិវារហើយព្រះដ៏ប្រោសលោះឯង គឺជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល គេនឹងហៅទ្រង់ថា ជាព្រះនៃលោកីយ៍ទាំងមូល។*

*អេសាយ៥៤:៤-៥*

***ព្រះអង្គនឹងធ្វើការមួយថ្មី***

*កុំឲ្យឯងរាល់គ្នានឹងចាំពីការទាំងប៉ុន្មានដែលកន្លងទៅហើយ ឬរិះគិតពីអស់ទាំងការពីចាស់បុរាណនោះឡើយ។*

*មើល អញនឹងធ្វើការ១ថ្មីវិញ ការនោះនឹងលេចឡើងឥឡូវ តើឯងរាល់គ្នានឹងមិនស្គាល់ទេឬ អញនឹងធ្វើផ្លូវ១នៅទីរហោស្ថាន ហើយទន្លេនៅសមុទ្រខ្សាច់។*

*អេសាយ៤៣:១៨-១៩*

***ចូរបន្តធ្វើថែមទៀត***

*បងប្អូនអើយ ខ្ញុំមិនរាប់ថាខ្លួនខ្ញុំចាប់បានហើយនោះទេ តែមានសេចក្តីនេះ១ គឺថា ខ្ញុំភ្លេចសេចក្តីទាំងប៉ុន្មានដែលកន្លងទៅហើយ ក៏ខំមមុលឈោងទៅឯសេចក្តីខាងមុខទៀត។*

*ទាំងរត់ដំរង់ទៅឯទី ដើម្បីឲ្យបានរង្វាន់នៃការងារដ៏ខ្ពស់របស់ព្រះ ក្នុងព្រះគ្រីស្ទយេស៊ូវ។*

*ភីលីព៣:១៣-១៤*

សូមកុំចុះចាញ់ កុំបោះបង់ចោល។ ជំនួសមកវិញ សូមប្រឹងប្រែងបន្តទៅមុខទៀតយ៉ាងសកម្ម!

***ព្រះអង្គមិនទាន់បញ្ចប់ជាមួយអ្នកនៅឡើយទេ!***

*ដ្បិតព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា អញស្គាល់សេចក្តីដែលអញគិតពីដំណើរឯងរាល់គ្នា មិនមែនគិតធ្វើសេចក្តីអាក្រក់ទេ គឺគិតឲ្យបានសេចក្តីសុខវិញ ដើម្បីដល់ចុងបំផុត ឲ្យឯងរាល់គ្នាបានសេចក្តីសង្ឃឹម។*

*យេរេមា២៩:១១*

# សេចក្ដីបញ្ចប់

ចូរខំប្រឹងយ៉ាងម៉ឺងម៉ាត់ឆ្ពោះទៅរករដូវកាលបន្ទាប់នៃជីវិតរបស់អ្នក។ អ្វីៗមិនអាចនៅតែដដែលៗដូចដែលពួកគេធ្លាប់ជួបនោះទេ ប៉ុន្តែ សូមកុំឲ្យខកខានអស់មួយជីវិតរបស់អ្នកដោយសារតែរស់នៅក្នុងអតីតកាលនោះ។

ពេលកំណត់បានមកដល់ហើយ ក្នុងការឈប់គិតនិងឈប់និយាយពីអតីតកាល។ អ្នកមានអនាគត។ ព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅក្បែរដើម្បីជួយអ្នក កំសាន្តចិត្តអ្នក ហើយគាំទ្រអ្នកក្នុងការបន្តទៅមុខទៀតដើម្បីបំពេញផែនការដ៏អស្ចារ្យដែលព្រះមានសម្រាប់អ្នក។

*ចូរចងចាំថា: ព្រះមិនទាន់បញ្ចប់ជាមួយអ្នកនៅឡើយទេ!*

### *នៅទីបញ្ចប់ តែងតែផ្ដល់នូវការចាប់ផ្ដើមជាថ្មីជានិច្ច*

នៅក្នុងយ៉ូហាន១០:១០ ព្រះយេស៊ូមានបន្ទូលថា «ចោរវាមកគិតតែពីលួចប្លន់ គិតតែពីសម្លាប់ និងបំផ្លាញប៉ុណ្ណោះ។ រីឯខ្ញុំវិញ ខ្ញុំមកដើម្បីឲ្យមនុស្សលោកមានជីវិតហើយឲ្យគេមានជីវិតពេញបរិបូណ៌(បំពេញឲ្យមានហូរហៀរ)»។

មិនថាជីវិតរបស់អ្នកល្អ ឬអាក្រក់ មុនពេលដែលអ្នកបានបាត់បង់ អ្នកមិនអាចរស់នៅក្នុងអតីតកាល ហើយរីករាយនៅក្នុងជីវិតបច្ចុប្បន្ននិងអនាគតបាននោះទេ។

អ្វីក្ដីដែលអ្នកបានបាត់បង់ ចូរប្ដេជ្ញាមិនត្រូវភ្លេចអ្វីដែលនៅសល់នោះទេ។

ចូរចងចាំ:

ព្រះអង្គល្អ។

ព្រះអង្គស្រឡាញ់អ្នកខ្លាំងណាស់។

ព្រះអង្គមានផែនការល្អសម្រាប់ជីវិតរបស់អ្នក។

# ការអធិស្ឋាននិងព្រះពរ

ពេលនេះខ្ញុំចង់អធិស្ឋានសម្រាប់អ្នក និងផ្តល់ដល់អ្នកនូវពាក្យលើកទឹកចិត្តចុងក្រោយៈ

*ព្រះវរបិតាអើយ ខ្ញុំម្ចាស់ចូលមករកព្រះអង្គ ក្នុងនាមព្រះយេស៊ូគ្រិស្ត ដែលឈរនៅចំពោះព្រះអង្គ ហើយព្រះអង្គជាអ្នកតំណាង ហើយទូលសូមព្រះគុណនិងក្តីមេត្តាសម្រាប់ខ្ញុំម្ចាស់។*

*ខ្ញុំម្ចាស់សូមអធិស្ឋានសម្រាប់មនុស្សវិសេសទាំងនេះ ដែលទទួលរងការឈឺចាប់។ ខ្ញុំម្ចាស់ទូលសូម ព្រះវិញ្ញាណដ៏វិសុទ្ធបានបង្ហូរព្រះវត្តមានរបស់ព្រះអង្គមកដល់យើងខ្ញុំម្នាក់ៗនៅពេលនេះ។ ព្រះអង្គមានបន្ទូលថា ទ្រង់គឺជាព្រះដែលប្រោសឲ្យជា ដល់អ្នកដែលមានចិត្តខ្ទេចខ្ទាំ។ ព្រះអង្គបានសន្យាថានឹងរុំរបួសរបស់ទូលបង្គំយើងខ្ញុំ ហើយប្រោសស្នាមដាំរបស់ទូលបង្គំយើងខ្ញុំឲ្យបានជាសះស្បើយ។*

*ទូលបង្គំយើងខ្ញុំសម្លឹងទៅឯព្រះអង្គ ព្រោះព្រះអង្គពិតជាជំនួយរបស់ទូលបង្គំយើងខ្ញុំ នៅពេលដែលយើងខ្ញុំត្រូវការ។ ព្រះអង្គបានសន្យាថានឹងមិនទុកឲ្យយើងខ្ញុំនៅតែម្នាក់ឯង ឯកា នៅក្នុងគ្រួសាររបស់យើងខ្ញុំនោះទេ។ ខ្ញុំម្ចាស់ទូលសូម ព្រះអម្ចាស់ ឲ្យធ្វើការនេះស្របតាមព្រះបន្ទូលហើយប្រទានដល់បុត្រនិងមិត្តសម្លាញ់និងគ្រួសាររបស់ព្រះអង្គ ដែលបានយកចិត្តទុកដាក់ជាមួយពួកគេ។*

*សូមជួយអ្នកនេះ ព្រះវិញ្ញាណអើយ ប្រសិនបើពួកគេបោះជំហានដោយជំនឿដើម្បីសាងជីវិតថ្មី។ ខ្ញុំម្ចាស់ទូលសូមឲ្យពួកគេបានចម្រុងចម្រើនទាំងផ្លូវចិត្ត ផ្លូវកាយនិងខាងវិញ្ញាណព្រមទាំងផ្នែកហិរញ្ញវត្ថុនិងផ្នែកសង្គម។ អាម៉ែន។*

ឱ កូនស្ងួនភ្ងាររបស់ព្រះអើយ ខ្ញុំជឿថាប្រេងតាំងនៃព្រះវិញ្ញាណដ៏វិសុទ្ធនឹងហូរមកលើអ្នកនៅពេលនេះ។ ខ្ញុំសូមណែនាំអ្នកឲ្យនៅជាប់ក្នុងវត្តមានរបស់ព្រះនៅក្នុងពេលណាមួយ អនុញ្ញាតឲ្យព្រះបានធ្វើការក្នុងអ្នក។ អនុញ្ញាតទ្រង់ផ្តល់ព្រះបន្ទូលដែលខ្ញុំបានចែកចាយជាមួយអ្នកហើយរង់ចាំ ទុកចិត្តលើទ្រង់ក្នុងការធ្វើការក្នុងអ្នក។

ខ្ញុំជឿថា ខ្យល់នៃព្រះវិញ្ញាណកំពុងបក់បោកលើអ្នកហើយរៀបចំអ្នកដើម្បីចូលទៅក្នុងរដូវកាលថ្មីនៅក្នុងជីវិតរបស់អ្នក។ សូមឲ្យក្ដីស្រឡាញ់របស់ព្រះអង្គ ព្រះគុណនៃព្រះអម្ចាស់ព្រះយេស៊ូគ្រិស្ដជាព្រះនៃយើង និងការរួមប្រកបជាមួយព្រះវិញ្ញាណដ៏វិសុទ្ធបាននៅជាមួយអ្នក។

អ្នកស្រីចយស៍បានណែនាំអ្នកឲ្យទទួលតន្ត្រី កាសែតចែកចាយព្រះបន្ទូលដែលមានចំណងជើងថា *«ការប្រោសឲ្យជាដួងចិត្តខ្ទេចខ្ទាំ»* ការសែតពិសេសនេះបានជួយមនុស្សរាប់ពាន់នាក់ មានបទពិសោធន៍ ជាមួយនឹងការប្រោសឲ្យជាដោយសារអំណាចនៃព្រះនៅក្នុងអារម្មណ៍របស់គេ ហើយអ្នកស្រីចយស៍ក៏មានជំនឿផងដែរថា វាក៏អាចជួយអ្នកបានដែរ។ ថែមពីលើនោះ អ្នកស្រីចយស៍បានណែនាំតន្ត្រីទីពីរនិងការសែតចែកចាយព្រះគម្ពីរមានចំណងជើងថា «ចូរមានកម្លាំង និងចិត្តក្លាហានឡើង!» ដើម្បីជាវការសែតវីដេអូនេះ សូមសរសេរមកកាន់អស័យដ្ឋានដែលបានផ្ដល់ជូននៅខាងក្រោយសៀវភៅនេះ។

# ការអធិស្ឋាន
# សំរាប់ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះជាម្ចាស់

ព្រះយេស៊ូគាប់ព្រះហឫទ័យក្នុងការសង្គ្រោះអ្នក និង ចាក់បំពេញអ្នកនូវព្រះវិញ្ញាណដ៏វិសុទ្ធលើសជាងអ្វីៗទាំងអស់។ បើអ្នកមិនទាន់យាងព្រះអម្ចាស់ព្រះយេស៊ូ ជាស្តេចនៃសន្តិភាព ជាព្រះអម្ចាស់និងព្រះអង្គសង្គ្រោះរបស់អ្នកនៅឡើយ ខ្ញុំសូមអញ្ជើញអ្នកឲ្យទទួលព្រះអង្គនៅពេលនេះ។ សូមអធិស្ឋានតាមសេចក្តីអធិស្ឋានដូចតទៅនេះ ហើយប្រសិនជាអ្នកពិតជាធ្វើដោយស្មោះត្រង់ពីចិត្តមែន អ្នកនឹងមានបទពិសោធន៍ជីវិតថ្មីក្នុងព្រះគ្រិស្ត។

*ព្រះវរបិតា*

*ព្រះអង្គ ទ្រង់ស្រឡាញ់ មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីឲ្យអស់អ្នកដែលជឿលើព្រះរាជបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនឲ្យគេវិនាសឡើយ។*

*ព្រះបន្ទូលរបស់ព្រះអង្គថា យើងខ្ញុំបានសង្គ្រោះដោយសារព្រះគុណ តាមរយៈជំនឿ។ ការសង្គ្រោះមិនមែនមកពីការប្រព្រឹត្តអំពើល្អទេ។*

*ទូលបង្គំជឿហើយប្រកាសនឹងមាត់ថា ព្រះយេស៊ូជាព្រះរាជបុត្រាព្រះអង្គ ជាព្រះសង្គ្រោះនៃពិភពលោក ។ ទូលបង្គំជឿថា ទ្រង់សុគត់លើឈើឆ្កាងសម្រាប់ទូលបង្គំនិងបានទទួលគ្រប់ទាំងអំពើបាបរបស់ទូលបង្គំ បង់ថ្លៃជំនួសបាបទូលបង្គំ។ ទូលបង្គំជឿនៅក្នុងចិត្តរបស់ទូលបង្គំថា ទ្រង់បានលើកព្រះគ្រិស្តពីសេចក្តីស្លាប់។*

*ទូលបង្គំសូមព្រះអង្គអត់ទោសបាបទូលបង្គំ។ ទូលបង្គំប្រកាសថា ព្រះយេស៊ូជាព្រះអម្ចាស់របស់ទូលបង្គំ។ យោងតាមព្រះបន្ទូលរបស់ព្រះអង្គ ទូលបង្គំបានសង្គ្រោះហើយនឹងរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច! អរព្រះគុណ ព្រះអង្គ*

*ព្រះវរបិតាអើយ ទូលបង្គំអរគុណព្រះអង្គដោយកត្តញ្ញូបំផុត! ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត អាម៉ែន។*

សូមអាន យ៉ូហាន៣:១៦; អេភេសូរ២:៨,៩; រ៉ូម១០:៩,១០, ១កូរិនថូស១៥:៣៤; ១យ៉ូហាន១:៩; ៤:១៤,១៦;៥:១២,១៣។

# ការអធិស្ឋានដើម្បីបានសង្គ្រោះ

"ព្រះអម្ចាស់ស្រឡាញ់អ្នក ហើយចង់មានទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នក។ បើសិនជា អ្នកមិនទាន់ទទួលព្រះយេស៊ូគ្រិស្តជាព្រះអង្គសង្គ្រោះរបស់អ្នកនៅឡើយ នោះអ្នកអាចទទួលឥឡូវនេះបាន។ សូមបើកចំហដួងចិត្តរបស់អ្នកចំពោះព្រះអង្គ និង អធិស្ឋានដូចខាងក្រោម:

"ឱព្រះវរបិតាអើយ ទូលបង្គំដឹងថា ទូលបង្គំមានបាបទាស់នឹងព្រះអង្គ។ សូមអត់ទោសបាបដល់ទូលបង្គំ សូមលាងសំអាតទូលបង្គំ។ ទូលបង្គំសន្យាថា ទុកចិត្តព្រះយេស៊ូ ជាព្រះរាជបុត្រារបស់ព្រះអង្គ។ ទូលបង្គំជឿថា ព្រះយេស៊ូសុគតដោយព្រោះទូលបង្គំ ព្រះអង្គទ្រង់បានយកបាបរបស់ទូលបង្គំដាក់លើអង្គទ្រង់ នៅពេលទ្រង់សុគតនៅលើឈើឆ្កាង។ ទូលបង្គំជឿថា ព្រះអង្គបានមានព្រះជន្មរស់ពីសុគតឡើងវិញ។ ទូលបង្គំសូមថ្វាយជីវិតដាច់ដល់ព្រះអង្គឥឡូវនេះ។
ទូលបង្គំ សូមអរព្រះគុណដល់ព្រះវរបិតាដែលបានប្រទានការអត់ទោស និងជីវិតអស់កល្ប។សូមព្រះអង្គជួយដល់ទូលបង្គំដើម្បីរស់នៅសំរាប់ព្រះអង្គ។ ទូលបង្គំអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត! អាម៉ែន"

នៅពេលអ្នកអធិស្ឋានចេញពីដួងចិត្តរបស់អ្នក ព្រះជាម្ចាស់បានទទួលយកអ្នក សំអាតអ្នក និង រំដោះអ្នកឲ្យមានសេរីភាពពីចំណងនៃសេចក្តីស្លាប់ខាងវិញ្ញាណ។ សូមចំណាយពេលអាន និង សិក្សាព្រះបន្ទូលទាំងនេះ ហើយទូលសូមព្រះជាម្ចាស់ដើម្បីនិយាយទៅកាន់អ្នក ដូចជាអ្នកដើរជាមួយទ្រង់តាមរយៈដំណើរនេះនៅក្នុងជីវិតថ្មីរបស់អ្នក។

| | |
|---|---|
| យ៉ូហាន ៣:១៦ | ១កូរិនថូស ១៥:៣-៤ |
| ១ យ៉ូហាន ១:៩ | ១ យ៉ូហាន ៤:១៤-១៥ |
| អេភេសូរ ១:៤ | អេភេសូរ ២:៨-៩ |
| ១ យ៉ូហាន ៥:១ | ១ យ៉ូហាន ៥:១២-១៣ |

សូមអធិស្ឋាននិងទូលសុំព្រះឲ្យជួយអ្នករកបានព្រះវិហារដែលមានជំនឿតាមព្រះគម្ពីរ ដែលអាចជួយអ្នកឲ្យរីកចំរើននៅក្នុងទំនាក់ទំនងរបស់អ្នកជាមួយព្រះគ្រិស្ត។ ព្រះជាម្ចាស់គង់ជាមួយអ្នកជានិច្ច។ ព្រះទ្រង់នឹងដឹកនាំអ្នកពីមួយថ្ងៃទៅមួយថ្ងៃ ហើយនឹងបង្ហាញអ្នកពីរបៀបរស់នៅជីវិតពេញបរិបូរដែលព្រះអង្គមានសំរាប់អ្នក!

# អំពីអ្នកនិពន្ធ

អ្នកស្រីចយស៍ជាគ្រូបង្រៀនព្រះបន្ទូលតាំងពីឆ្នាំ១៩៧៦ ហើយបានបំរើការពេញម៉ោងតាំងពីឆ្នាំ១៩៨០។ អ្នកស្រីជាអ្នកនិពន្ធដែលលក់ដាច់ជាងគេបំផុតដែលមានសៀវភៅជំរុញចិត្តជាង៥៤ក្បាលរួមជាមួយ អាថ៌កំបាំងនៃការរស់នៅដ៏អស្ចារ្យ អំណាចនៃការជឿលើសេចក្តីអធិស្ឋាន ហើយនិងសមរភូមិនៃគំនិត។ រួមជាមួយនឹងកាសែតជាង២២០អាល់ប៊ុម ហើយមានជាង៩០វីដេអូ។ ការចាក់ផ្សាយតាមវិទ្យុ ជីវិតក្នុងព្រះបន្ទូលរបស់ចយស៍និងតាមកម្មវិធីទូរទស្សន៍ដែលកំពុងផ្សាយនៅជុំវិញពិភពលោកក្នុងកម្មវិធី ជីវិតរីករាយប្រចាំថ្ងៃ។ អ្នកស្រីធ្វើដំណើរយ៉ាងសកម្ម ដើម្បីចែកចាយព្រះបន្ទូលដែលកំពុងពេញនិយមតាមរយៈសិក្ខសាលាអំពី «ជីវិតនៅក្នុងព្រះបន្ទូល»។ អ្នកស្រីចយស៍និងស្វាមីរបស់គាត់គឺលោកដេវមានកូនបួននាក់ហើយរស់នៅក្នុងរដ្ឋ St. Louis, Missouri។

# សៀវភៅផ្សេងទៀតដែលនិពន្ធដោយអ្នកស្រី ចយស៍ ម៉ៃយ័រ

The Everyday Life Bible (hardcover or bonded Leather)

The Confident Woman

Look Great Fell Great

Battlefield of the Mind*

Battlefield of the Mind Devotional

Approval Addition

Ending Your Day

In Pursuit of Place

The Secret Power of Speaking God's Word

Seven Things That Steal Your Joy

Starting Your Day Right

Beauty for Ashes (revised edition)

How to Hear from God*

Knowing God Intimately

The Power of Simple Prayer

The Battle belongs to the Lord

The Secrets to Exceptional Living

Eight Ways to keep the Devil Under Your Feet

Teenagers Are People Too!

Filled with the Spirit

Celebration of Simplicity

The Joy of Believing Prayer

Never Lose Heart

Being the person God Made You to Be

A Leader in the Making

“ Good Morning, This Is God! ” (gift books)

Jesus- Name Above All Names

Making Marriage Work

(Previously published as Help Me-I’m Married)

Reduce me to Love

Be Healed in Jesus’s Name

How to Succeed at Being Yourself

Weary Warriors, Fainting Saints

Be Anxious for Nothing*

Straight Talk Omnibus

Don’t Dread

Managing Your Emotions

Healing the Brokenhearted

Me and My Big Mouth!*

Prepare to Proper

Do It Afraid!

Expect a Move of God in Life… Suddenly!

Enjoying Where Your Are on the Way

To Where You Are Going

The Most Important Decision You Will Ever Make

When, God, When?

Why, God, Why?

The Word, the Name, the Blood

Tell Them I Love Them

Peace

If Not for the Grace of God*

# សៀវភៅសរសេរដោយលោកដេវ

Life Lines

# អ្នកមិនឯកាទេ!

តើអ្នកធ្លាប់មានបទពិសោធន៍ការបាត់បង់នៅក្នុងជីវិតរបស់អ្នកឬទេ? ការបាត់បង់ដែលបន្សល់ទុកដល់អ្នកនូវអារម្មណ៍ឯកា អសមត្ថភាព ឬនៅក្នុងក្ដីអស់សង្ឃឹម? ប្រហែលជាអ្នកដែលជាទីស្រឡាញ់របស់អ្នកបានបាត់បង់ជីវិត ឬបែកបាក់មិត្តសម្លាញ់ជិតស្និទ្ធណាម្នាក់ ឬប្រហែលជាភាពឯកាដោយសារការយល់ខុស។ មានហេតុផលជាច្រើនដែលធ្វើឲ្យមនុស្សមានអារម្មណ៍ឯកា តែអរគុណដល់ព្រះ យើងអាចយកឈ្នះវាដោយសារព្រះបន្ទូលរបស់ទ្រង់!

នៅក្នុងសៀវភៅនេះ អ្នកស្រីចយស៍ ម៉ៃយ័រ ជាអ្នកនិពន្ធដែលលក់ដាច់ជាងគេបំផុតនឹងបង្រៀនអ្នកពីរបៀបនៃការយកជ័យជម្នះអារម្មណ៍នៃភាពឯកា និងការរកឃើញនូវកម្លាំងថ្មី សង្ឃឹមថ្មី និងអំណរថ្មីតាមរយៈព្រះអម្ចាស់ព្រះយេស៊ូ។ អ្នកស្រីនឹងផ្ដល់ជូនដល់អ្នកនូវការអនុវត្តន៍ជាក់ស្ដែង និងវិធីដែលមានឥទ្ធិពលដើម្បីប្រឆាំងជាមួយនឹងភាពឯកានិងភាពសោកស្ដាយ ដើម្បីឲ្យអ្នកអាចរស់នៅដោយភាពរីករាយ មានជីវិតដែលប្រសើរឡើង។

អាចមានពេលនៅក្នុងជីវិតដែលអ្នកមានអារម្មណ៍ថាឯកា តែចូរចងចាំថា អ្នកមិននៅតែឯងទេ ព្រោះព្រះគង់នៅជាមួយអ្នកហើយ។

---

## ចូររកមើលសៀវភៅផ្សេងៗទៀតនៅក្នុងឈុតទាំងនេះ

.ចូរនិយាយឲ្យចំពីកង្វល់
.ចូរនិយាយឲ្យចំពីការបាក់ទឹកចិត្ត
.ចូរនិយាយឲ្យចំពីការភ័យខ្លាច
.ចូរនិយាយឲ្យចំពីការគ្មានសុវត្ថិភាព
.ចូរនិយាយឲ្យចំពីអារម្មណ៍ធុញថប់
.ចូរនិយាយឲ្យចំពីការព្រួយចិត្ត